ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សេចក្តីព្រាង**

# កម្មវិធីវិនិយោគបីឆ្នាំរំកិល
# ២០២០-២០២២
# ខេត្តកំពង់ស្ពឺ

បានទទួលការអនុម័តពីក្រុមប្រឹក្សាខេត្ត
ក្នុងកិច្ចប្រជុំសាមញ្ញ លើកទី៥៥ ថ្ងៃព្រហស្បតិ៍ ១៤រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កំពង់ស្ពឺ ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ២០១៨

# មាតិកា

ទំព័រ

**សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត** ........................ ii

**អារម្ភកថា** ........................ v

**សេចក្តីផ្តើម** ........................ ១

**ផែនទី** ........................ ៣

**ជំពូកទី១ ៖ ស្ថានភាពទូទៅ និងបញ្ហាប្រឈមក្នុងខេត្ត** ........................ ៤

១.១.សេចក្តីសង្ខេបទិន្នន័យចម្បងរបស់ខេត្ត ........................ ៥

១.២.ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ........................ ៩

១.២.១.ផ្នែកសេដ្ឋកិច្ច ........................ ១០

១.២.២.ផ្នែកសង្គមកិច្ច ........................ ២៧

១.២.៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ........... ៤១

១.២.៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........................ ៤៧

**ជំពូកទី២ ៖ គម្រោង សកម្មភាព នៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត** ........................ ៥៣

២.១. តារាងសង្ខេបប្រភពមូលនិធិ ........................ ៥៤

២.២. តារាងគម្រោង សកម្មភាពកំពុងដំណើរការ ........................ ៥៧

២.៣. តារាងគម្រោង សកម្មភាពវិនិយោគមានថវិកាគាំទ្រ ........................ ៨២

២.៤. តារាងគម្រោង សកម្មភាពអាទិភាពមិនទាន់មានថវិកាគាំទ្រ ........................ ៩៤

២.៥. តារាងកម្មវិធីប្រតិបត្តិការសេវារដ្ឋបាល ........................ ១២១

២.៦. តារាងការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា ........................ ១២៤

២.៧. តារាងគម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័នកំពុងដំណើរការ ........................ ១២៥

**ជំពូកទី៣ ៖ ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត** . ១២៧

ឧបសម្ព័ន្ធនានា

ឧបសម្ព័ន្ធទី១ ៖ សេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ឧបសម្ព័ន្ធទី២ ៖ ព័ត៌មានស្តីពីពិន្ទុវិស័យតាមបណ្តាក្រុង ស្រុក ខេត្តកំពង់ស្ពឺ ឆ្នាំ ២០១៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តកំពង់ស្ពឺ**
លេខ ៖................សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២២)
## របស់ខេត្តកំពង់ស្ពឺ

## ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបោះឆ្នោតក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/០៣១៦/៣១៦ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ របស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថនរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា ១២ នៃអនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងប្រកាសអន្តរក្រសួងលេខ ៣៥១៤ ប្រក ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងតាមស្មារតីនៃកិច្ចប្រជុំសាមញ្ញលើកទី៥៥ នាថ្ងៃព្រហស្បតិ៍ ១៤រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ២០១៨។

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២២) របស់ខេត្តកំពង់ស្ពឺ ដែលបានអនុម័តដោយក្រុមប្រឹក្សាខេត្តកំពង់ស្ពឺក្នុងកិច្ចប្រជុំសាមញ្ញលើកទី ៥៥ នាថ្ងៃព្រហស្បតិ៍ ១៤រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ២០១៨។

**ប្រការ ២.-**

គណៈអភិបាលខេត្ត ត្រូវចាត់ចែងផ្សព្វផ្សាយកម្មវិធីវិនិយោគនេះដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ។ គណៈអភិបាលត្រូវចាត់ចែងសម្របសម្រួល និងកៀរគរធនធាននានា ក្នុងការអនុវត្តកម្មវិធីវិនិយោគនេះប្រកបដោយតម្លាភាព គណនេយ្យភាព ការចូលរួម និងប្រសិទ្ធភាពខ្ពស់។

**ប្រការ ៣.-**

គណៈអភិបាលខេត្ត ត្រូវរៀបចំយន្តការ និងប្រព័ន្ធសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានា ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្ត។ គណៈអភិបាលខេត្តត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ និងរាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាខេត្ត អំពីវឌ្ឍនភាពនៃការអនុវត្តផែនការទៅតាមកាលកំណត់។ គណៈអភិបាលខេត្តត្រូវរៀបចំ និងដាក់របាយការណ៍ស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំជូនក្រុមប្រឹក្សា។

**ប្រការ ៤.-**

គណៈអភិបាលខេត្ត ត្រូវធ្វើបច្ចុប្បន្នភាពកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត នៅរៀងរាល់មួយឆ្នាំម្តង ដើម្បីពិនិត្យមើលគម្រោងអាទិភាពនានាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់នៃកម្មវិធីវិនិយោគខេត្ត។

**ប្រការ ៥.-**

គណៈអភិបាលខេត្ត មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធទាំងអស់ក្នុងខេត្ត ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃទី..........................ខែ...........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

កំពង់ស្ពឺ ថ្ងៃទី...........ខែ.............ឆ្នាំ២០១៩

**ជ.ក្រុមប្រឹក្សាខេត្ត**

**ប្រធាន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- លេខាធិការដ្ឋាន គ.ជ.អ.ប
  (<u>ដើម្បីជូនជ្រាប</u>)
- ដូចក្នុងប្រការ៥
  (<u>ដើម្បីអនុវត្ត</u>)
- ឯកសារកាលប្បវត្តិ

# អារម្ភកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រកំណែទម្រង់ថ្មីៗ ពិសេសកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលកំណែទម្រង់នេះជំរុញឱ្យដំណើរការអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការនៅមូលដ្ឋានមានការរីកដុះដាលជាបន្តបន្ទាប់។ ការដាក់ចេញគោលនយោបាយ និងយុទ្ធសាស្ត្រកំណែទម្រង់ មានគោលបំណងបង្ហិតសេវាសាធារណៈឱ្យនៅជិតប្រជាពលរដ្ឋ សំដៅរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមរយៈការអនុវត្តគោលការណ៍អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយចីរភាព។

ទន្ទឹមនឹងនេះ ខេត្តកំពង់ស្ពឺក៏មានការរីកចម្រើនលើគ្រប់វិស័យ ដែលបានធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរឡើងជាលំដាប់ និងបានរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ដើម្បីចូលរួមចំណែកលើមាគ៌ាដ៏ត្រឹមត្រូវក្នុងការលើកកម្ពស់កិច្ចអភិវឌ្ឍន៍ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានប្រកបដោយចីរភាព គណនេយ្យភាព និងតម្លាភាព ការកសាងផែនការអភិវឌ្ឍន៍រយៈពេលវែងមានភាពចាំបាច់បំផុត ដែលតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រាប់អាណត្តិនីមួយៗរបស់ក្រុមប្រឹក្សា។ កម្មវិធីវិនិយោគបីឆ្នាំរំកិលដែលរដ្ឋបាលខេត្តបានរៀបរៀងឡើងដោយសម្រិតសម្រាំងបំផុតនេះមានសារៈសំខាន់ណាស់ក្នុងការចង្អុលទិសដៅ ដើម្បីកំណត់នូវចក្ខុវិស័យ គោលបំណង និងគោលដៅអភិវឌ្ឍន៍ច្បាស់លាស់ និងអាចក្លាយជាមូលដ្ឋានសម្រាប់ឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។

សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២២) ដែលបានរៀបចំឡើងយ៉ាងហ្មត់ចត់ និងមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ គឺជាផែនការប្រតិបត្តិលើកទី៤ របស់ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ អាណត្តិទី២ និងជាឯកសារផ្លូវការសម្រាប់ដឹកនាំការអនុវត្តគម្រោងអភិវឌ្ឍន៍ខេត្ត។

ក្នុងនាមរដ្ឋបាលខេត្តកំពង់ស្ពឺ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ពិសេស គ.ជ.អ.ប បណ្តាមន្ទីរអង្គភាព ជុំវិញខេត្ត ការិយាល័យសមាគម អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន លោក លោកស្រីទាំងអស់ដែលជាមន្ត្រីរាជការក្នុងដែនរដ្ឋបាលថ្នាក់ខេត្ត ក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានរួមចំណែកក្នុងការកសាងកម្មវិធីវិនិយោគនេះឡើង។ រដ្ឋបាលខេត្តសង្ឃឹមយ៉ាងមុតមាំថា សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះនឹងក្លាយជាឧបករណ៍ដែលមានសារៈសំខាន់បំផុតសម្រាប់ឱ្យអ្នកពាក់ព័ន្ធទាំងអស់ប្រើប្រាស់ ដើម្បីគាំទ្រដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខេត្តកំពង់ស្ពឺឱ្យមានការរីកចម្រើនឆ្លើយតបបានសមស្របទៅនឹងតម្រូវការ ដើម្បីធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរ៕

ថ្ងៃទី..........................ខែ...........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

កំពង់ស្ពឺ ថ្ងៃទី...........ខែ.............ឆ្នាំ២០១៩

**ជ.ក្រុមប្រឹក្សាខេត្ត**

**ប្រធាន**

# សេចក្តីផ្តើម

ខេត្តកំពង់ស្ពឺជាខេត្តមួយក្នុងចំណោម ២៥ រាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ហើយមានចម្ងាយ ៤៨ គីឡូម៉ែត្រ ខាងលិចរាជធានីភ្នំពេញ មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកណ្តាល និងខេត្តតាកែវ ខាងត្បូងជាប់នឹងខេត្តតាកែវ និងខេត្តកំពត ខាងលិចជាប់នឹងខេត្តព្រះសីហនុ និងខេត្តកោះកុង ខាងជើងជាប់នឹងខេត្តកំពង់ឆ្នាំង និងខេត្តពោធិសាត់។

ខេត្តកំពង់ស្ពឺ ចែកជា ៧ ស្រុក ១ ក្រុង និងមាន ៨២ ឃុំ និង៥ សង្កាត់ ភូមិមានចំនួន ១,៣៧៩ ក្នុងនោះភូមិមានក្របខ័ណ្ឌចំនួន ១,៣៦៨ ភូមិ និងភូមិអត់ក្របខ័ណ្ឌមានចំនួន ១១ ភូមិ។ មានផ្ទៃដីសរុប ៦,៩៦៩.៦៣ គីឡូម៉ែត្រការ៉េ មានប្រជាពលរដ្ឋសរុបចំនួន ៨៤៨,០៧៦ នាក់ ក្នុងនោះស្ត្រីមានចំនួន ៤៣១,៩៦២ នាក់ មានគ្រួសារសរុបចំនួន ១៧៨,៥៩០ គ្រួសារ ក្នុងនោះគ្រួសារប្រកបរបរកសិកម្មមានចំនួន ៧២.៩%និងមានដង់ស៊ីតេប្រជាពលរដ្ឋ ១២៣ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ។ ខេត្តមានវិស័យកសិកម្មជាវិស័យស្នូល និងមានវិស័យចម្បងផ្សេងៗទៀតដូចជា វិស័យធនធានទឹក អប់រំ សុខាភិបាល និងវិស័យការងារ ក្រៅពីនេះក៏មានការប្រើប្រាស់ដីធ្លីធនធានធម្មជាតិ រដ្ឋបាល និងសន្តិសុខ។

បន្ទាប់ពីការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤ របស់រាជរដ្ឋាភិបាល កំណែទម្រង់ជាច្រើនត្រូវដាក់ចេញដោយរាជរដ្ឋាភិបាល ក្នុងនោះអភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រដែលមានចំណុចសំខាន់៤ គឺការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងប្រព័ន្ធ យុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។ អាស្រ័យដោយមានការផ្លាស់ប្តូរគោលនយោបាយនេះ យើងឃើញថាកំណែទម្រង់រដ្ឋបាលសាធារណៈបានធ្វើឱ្យការគ្រប់គ្រងរដ្ឋបាលដែនដីនៃព្រះរាជាណាចក្រកម្ពុជាមានការប្រែប្រួលទាំងស្រុង ពិសេសច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតឱ្យមានអង្គក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដែលកើតឡើងដោយការបោះឆ្នោតជាសកលពីសំណាក់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន និងអសកលតាមរយៈឃុំ សង្កាត់។ នៅថ្នាក់ឃុំ សង្កាត់ ក្រោយដំណើរការបោះឆ្នោត យើងឃើញថាឃុំ សង្កាត់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ពិសេសការឆ្លើយតបនូវតម្រូវការរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន ការពង្រឹងនូវការផ្តល់សេវាសាធារណៈ ការផ្តល់នូវភាពជាម្ចាស់ពេញលេញជូនប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។ កំណែទម្រង់ រដ្ឋបាលសាធារណៈ និងការអនុវត្តគោលនយោបាយជាយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលកម្ពុជា វិស័យការងារជាច្រើននៅក្នុងថ្នាក់រដ្ឋបាលខេត្តមានការវិវត្តរីកចម្រើនគួរឱ្យមានមោទនភាព ដូចជាវិស័យកសិកម្ម វិស័យអប់រំ វិស័យសុខាភិបាល វិស័យសាធារណការនិងដឹកជញ្ជូន វិស័យអភិវឌ្ឍន៍ជនបទ និងវិស័យធនធានទឹក។ល។ វិស័យទាំងនេះបានរួមចំណែកឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ធ្វើឱ្យជីវភាពរស់នៅរបស់គាត់កាន់តែល្អប្រសើរ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានបញ្ហាប្រឈម និងតម្រូវការមួយចំនួនដែលទាមទារឱ្យមានការឆ្លើយតបបានត្រឹមត្រូវទាន់ពេលវេលា និងមានប្រសិទ្ធភាពពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋាន ទើបគោលនយោបាយជាយុទ្ធសាស្ត្រទាំងឡាយរបស់រាជរដ្ឋាភិបាលអាចប្រព្រឹត្តទៅបានដោយប្រសិទ្ធភាព។

រដ្ឋបាលខេត្ត ដែលបានប្រសូត្រចេញពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទីភារកិច្ច មុខងារ និងកាតព្វកិច្ចជាច្រើនដែលត្រូវបំពេញឱ្យខានតែបានក្នុងកាតព្វកិច្ចជាចម្បងមុនគេ គឺការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅដើមអាណត្តិនីមួយៗរបស់ខ្លួនឱ្យស្របតាមអនុក្រឹត្យលេខ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យលេខ២១៩ អនក្រ.បក និងប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រកាសលេខ ៣៥១៤ ប្រក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣។

គោលបំណងសំខាន់នៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលគឺសម្រាប់ធ្វើជាមូលដ្ឋានក្នុងការចាត់ចែងអនុវត្តស្របតាមចក្ខុវិស័យរួដែលមានក្របខ័ណ្ឌយុទ្ធសាស្ត្រ គោលបំណង និងគោលដៅរបស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ដែលមានយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពក្នុងបរិបទនៃការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ដើម្បីរួមចំណែកបំពេញកាតព្វកិច្ចដែលច្បាប់បានកំណត់ កម្មវិធីវិនិយោគបានដំណើរការយ៉ាងមមាញឹក ក្រោយពីកិច្ចប្រជុំណែនាំស្តីពីដំណើរការកសាងកម្មវិធីវិនិយោគខេត្ត (២០២០-២០២២) នាថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៨ ។ កិច្ចប្រជុំនេះបានណែនាំដល់មន្ទីរ អង្គភាព ក្រុង ស្រុក មន្ត្រីរាជការ សង្គមស៊ីវិល និងផ្នែកឯកជន អ្នកពាក់ព័ន្ធឱ្យអនុវត្តតាមប្រតិទិនការងារមួយដ៏ជាក់លាក់ ដែលរដ្ឋបាលខេត្តបានឯកភាព។

ទោះបីកម្មវិធីវិនិយោគនេះបានកសាងឡើងក្នុងរយៈពេលខ្លីស្របពេលដែលចំណេះដឹងមន្ត្រីរាជការ និងអ្នកពាក់ព័ន្ធទាំងអស់របស់រដ្ឋបាលខេត្តនៅមានកម្រិត ប៉ុន្តែយើងខ្ញុំសង្ឃឹមថាកម្មវិធីវិនិយោគនេះនឹងក្លាយជាឯកសារដ៏មានសារៈប្រយោជន៍ និងជាត្រីវិស័យសម្រាប់ចង្អុលបង្ហាញផ្លូវឱ្យរដ្ឋបាលខេត្តចាត់តាំងអនុវត្តសកម្មភាពជាអាទិភាពសំខាន់ៗទាំងឡាយសំដៅដោះស្រាយបញ្ហាប្រឈម តម្រូវការ និងសំណូមពរនានារបស់ប្រជាពលរដ្ឋ រួមទាំងការលើកកម្ពស់គុណភាពសេវាកម្មសាធារណៈដែលនឹងបានផ្តល់ដោយរដ្ឋបាលនានាផងដែរ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

កម្មវិធីវិនិយោគបីឆ្នាំរំកិល ខេត្តកំពង់ស្ពឺ ឆ្នាំ២០២០-២០២២ មានបីជំពូកគឺ៖

ជំពូកទី១ ៖ ស្ថានភាពទូទៅ និងបញ្ហាប្រឈមក្នុងខេត្ត

ជំពូកទី២ ៖ គម្រោង សកម្មភាព នៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

ជំពូកទី៣ ៖ ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

កម្មវិធីវិនិយោគបីឆ្នាំរំកិល ឆ្នាំ២០២០-២០២២ របស់ខេត្ត ត្រូវបានពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ នៅក្នុងសម័យប្រជុំសាមញ្ញលើកទី ៥៥ នាថ្ងៃព្រហស្បតិ៍ ១៤រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ២០១៨។


ផែនទី ខេត្តកំពង់ស្ពឺ
Kampong Speu Map
N
W
E
S
ខេត្តពោធិ៍សាត់
ខេត្តកំពង់ឆ្នាំង
ខេត្តកោះកុង
ខេត្តកណ្តាល
ខេត្តព្រះសីហនុ
ខេត្តកំពត
ខេត្តតាកែវ
មាត្រដ្ឋាន 1:140,000
20,000 10,000 0 Meters
Village
Commune office
District_Centers
Provincial_Centers
Hospital
Health center
Pagoda
School
Post Office
Historical Site
Mine
Sealed road
Laterite road
Unsealed road
Track
Street
Permanent river
Seasonal stream
Canal
Major canal
Levee
Provincial boundary
District boundary
Commune boundary
5110, Lake
5120, Reservoir
5210, River
6100, Barren land
6200, Sand bank
UTM
48 N
WGS 1984
WGS 1984
12 - 26
26 - 47
47 - 65
65 - 82
82 - 102
102 - 138
138 - 216
216 - 402
402 - 1,756

# ជំពូកទី ១
## ស្ថានភាពទូទៅ និងបញ្ហាប្រឈមក្នុងខេត្ត

## ១. ស្ថានភាពទូទៅ និងបញ្ហាប្រឈមក្នុងខេត្ត

## ១.១. សេចក្តីសង្ខេបទិន្នន័យចម្បងរបស់ខេត្ត

### តារាងសង្ខេបទិន្នន័យចម្បងរបស់ខេត្ត

| ល.រ | បរិយាយ | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ |
|---|---|---|---|---|---|---|
| **ព័ត៌មានទូទៅ** | | | | | | |
| ១ | ផ្ទៃដីខេត្ត (គ.ម$^{២}$) | ៦,៩៦៩.៦៣ | ៦,៩៦៩.៦៣ | ៦,៩៦៩.៦៣ | ៦,៩៦៩.៦៣ | ៦,៩៦៩.៦៣ |
| ២ | ចំនួនក្រុង ស្រុក | ៨ | ៨ | ៨ | ៨ | ៨ |
| ៣ | ចំនួនឃុំ សង្កាត់ | ៨៧ | ៨៧ | ៨៧ | ៨៧ | ៨៧ |
| ៤ | ចំនួនភូមិ | ១,៣៤៩ | ១,៣៦៨ | ១,៣៧៩ | ១,៣៧៩ | ១,៣៧៩ |
| ៥ | ចំនួនគ្រួសារ | ១៧០,៧៧០ | ១៧៥,៦៦៣ | ១៧៨,២១៨ | ១៨៣,២៤៤ | ១៨៨,៥៨៥ |
| ៦ | % មេគ្រួសារជាស្ត្រី | ១៥.៦១ | ១៥.៤១ | ១៥.៤៤ | ១៥.៥៧ | ១៥.៤៥ |
| ៧ | ចំនួនប្រជាជនសរុប | ៨៣៧,៧៣៥ | ៨៤៨,៥៤០ | ៨៤៨,០៧៦ | ៨៥៧,៣២២ | ៨៧០,០៨១ |
| ៨ | ចំនួនស្រី | ៤២៧,៧១៥ | ៤៣២,៦៥០ | ៤៣១,៩៦២ | ៤៣៧,៩៨២ | ៤៤៦,៤៣១ |
| ៩ | ចំនួនប្រុស | ៤១០,០២០ | ៤១៥,៨៨១ | ៤១៦,១១៤ | ៤១៩,៣៤០ | ៤២៣,៦៥០ |
| ១០ | %អ្នកមានអាយុពី០-១៧ឆ្នាំ | ៣៨.៣៤ | ៣៨.៧៥ | ៣៧.៨២ | ៣៧.៤៨ | ៣៦.៩៥ |
| ១១ | %អ្នកមានអាយុពី១៨-៦០ឆ្នាំ | ៥២.៥៣ | ៥២.០៧ | ៥២.៧៩ | ៥២.៩២ | ៥៣.៤២ |
| ១២ | %អ្នកមានអាយុពី៦១ឆ្នាំឡើង | ៩.១៣ | ៩.១៨ | ៩.៣៩ | ៩.៦០ | ៩.៦៣ |
| ១៣ | កំណើនប្រជាជនប្រចាំឆ្នាំ(%) | ១.២៩ | ១.២១ | -០.០៥ | ១.០៩ | ១.៤៩ |
| ១៤ | អត្រាភាពក្រីក្រ (%) (CDB) | | | | | ២០.០៦ |
| | អត្រាភាពក្រីក្រ (%) (ID Poor) | | | | | |
| ១៥ | % អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម | ៧០ | ៧២.៩ | ៦៦.៤ | ៦២.៦ | ៦០.២ |
| ១៦ | %អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម | ០.៣ | ០.៣ | ០.៣ | ០.៣ | ០.៣ |

| ល.រ | បរិយាយ | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ |
|---|---|---|---|---|---|---|
| ១៧ | %អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម | ២៦.៨ | ២៩.៨ | ៣៣.៣ | ៣៧.២ | ៣៩.៥ |
| ១៨ | %មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស | ៥.៤ | ៥.៦ | ៦.២ | ៥.៥ | ៤.៧ |
| ១៩ | %មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស | ២ | ២ | ២.១ | ១.៩ | ១.៥ |
| ២០ | %ខ្នងផ្ទះមានអគ្គិសនីប្រើប្រាស់ | ៣៩.៨៤ | ៥៦.៨៥ | ៧២.១៧ | ៨១.៦៧ | ៨៨.៣២ |
| **អប់រំ** | | | | | | |
| ២១ | %កុមារអាយុ៣-៥ឆ្នាំបានចូលរៀន | ៣១.៦ | ៣៣.៩ | ៣៥.៨ | ៣៧.២ | ៤០.៧ |
| ២២ | %កុមារអាយុ៦ឆ្នាំបានចូលរៀន | ៨៧.៦ | ៨៨.១ | ៨៨.៤ | ៨៧.២ | ៨៩.៦ |
| ២៣ | %កុមារអាយុ៦-១១ឆ្នាំបានចូលរៀន | ៨៥.៥ | ៨៥.៣ | ៨៥.៩ | ៨៥.០ | ៨៦.៤ |
| ២៤ | %កុមារអាយុ១២-១៤ឆ្នាំបានចូលរៀន | ៨៨.៥ | ៨៨.៨ | ៨៧.៦ | ៨៧.៣ | ៨៨.២ |
| ២៥ | %អ្នកចេះអក្សរអាយុ១៥-១៧ឆ្នាំ | ៩៨.៩ | ៩៩ | ៩៩ | ៩៨.៩ | ៩៩ |
| ២៦ | %អ្នកចេះអក្សរអាយុ១៨-៤៥ឆ្នាំ | ៩៥.៥ | ៩៦.៩ | ៩៧.៨ | ៩៦.២ | ៩៧.១ |
| **សុខភាព** | | | | | | |
| ២៧ | ចំនួនមណ្ឌលសុខភាព | ៥៤ | ៥៤ | ៥៥ | ៥៥ | ៥៤ |
| ២៨ | %ស្ត្រីសម្រាលកូនដោយឆ្មប ពេទ្យ | ៩១.៥ | ៩៤.១ | ៩៣.១ | ៩៧.០ | ៩៧.៥ |
| ២៩ | អត្រាស្លាប់របស់មាតាក្រោយពេលសម្រាល (០-១ខែ) ក្នុង១ពាន់កំណើត | ៣.២ | ៤.៤ | ៧.១ | ៣.៣ | ៣.៦ |

| ល.រ | បរិយាយ | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ |
|---|---|---|---|---|---|---|
| ៣០ | អត្រាស្លាប់របស់កុមារក្រោយពេលកើត(០-១ខែ) ក្នុង១ពាន់កំណើត | ៣.១ | ៣.៧ | ៤.៩ | ១.៩ | ១.៦ |
| ៣១ | % កុមារអាយុពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ៩៤.៨ | ៩៧.៨ | ៩៥ | ៩៦.១ | ៩៣.៦ |
| ៣២ | ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍ | ៨២៩ | ៧៨៤ | ៧៣៧ | ៨០០ | ៧៣០ |
| **ភាពងាយរងគ្រោះ** | | | | | | |
| ៣៣ | ចំនួនជនពិការ | ៦,៨៣៤ | ៧,០៦៦ | ៧,៣១២ | ៧,៦០២ | ៧,១៧២ |
| ៣៤ | %ជនពិការអាយុ១៨ឆ្នាំឡើងមិនអាចរកចំណូលបាន | ២៤.២ | ៣១.២ | ៣៣.១ | ៤១.៩ | ៤២.៨ |
| ៣៥ | ចំនួនកុមារកំព្រាឪពុកម្តាយស្លាប់ដោយជំងឺអេដស៍ | ៦៤១ | ៥២៤ | ៤០៧ | ៣៥១ | ២៥៤ |
| ៣៦ | ចំនួនចាស់ជរាគ្មានទីពឹង (អាយុ៦១ឆ្នាំឡើង) | ១,០៥០ | ១,០៨១ | ១,១៤៧ | ១,១៤៧ | ១,០៤៧ |
| ៣៧ | ចំនួនគ្រួសាររងគ្រោះដោយខ្យល់ព្យុះ/កន្ត្រាក់ | ៤៤ | ១៣០ | ២៦៣ | ៤១ | ៩៤ |
| ៣៨ | ចំនួនគ្រួសាររងគ្រោះដោយទឹកជំនន់ | ៤៤ | ២៣ | ៦៥៣ | ៣៣ | ៧១៣ |
| ៣៩ | ចំនួនគ្រួសាររងគ្រោះដោយរាំងស្ងួត | ៨,៥១៤ | ៦,៨២៣ | ៤,៩៣០ | ៤,៧០៤ | ១,៦៥៤ |
| ៤០ | %គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | ១.១ | ១ | ១.៧ | ១.១ | ១.១ |
| ៤១ | %គ្រួសារមានទឹកស្អាតប្រើប្រាស់ | ៧៣ | ៧៣ | ៧៤.២ | ៧១.១ | ៦៩.៤ |
| ក្នុងនោះ: | %គ្រួសារប្រើទឹកអណ្តូងជីកមិនមានការការពារ | ៤ | ៤.៨ | ២ | ១.៩ | ១.៨ |

| ល.រ | បរិយាយ | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ |
|---|---|---|---|---|---|---|
| ៤២ | %គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ៤០.៤ | ៤៦.៧ | ៥៣ | ៦៤.៨ | ៦៧.៥ |
| ៤៣ | %កុមារបានចុះសំបុត្រកំណើត (០-៣០ថ្ងៃ) | ៧៩.៣ | ៨២.៩ | ៨០.៦ | ៩១.៧ | ៩២ |
| ៤៤ | ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | ១,៥៨៣ | ១,៥១៩ | ១,៦២០ | ១,៥៣១ | ១,៥៣៥ |
| ៤៥ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរ | ២២៣ | ២៣២ | ២៦១ | ២៥០ | ២៤០ |
| ៤៦ | ចំនួនអ្នកស្លាប់ដោយអំពើហិង្សានានា | ១៧ | ៣ | ៨ | ៣ | ៣ |
| ៤៧ | ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន | ៤០៤ | ៧៥៦ | ១,៣៥៣ | ២,៥៣៦ | ២,៧៩៤ |

## ១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមក្នុងខេត្ត

ខេត្តកំពង់ស្ពឺ ជាខេត្តមួយស្ថិតនៅភាគខាងលិចរាជធានីភ្នំពេញប្រមាណជា ៤៨គីឡូម៉ែត្រ ដែលឆ្លងកាត់ដោយផ្លូវជាតិលេខ៤។ យោងតាមលក្ខណៈភូមិសាស្ត្រ ខេត្តកំពង់ស្ពឺចែកចេញជាស្រុក៧ និងក្រុង១ រួមមាន ៨២ឃុំ និង៥សង្កាត់ ដែលមានចំនួន១,៣៧៩ភូមិ ក្នុងនោះភូមិមានក្របខ័ណ្ឌ១,៣៦៨ និងភូមិគ្មានក្របខ័ណ្ឌចំនួន ១១ភូមិ និងមានប្រជាពលរដ្ឋសរុបចំនួន ១៨៨,៥៨៥គ្រួសារ ហើយប្រជាពលរដ្ឋសរុប ៨៥៧,៣២២នាក់ ក្នុងនោះស្រីចំនួន ៤៣៧,៩៨២នាក់។ ដង់ស៊ីតេប្រជាពលរដ្ឋ ១២៣នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ និងមានចំនួនសមាជិកគ្រួសារជាមធ្យម ០៥នាក់។ ប្រជាពលរដ្ឋមានកំណើនមធ្យមចំនួន១.០៩% ក្នុងឆ្នាំ២០១៨។ ខេត្តមានផ្ទៃដីស្រែចំនួន ១១៨,០២៩.៩៣ហិកតា ផ្ទៃដីចម្ការចំនួន ៣,០៨៤.៣០ហិកតា សម្រាប់ប្រកបរបរកសិកម្ម។ ក្រៅពីនេះ មានផ្ទៃដីព្រៃភ្នំ និងដីសំណង់ធារាសាស្ត្រចំនួន ៥២២,៦៧៩ហិកតា អត្រាប្រជាពលរដ្ឋមានមុខរបរកសិកម្មជាចម្បងមានចំនួន ៦២.៦%។

ផ្ទៃដីរបស់ខេត្តប៉ែកខាងលិចគ្របដណ្តប់ដោយជួរភ្នំក្រវាញ ដែលជាហេតុធ្វើឱ្យខេត្តខ្សត់ទឹកភ្លៀង ដោយសារខ្យល់ និងកម្ពស់ជួរភ្នំក្រវាញ ដែលបាននាំទឹកភ្លៀងអស់មួយចំនួនធំធ្លាក់ទៅតំបន់ផ្សេងៗ។ ប៉ុន្តែខេត្តអាចជៀសវាងបានយ៉ាងងាយពីការប៉ះទង្គិចដោយខ្យល់ព្យុះ។ ភាគខាងជើងគ្របដណ្តប់ដោយតំបន់ទំនាបសម្បូរទៅដោយដីមានជីជាតិ ដែលបង្កលក្ខណៈងាយស្រួលដល់ការងារបង្កបង្កើនផលកសិកម្ម ពិសេសដំណាំស្រូវ និងដំណាំចម្រុះផ្សេងៗទៀត។ ម្យ៉ាងទៀត ស្ទឹងព្រែកត្នោតជាស្ទឹងមួយដែលហូរកាត់ខេត្តកំពង់ស្ពឺបាននាំនូវប្រភពទឹកមកស្រោចស្រពដីទំនាបទាំងឡាយ ដែលកត្តាទាំងនេះហើយនាំឱ្យចំនួនប្រជាកសិករមានរហូតដល់ ៦២.៦%ប្រកប

មុខរបរកសិកម្ម។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ផ្ទៃដីខេត្តទាំងមូលទទួលបាននូវកម្រិតទឹកភ្លៀងតិចជាងបណ្តាខេត្តផ្សេងៗទៀត និងដោយសារខ្វះខាតប្រភពទឹកមេ និងប្រព័ន្ធប្រឡាយចែកចាយខ្វាតតូចសម្រាប់ធ្វើការស្រោចស្រព។

ស្រុកសំរោងទង និងក្រុងច្បារមន ស្ថិតនៅក្នុងតំបន់កណ្តាលនៃខេត្ត ហើយប្រជាពលរដ្ឋមួយចំនួនប្រកបរបរលក់ដូរ មួយចំនួនទៀតជាមន្ត្រីរាជការ និងរបរផ្សេងៗទៀត។ ក្រុង ស្រុកទាំងពីរនេះជាទីតាំង មួយដ៏សំខាន់ដែលមានសក្តានុពលខាងវិស័យកាត់ដេរ សហគ្រាសធុនតូច និងមធ្យម សិប្បកម្ម និងអាជីវកម្មធំតូចផ្សេងៗទៀតផងដែរ។ ស្រុកឱរ៉ាល់ ស្រុកថ្ពង និងស្រុកភ្នំស្រួច ផ្ទៃដីមួយភាគធំគ្របដណ្តប់ដោយព្រៃឈើ និងមានភ្នំ រាយប៉ាយ ហើយក៏ជាតំបន់ដែលមានដីជាតិល្អសម្រាប់ការប្រកបរបរកសិកម្ម អាជីវកម្មថ្ម រ៉ែក្រោមដី ការទាញយកអនុផលព្រៃឈើ និងជាតំបន់ដែលមានសក្តានុពលខាងវិស័យកសិ-ឧស្សាហកម្ម (ដូងប្រេង ពោត អំពៅ..) និងកសិដ្ឋានចិញ្ចឹមសត្វធំតូចផងដែរ។ ចំណែកស្រុកគងពិសី ស្រុកឧដុង្គ និងស្រុកបសេដ្ឋ ប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម ការដាំដំណាំរួមផ្សំ និងមុខរបរ បន្ទាប់បន្សំប៉ុណ្ណោះ ព្រោះស្រុកទាំងនេះមានទីតាំងភូមិសាស្ត្រជាតំបន់ទំនាប និងមានជួរភ្នំព័ទ្ធជុំវិញ ហើយក៏ឧស្សាហ៍ជួបគ្រោះរាំងស្ងួត។ ក្រៅពីនេះស្រុកទាំងបីមានលក្ខណៈអំណោយផលលើមុខរបរឡើងត្នោត ពិសេសស្រុកឧដុង្គ មុខរបរនេះទទួលបានការយកចិត្តទុកដាក់ និងលើកទឹកចិត្តតាមរយៈការកែច្នៃ ផលិតផលស្ករត្នោតឱ្យទៅជាម្សៅស្ករមានគុណភាពល្អ ដើម្បីងាយស្រួលទុកដាក់សម្រាប់នាំចេញទៅក្រៅប្រទេស និងទីផ្សារក្នុងស្រុក ដោយមានតម្លៃខ្ពស់សមរម្យអាចជួយបង្កើនកម្រិតជីវភាពកសិករបានមួយចំណែកព្រោះតែរសជាតិដ៏ផ្អែមឈ្ងុយឆ្ងាញ់របស់វា។

### ១.២.១. ស្ថានភាពសេដ្ឋកិច្ច (ទិន្នន័យចាស់)

ដើម្បីជំរុញក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រទាំងឡាយរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធដល់ការលើកកម្ពស់គុណភាពប្រសិទ្ធភាពក្នុងផ្នែកសេដ្ឋកិច្ច ពិសេសការជំរុញការបង្កើនផលិតកម្មស្រូវ និងការនាំចេញ អង្ករ ស្វាយ ស្ករអំពៅ ស្ករត្នោត ទៅកាន់ទីផ្សារបរទេសរបស់រាជរដ្ឋាភិបាល។ រដ្ឋបាលខេត្តបានចាត់តាំងអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលដោយការទទួលខុសត្រូវខ្ពស់ ដើម្បីរួមចំណែកធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានប្រសើរឡើង បើទោះបីខេត្តកំពុងជួបប្រទះបញ្ហាខ្លះៗនៅក្នុងស្ថានភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ដែលទាមទារឱ្យមានការដោះស្រាយជាបន្តបន្ទាប់យ៉ាងណាក្តី។ ស្ថានភាពជាក់ស្តែងនៃវិស័យនានានៅក្នុងផ្នែកសេដ្ឋកិច្ចមានដូចខាងក្រោម៖

#### ១.២.១.១ វិស័យអាជីវកម្ម

#### ១. ការខារពាណិជ្ជកម្ម

វិស័យពាណិជ្ជកម្មក្នុងខេត្ត កាន់តែមានការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ ដោយផ្អែកលើគោនយោបាយរបស់រាជរដ្ឋាភិបាល និងមានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ ជាក់ស្តែងខេត្តមានផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ៤៤ ផ្លូវជាតិលេខ៥១ និងផ្លូវជាតិលេខ៤១ ដែលជាផ្លូវសេដ្ឋកិច្ចសម្រាប់ការដឹកជញ្ជូនផលិតផលទំនិញ បានយ៉ាងងាយស្រួល។ ទន្ទឹមនឹងនេះដើម្បីចូលរួមចំណែកក្នុងការពង្រឹងវិស័យឯកជន និងជំរុញឲ្យមានកំណើនសេដ្ឋ

កិច្ចក្នុងតំបន់ មន្ទីរពាណិជ្ជកម្មខេត្ត បានធ្វើការគ្រប់គ្រងស្ថានភាពទូទៅធ្វើពាណិជ្ជកម្ម និងការក្តាប់បាននូវការប្រកួតប្រជែងលើទីផ្សារ។ ការជំរុញឲ្យមានការផលិតដើម្បីបំពេញតម្រូវការទីផ្សារ និងការនាំចេញនៅនឹងកន្លែងតាមរយៈពិព័ណ៌ពាណិជ្ជកម្ម សំដៅលើកកម្ពស់ការប្រកួតប្រជែងរបស់កសិករ ផលិតករ សិប្បករ សេវាករ និងអ្នកនាំចេញ។ ដើម្បីធានានូវសុវត្ថិភាពនៃយន្តការនេះ មន្ទីរបានរៀបចំផែនការក្នុងការផ្សព្វផ្សាយដល់មូលដ្ឋាន ក្នុងគោលដៅស្វែងយល់អំពីច្បាប់ពាណិជ្ជកម្ម និងការបង្កើនផលិតភាពទំនិញ ការបង្កើតផលិតផលថ្មីៗ និងតម្លៃបន្ថែមនៃផលិតផល និងជាពិសេសការបង្កើតឲ្យមានសមាគមអាជីវកម្មទៅដល់មូលដ្ឋាន ដើម្បីពង្រឹង និងពង្រីកទីផ្សារឲ្យបានទូលាយសំដៅការការពារបរិមាណ គុណភាព និងតម្លៃផលិតផលដែលសម្រេចបានជូនដល់ប្រជាកសិករ ។

**បញ្ហាប្រឈម រួមមាន៖**

- ការយល់ដឹងពីច្បាប់ក្នុងការធ្វើពាណិជ្ជកម្មនៅមានកម្រិត
- ការសហការរវាងក្រុមហ៊ុន សហគ្រាស និងអាជ្ញាធរមូលដ្ឋានជាមួយមន្ទីរជំនាញដែលពាក់ព័ន្ធនៅមានកម្រិត
- ក្រុមហ៊ុន សហគ្រាសមួយចំនួនពុំសូវយកចិត្តទុកដាក់ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ឲ្យបានត្រឹមត្រូវតាមគោលការណ៍ និងខ្លះទៀតមិនទាន់បានលើកស្លាកយីហោរបស់ខ្លួនឡើយ ។

## ២. ការងារវិស័យឯកជន (ទិន្នន័យចាស់)

ការវិនិយោគវិស័យឯកជនក្នុងខេត្ត សព្វថ្ងៃមានក្រុមហ៊ុនឯកជនធ្វើការវិនិយោគវិស័យកសិ-ឧស្សាហកម្ម ចំនួន២០ក្រុមហ៊ុនក្នុងនោះ កំពុងដំណើរការអនុវត្តទៅលើផ្ទៃដីដាំដុះចំនួន៨៧.៣៧,៩៦៩ហិកតាដែលបាននិងកំពុងគ្រប់ គ្រង និងធ្វើការដាំដុះលើផ្ទៃដីចំនួន ៤៦.៩៤៧,៧០ហិកតា ដែលត្រូវបានអនុញ្ញាត ឲ្យធ្វើការវិនិយោគក្នុងខេត្ត ហើយផ្តល់ការងារជូនប្រជាពលរដ្ឋក្នុងស្រុកប្រមាណជាង ៥.៧៣២នាក់ក្នុងមួយថ្ងៃ។ គិតមកដល់ពេលនេះ យើងមានរោងចក្រ សហគ្រាស និងគ្រឹះស្ថាន សរុបចំនួន២៥៣កន្លែង មានកំលាំងពលកម្មសរុប ១១៧.៧០៧នាក់ ស្រីចំនួន៩៧.២៣២នាក់។ ការវិនិយោគខាងឧស្សាហកម្ម និងកម្មន្តសាល ក្នុងខេត្តមានរោងចក្រធុនធំមានចំនួនសរុប ១៤៧រោងចក្រ ដែលប្រើប្រាស់កំលាំងពលកម្ម ចំនួន **៩៧.២១៩នាក់** ស្ត្រីចំនួន **៩៥.៥៧៤នាក់**។ សហគ្រាសធុនតូច មធ្យម និងសិប្បកម្មសរុបចំនួន **៦.១៦៤** មូលដ្ឋាន ប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន **១៧.១៥៧** ស្រី **៥.៧៥៤** និងបានផ្តល់ចំណូលជាអចិន្ត្រៃយ៍ជូនប្រជាពលរដ្ឋក្នុងរង្វង់ **២៣.៥លានដុល្លារ** ក្នុង១ខែ គិតជាមធ្យមប្រមាណ **២៨២លាន**ដុល្លារក្នុង១ឆ្នាំ។ មានក្រុមហ៊ុន សហគ្រាសដែលបានចុះបញ្ជី

សរុបចំនួន ៤៧៦ ក្រុមហ៊ុនសហគ្រាស ក្នុងនោះ ក្រុមហ៊ុន១៥៤ សាខាក្រុមហ៊ុន១២៦ សហគ្រាសផ្សេងៗ ១៤៣ និងសហគ្រាសម៉ាស៊ីនកិនស្រូវ ៥៣។

**បញ្ហាប្រឈម រួមមាន៖**

- វិស័យឯកជនមួយចំនួន ពុំសូវយកចិត្តទុកដាក់ក្នុងការបង់ពន្ធជូនរដ្ឋ និងរៀបចំលិខិតបទដ្ឋាន ឲ្យបានត្រឹមត្រូវ
- វិស័យខ្លះមានលក្ខណៈស្មុកស្មាញពិបាកគ្រប់គ្រង ហើយពុំសូវស្តាប់ការណែនាំ
- ក្រុមហ៊ុនមួយចំនួន ពុំសូវយកចិត្តក្នុងការចុះបញ្ជីពាណិជ្ជកម្ម និងលើកស្លាកយីហោរបស់ខ្លួន ឲ្យបានត្រឹមត្រូវតាមគោលការណ៍ឡើយ ។

## ៣. ការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ( ទិន្នន័យចាស់ )

វិស័យប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវបានចាត់ទុកជាគម្រោងផែនការ និងសកម្មភាពការងារសំដៅជុំរុញការរៀបចំប្រព័ន្ធប្រៃសណីយ៍និងទូរគមនាគមន៍ មួយស្របតាមការីកចំម្រើនបណ្តាញប្រទេសក្នុងតំបន់ និងអន្តរជាតិឲ្យបានប្រសិទ្ធសេដ្ឋកិច្ចខ្ពស់ សេវាកម្មទំនើបនិងគ្របដណ្តប់ទូទាំងខេត្ត ដោយមានប្រព័ន្ធត្រួតពិនិត្យគុណភាពសំដៅចូលរួមជុំរុញកណើនសេដ្ឋកិច្ច និងលើកកំពស់ជីវភាពប្រជាពលរដ្ឋ ។ ការធ្វើការពង្រីកសេវាកម្មប្រៃសណីយ៍ និងទូរគមនាគមន៍ នៅតាមតំបន់ ជនបទបង្កលក្ខណៈ ឲ្យប្រជាពលរដ្ឋងាយបានព័តិមាន និងបញ្ជូនព័តិមានក្នុងការទំនាក់ទំនងឱ្យបានឆាប់រហ័សនិងបង្កើន សហប្រតិបត្តិការទាកទាញ និងលើកទឹកចិត្តអ្នកវិនិយោគឯកជន ។

### ក. វិស័យប្រៃសណីយ៍ ( ទិន្នន័យចាស់ )

សេវាកម្ម និងអាជិកម្មប្រៃសណីយ៍ មានការរិកចម្រើនគួរឲ្យកត់សំម្គាល់ ដោយបង្កើនឥតឈប់ឈរនូវទំនុកទុកចិត្ត និងការជឿជជាក់ពីសំណាក់អតិថិជនជនជាតិ និងអន្តរជាតិ ជាពិសេសធ្វើកាប្រកួតប្រជែងជាមួយ បណ្តាញក្រុមហ៊ុនឯកជនដែលរកស៊ីប្រហាក់ប្រហែល ។ បម្រើសេវាបញ្ញូ និងទទួលបញ្ញើនៅកន្នុងប្រទេសក្នុង១សប្តាហ៍មាន ០៧ ជើង ចំពោះបញ្ញើ ទៅតាមបណ្តាស្រុកទាំង៨ក្នុងខេត្តអនុវត្តជារៀងរាល់ថ្ងៃ។ ចំពោះបញ្ញើតាមផ្លូវរាបពីភ្នំពេញមកពីមន្ទីប្រៃណីយ៍និងរគមនាគមន៍ខេត្ត១សប្តាហ៍បញ្ជូននិងទទួលបាន៧ជើង មានបញ្ញើក្នុងនិងក្រៅប្រទេស ។ ដោយឡែកបញ្ញើឆាប់រហ័ស EMS បញ្ជូនទទួលពីខេត្តទៅតាមបណ្តាប្រទេសជាង៩០លើពិភពលោក តាមរយះក្រសួងប្រៃសណីយ៍មាន៧ជើង ក្នុងមួយសប្តាហ៍ចំពោះ (បញ្ជូននិងទទួលបញ្ញើទាំង ២ប្រភេទគឺមានរយះពេលតែមួយ)។ ក្នុងឆ្នាំ២០១៨ការបញ្ជូន និងទទួលបញ្ញើក្នុងប្រទេសសម្រេចបាន ១៣៧២ ច្បាប់កញ្ចប់ផ្សេងៗសរុប៤៥៩កញ្ចប់ បញ្ជូននិងទទួលបញ្ញើក្រៅ ប្រទេសសម្រេចបាន២៥៤៨ ច្បាប់ក្នុងនោះកញ្ចប់ផ្សេងៗសរុប១១១៧ កញ្ចប់។(គិតត្រឹមថ្ងៃទី១២ខែធ្នូឆ្នាំ២០១៨)

### ខ . វិស័យទូគមនាគមន៍ ( ទិន្នន័យចាស់ )

សេវាកម្ម អាជីវកម្មវិស័យទូកមនាគមន៍ មានការីកចម្រើនគួរឲ្យកត់សំម្គាល ព្រោះការរីកចម្រើនវិស័យបានបង្កើនឡើងឥតឈប់ឈរនូវទំនុកចិត្ត និងការជឿជាក់ពីសំណាកអតិថិជន ជនជាតិ និងអន្តរជាតិ ជាពិសេសធ្វើការប្រកួតប្រជែងរបស់បណ្តាក្រុមហ៊ុនរដ្ឋ និងឯកជនដែលមានការកស៊ីប្រហាក់ប្រហែលគ្នា ។ សិត្ថិដែលមន្ទីរទទួលបានពីរការស្រង់ទិន្និន័យលើវិស័យទូរគមនាគមន៍ និងព័តិមានវិទ្យាទូទាំងខេត្ត មានក្រុមហ៊ុនទូរស័ព្ទអចល័តចំនួន៣ក្រុមហ៊ុនមានចំនួន ៤០៣ គ្រឿង ក្រុមហ៊ុនទូស័ព្ទចល័តចំនួន៨ក្រុមហ៊ុន បណ្តាញក្រុមហ៊ុនខ្សែកាប្លិ៍អុកទិចចំនួន៧ក្រុមហ៊ុន ក្រុមហ៊ុនបម្រើប្រព័ន្ធអ៊ីនធឺណែតចំនួន៥ក្រុមហ៊ុន មានទីតាំងនៅស្ថានីយ៍ទូស័ព្ទ ក្រុមហ៊ុននានាទូទាំងខេត្តចំនួន៣៨៤បង្គោលដែលបានបំពាក់ម៉ៃក្រូវ៉េវ ។

**បញ្ហាប្រឈមនិងអាទិភាពសំខាន់ៗះ**

- ការផ្សព្វផ្សាយច្បាប់ស្តីពីប្រៃសណីយ៍និងច្បាប់ទូរគមានគមន៍នៅមិនទាន់បានទូលំទូលាយឡើយ
- ខ្វះការយល់ដឹងនិងការចូលរួមរបស់ប្រតិបត្តិក-ប្រជាជនក្នុងការអនុវត្តច្បាប់ស្តីពីប្រៃសណីយ៍ និងច្បាប់ ទូរគមនាគមន៍ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនិងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍
- ប្រតិបត្តិករទូរគមនាគមន៍មួយចំនួនមិនបានគោរពតាមគោលការណ៍បទដ្ឋានបច្ចេកទេស2 និងការណែនាំរបស់ក្រសួងក៏ដូចជាអាជ្ញាធរដែនដី មន្ទីរជំនាញមុន និងតំឡើងបង្គោលអង់តែន ឬស្ថានីយ៍ថ្មី។
- បណ្តាប្រតិបត្តិករក្រុមហ៊ុនទូរស័ព្ទមួយចំនួននៅតែបន្តការលក់និងចែកចាយស៊ីមទូរស័ព្ទរបស់ខ្លួន ទៅដល់ភ្នាក់ងារលក់ និងអ្នកប្រើប្រាស់ ដោយមិនមានឯកសារបញ្ជាក់គ្រប់គ្រាន់
- វិទ្យុផ្សាយសម្លេងដែលបោះទីតាំងក្នុងខេត្តមិនបានស្នើសុំការអនុញ្ញាតិនិងជូនដំណឹងមកមន្ទីរ
- ខ្វះធនធានមនុស្សសម្រាប់បំរើការងារតាមបណ្តាការិយាល័យជំនាញនៅមន្ទីរនិងនៅតាស្រុក
- សមត្ថភាពជំនាញបច្ចេកទេសរបស់មន្ត្រីក្នុងអង្គភាពនៅមានកំរិតទាប
- ទីកន្លែងបំពេញការងារសព្វថ្ងៃមានលក្ខណៈតូចចង្អៀត(មានមន្ទី សាខាប្រៃសណីយ៍ សាខាទូរគមានគមន៍កម្ពុជា)
- ការអនុវត្តន៍ លិខិតបទដ្ឋាននិងលិខិតគតិយុទ្ធនានាគឺបានអនុវត្តន៍នៅមានភាពធូរលុង នៅតាមបណ្តាការិយាល័ជំនាញដែលជាហេតុនាំឲ្យការងារអនុវត្តន៍មិនទទួលបានប្រសិទ្ធភាព។
- ការរៀបចំធ្វើគម្រោងផែនការសកម្មភាព និងផែនការផ្សេងៗ មិនទាន់សុក្រិតច្បាស់លាស់ និងស៊ីជម្រៅ ។
- មន្ត្រីដែលអនុវត្តកាងារជំនាញមួយចំនួន មិនសូវយល់ច្បាស់ពីការងារបច្ចេកទេសថ្មីៗ ។
- គ្រប់គ្រងមិនទាន់បានពិតប្រាកដនូវទិន្នន័យចំនួនបង្គោលអង់តែនទូរសព្ទ័ និងចំនួនម៉ៃក្រូវ៉េវទូទាំងខេត្តកំពង់ស្ពឺ ។

### គ. ការិយាល័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ( ទិន្នន័យចាស់ )

- បានបញ្ជូនរបាយការណ៍ឆ្នាំ២០១៨ជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍តាមរយៈ Email Intneat
- បន្តផ្សព្វផ្សាយពីសកម្មភាពរបស់មន្ទីរតាមបណ្តាញព័តមានសង្គមថ្មីៗ ។
- បានចងបដាផ្សព្វផ្សាយរបស់វិទ្យាស្ថានជាតិនៅខាងមុខមន្ទីរអប់រំយុវជន និង កីឡាមួយទៀតនៅមុខវិទ្យាល័យខេត្តកំពង់ស្ពឺ និងបាន ចែកជូនសិស្សានុ សិស្សស្ដីពីការជ្រើសរើសប្រឡងចូលរៀននៅវិទ្យាស្ថានជាតិក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

## ១.គោលបំណងអភិវឌ្ឍន៍វិស័យប្រៃសណីយ៍និងទូរគមនាគមន៍ (ទិន្នន័យចាស់)

សេវាប្រសសនិយ៍ និងទូរគមនាគមន៍ ហាក់ដូចជាមានការខ្វះខាត់ច្រើននៅឡើយ ពីព្រោះប្រជាពលរដ្ឋភាគច្រើនពុំទាន់យល់ដឹង ពីប្រភេទសេវាកម្ម និងផល់ប្រយោជន៍របស់វានៅឡើយទេ។ កង្វះខាតធនធានមនុស្ស និងសម្ភារះ និងឧបករណ៍ប្រើប្រាស់ទំនើបៗលើការបំរើសេវាកម្មទាំងពីរ មិនទាន់មានរីកចម្រើនទៅដល់ទីជនបទនៅឡើយទ។ ការកង្វះខាត់ទីតាំងបំម្រើការ និងការផ្សព្វផ្សាយការប្រើប្រាស់សេវានិង ច្បាស់គ្រប់គ្រងលើវិស័យនេះ នៅមានភាពធូររលុង។

ដើម្បីបំពេញកង្វះខាតខាងលើនេះ និងដើម្បីចូលរួមអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តបានដាក់ចេញនូវគោលបំណងរបស់ខ្លួនក្នុងរួមចំណែកអភិវឌ្ឍន៍ខេត្តមានដូចខាងក្រោម ៖

១-លើកកម្ពស់សម្ថតភាពធនធានមនុស្សដែលមានស្រាប់ដើម្បីធានាឲ្យបានលើការអនុវត្តជំនាញ

២-ធានាបាននៅការបម្រើសេវាប្រៃសណីយ៍ជូនប្រជាពលរដ្ឋនៅតាមជនបទឲ្យបានទូលំទូលាយ

៣-ពង្រីកសេវាទូរគមនាគមន៍របស់រដ្ឋ និងឯកជនឲ្យទៅដល់ជនបទ ដើម្បីប្រជាជនមានសេវាប្រើប្រាស់គ្រប់គ្រាន់ ។

## ២. គោលដៅអភិវឌ្ឍន៍ប្រៃសណីយ៍ និងទូរគមនាគមន៍ (ទិន្នន័យចាស់)

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការជំរុញឲ្យប្រជាពលរដ្ឋមានសេវាប្រៃសណីយ៍ និងទូរគមនាគមន៍តាមបណ្តាស្រុកទូទាំងខេត្ត ខេត្តបានកំណត់ នូវគោលដៅ សម្រាប់ធ្វើការអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍របស់ខ្លួនដូចខាងក្រោមៈ

- ពង្រីកការតភ្ជាប់ប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍ និង សេវាប្រៃសណីយ៍ទៅតាមបណ្តាស្រុកទូទាំងខេត្តបាន៧០% បន្ថែមទៀតនៅឆ្នាំ២០១៩ ។
- ស្តាហេដ្ឋារចនាសម្ព័ន្ធនានាឲ្យទៅដល់បណ្តាស្រុក និងឃុំ-សង្កាត់ទាំង៨៧ឲ្យបាន១០%នៅឆ្នាំ២០១៩ ។

## ៣. យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ (ទិន្នន័យចាស់)

ដើម្បីសម្រេចបាននូវគោលដៅប្រកបដោយជោគជ័យមន្ទីបានជ្រើសរើសយកនូវយុទ្ធសាស្ត្រមួយចំនួនដើម្បីសម្រេចនិងស្ថេរភាពក្នុងការអភិវឌ្ឍន៍យូរអង្វែងរួមមានៈ

- ទំនាក់ទំនងល្អជាមួយអង្គកាជាតិ អន្តរជាតិ និងអង្គកាក្រៅរដ្ឋាភិបាលក្រុមហ៊ុឲ្យបានជិតស្និទ្ធក្នុងការធ្វើគរោងផែនការអភិវឌ្ឍន៍ វិស័យប.ទ។

- ទំនាក់ទំនង និងបង្កលក្ខណៈងាយស្រួលជាមួយក្រុមហ៊ុនឯកជន ដែលមានបំណងចង់វិនិយោគលើវិស័យ ប.ទ នៅក្នុងខេត្ត។
- លើកគំរោងស្នើរសុំថវិកាពីរាជរដ្ឋាភិបាលនិងបណ្តាអង្គការនានា ឲ្យគាំទ្រលើផែនការអភិវឌ្ឍន៍លើវិស័យប.ទ
- បង្កើនចំណេះដឹងជំនាញបន្ថែមដល់មន្ត្រីរាជការ ក្នុងមន្ទីនៅក្រសួងនិងគ្រឹះស្ថាននានា
- សហការធ្វើការសិក្សាគម្រោងជាមួយមន្ត្រីបចេក្ខកទេសក្រសួង និងម្ចាស់ជំនួយដើម្បីលើកគម្រោង និងអភិវឌ្ឍន៍មជ្ឈមណ្ឌលប្រព័ន្ធទូគមនាគមន៍ និងបណ្តាញខ្សែកាប្លិ៍អុបទិច ក្នុងទីរួមខេត្ត
- សហការជាមួយកងកំលាំងប្រដាប់អាវុធ និងអាជ្ញាធរ គ្រប់លំដាប់ថ្នាក់ ដើម្បីធ្វើការត្រួតពិនិត្យលើការប្រើប្រាស់វិទ្យុទាក់ទងខុសច្បាប់។
- សហការជាមួយក្រសួង មន្ទីរជំនាញ អាជ្ញាធរខេត្ត-ស្រុក ដើម្បីធ្វើគម្រោងសាងសង់អាគារការិយាល័យប .ទតាមបណ្តាស្រុកនិងបើកឲ្យតំណើរការនូវសេវាកម្មអាជីវកម្មប.ទ។

### ១.២.១.២ វិស័យកសិកម្ម

### ១. ការងារកសិកម្ម

កសិកម្មជាវិស័យអាទិភាពរបស់ខេត្តប្រជាពលរដ្ឋ ៧២.៩% ជាកសិករនិងបានប្រកបរបរកសិកម្ម ជាចំបងនៅ លើតំបន់វាលទំនាបផ្នែកខាងកើតនិងកណ្តាលខេត្ត ។វិស័យកសិកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការ ធានាសន្តិសុខស្បៀងជូនដល់ប្រជាពលរដ្ឋទូទាំងខេត្តនិងរួមចំណែកក្នុងការនាំចេញអង្ករបស់រាជរដ្ឋាភិបាលស្បៀង ) ៨២,សល់គឺតជាអង្ករ២២៨តោនឆ្នាំ២០១៨និងជាខេត្តដែលកំពុងមានលទ្ធភាពចិញ្ចឹមសត្វមានការរីកចំរើនគួរឲ្យ( ២២៥,កត់សំគាល់រួមមានជ្រូក៥៦២ក្បាល៣០៦,គោ-៣១៨ក្បាលនិងមាន់២ក្ប៥០៧,៧១៨,បាល ដើម្បីធានាបានការផ្គត់ផ្គង់ជីវភាពបង្កើនប្រាក់ចំណូលគ្រួសារ និងសេដ្ឋកិច្ចជាតិ សង្គមផងដែរ។

### ក.ការបង្កបង្កើនផលស្រូវប្រាំង និងវស្សា (ទិន្នន័យចាស់)

ផ្ទៃដីផលិតស្រូវសរុបប្រចាំឆ្នាំ (រដូវវស្សានិងប្រាំង) មានការកើនឡើងជាលំដាប់ក្នុងរយៈពេល៣ឆ្នាំ ចុងក្រោយនៅឆ្នាំ២០១៥ ចំនួន ១១៣,៩០៥ ហ.ត ទិន្នផល៣.០១០តោន/ហ.ត បរិមាណផលសរុបចំនួន ៣៣៩,២៤៨តោន និងឆ្នាំ២០១៧អនុវត្តបានចំនួន ១១៤,១៥០ ហ.តទិន្នផល៣.០៣៦តោន/ហ.ត បរិមាណ ផលសរុប៣៤៦,៨៩៣តោ ។ ផ្ទៃដីស្រូវវស្សាមានចំនួន ១១៣,៦០០ ហ.ត ដែលលាតសន្ធឹងគ្រប់ដណ្តប់ ផ្នែកកណ្តាល និងខាងកើតនៃខេត្តលើកលែងតែស្រុកឱរ៉ាល់និងមួយចំណែកនៃស្រុកភ្នំស្រួច ជាដីសម្បទានសេដ្ឋកិច្ចវិនិយោគដំណាំកសិឧស្សាហកម្ម ។ ការងារបង្កបង្កើនផលស្រូវវស្សា តែងតែជួបគ្រោះរាំងស្ងួត ជារៀងរាល់ឆ្នាំ ធ្វើឲ្យការងារ បង្កបង្កើនផលមានការយឺតយ៉ាវមានឆ្នាំខ្លះអនុវត្តមិនគ្រប់ផែនការ។ នៅឆ្នាំ២០១៥ អនុវត្តបានចំនួន១០៧,៦៤៧ ហ.ត ស្មើនឹង៩៤.៨៦% និងឆ្នាំ២០១៧ អនុវត្តបានចំនួន១១៣,៧១១គឺស្មើនឹង១០០.១០%។ ទិន្នផលស្រូវប្រចាំឆ្នាំមានការកើនឡើងចាប់ពីឆ្នាំ២០១៥ មាន ៣,០១០ តោនក្នុងមួយហិកតា និង ឆ្នាំ២០១៧ មានចំនួន ៣.០៣៦តោនក្នុងមួយហិកតា។ខេត្តកំពង់ស្ពឺជាខេត្តដែល ធានាបាននូវការផ្គត់ផ្គង់ស្បៀង និងរួមចំណែកនាំចេញស្រូវអង្ករទៅកាន់ខេត្តផ្សេងៗ និងក្រៅប្រទេស ដោយសារខេត្តមានស្បៀងសល់ជាអង្ករចំនួន ៧៧,៥២៨ តោន នៅឆ្នាំ២០១៥ និងចំនួន ៧៩,៨៦៦ តោន ឆ្នាំ២០១៧។

## ខ.ការចិញ្ចឹមសត្វ និងដំណាំរួមផ្សំ ដំណាំកសិឧស្សាហកម្ម (ទិន្នន័យចាស់)

ការចិញ្ចឹមសត្វ ជាកត្តាដ៏សំខាន់របស់ការងារកសិកម្ម ពិសេស ដើម្បីផ្គត់ផ្គង់ជាម្ហូបអាហារលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋក្នុងខេត្តនិងរួមចំណែកក្នុការកនាំសត្វនិងផលិតផលសត្វចេញទៅក្រៅខេត្ត ដោយផ្អែកលើសក្តានុពល លើការចិញ្ចឹមសត្វដូចជាហេដ្ឋារចនាសម្ព័ន្ធល្អ ដីមិនលិចទឹកនៅរដូវវស្សា ធ្វើឲ្យការវិនិយោគលើការចិញ្ចឹមសត្វមានការកើនឡើង។ ជាក់ស្តែងនៅឆ្នាំ២០១៥ គោមានចំនួន៣៣០,៣៣៥ក្បាល ជ្រូកចំនួន១៨៦,៦៥៥ក្បាល បក្សីចំនួន២,០៣៥,៩៦៧ក្បាល និងឆ្នាំ២០១៧គោមានចំនួន ៣៣០,៥៥៦ក្បាល ជ្រូកចំនួន១៨៨,៦២៤ក្បាល បក្សីចំនួន២,១២៤,៧១៦ក្បាល។ ការចិញ្ចឹមសត្វមានការកើនឡើងឬថយចុះអាស្រ័យលើការប្រែប្រួលនៃតំលៃចំណីសត្វនិងការនាំចូលសត្វពីខាងក្រៅ។ ប៉ុន្តែទោះជាយ៉ាងណាក៏មានការចិញ្ចឹមសត្វមានការកើនឡើងប្រហែល ៣%ក្នុងមួយឆ្នាំ ។

ដំណាំរួមផ្សំមាន ពោត សណ្តែក ដំឡូងដី អំពៅ ត្រាវ បន្លែ ។ល។ ត្រូវបានដាំដុះរាយប៉ាយទូទាំងខេត្ត ជាពិសេសនៅតាមដំបន់មានប្រភពទឹកទាំងរដូវប្រាំងនិងរដូវវស្សា ដូចជានៅតាមដងស្ទឹងព្រែកត្នោត មានស្រុកសំរោងទង និងក្រុងច្បារមន ។ មានដាំដុះដំណាំបន្លែនៅក្នុងស្រែ ក្រោយពេលប្រមូលផលស្រូវវស្សាដូចជានៅស្រុកគងពិសី ស្រុកបសេដ្ឋ និងស្រុកឧដុង្គ ជាដើម ផលិតផលបន្លែមួយចំនួនត្រូវបានលក់ទៅកាន់ទីផ្សាររាជធានីភ្នំពេញនិងខេត្តព្រះសីហនុ ។ ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន ១,៧១៩ ហ.ត នៅឆ្នាំ២០១៥ និងនៅ ឆ្នាំ ២០១៧ចំនួន២,១៧៥ ហ.ត ។ ដំណាំកសិ-ឧស្សាហកម្មឆ្នាំ ២០១៧ មានអំពៅ ពោត ដំឡូងដី កៅស៊ូ ឈើមៃសាក់។ល។ ដែលត្រូវ បានដាំដុះដោយការវិនិយោគរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចំនួន២០ក្រុមហ៊ុន ដាំដុះសម្រេចបានចំនួន ៤៩,០៤៦ ហិកតានិងស្រូបយកកម្លាំងពលកម្មសរុបចំនួន៤,៣៨០នាក់ ។

## គ.វិស័យព្រៃឈើ (រដ្ឋបាលព្រៃឈើ) (ទិន្នន័យចាស់)

ប្រទេសកម្ពុជា ជាប្រទេសមួយស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍នៃតំបន់ត្រូពិចដែលសម្បូរណ៍ទៅដោយធនធានធម្មជាតិ ជាពិសេសព្រៃឈើដែលគ្របដណ្តប់លើផ្ទៃដីប្រមាណ៧៣% នៃផ្ទៃប្រទេសមុនឆ្នាំ១៩៧០(គម្របធនធានព្រៃឈើកម្ពុជា ២០០៤)។

នៅក្នុងឆ្នាំ២០០៦ គម្របព្រៃឈើកម្ពុជាបានថយចុះមកនៅប្រមាណ ៥៩%នៃផ្ទៃប្រទេស(កម្មវិធីព្រៃឈើជាតិ) ការថយចុះ នេះបណ្តាលមកពីការរុករានកាន់កាប់ដីព្រៃឈើ ការបំលែងដីព្រៃឈើទៅជាដីកសិកម្ម តាមរយៈ សម្បទានដីសេដ្ឋកិច្ច ការផ្សព្វផ្សាយ និងការពង្រឹងការអនុវត្តច្បាប់នៅមានកំរិត ការគាំទ្រសហគមន៍ព្រៃឈើនៅមានកំរិត ការកំណត់ព្រំប្រទល់ និងការចុះបញ្ជិកាដីព្រៃឈើយឺតយ៉ាវ ការកើនឡើងនូវតម្រូវការប្រើប្រាស់ផលិតផលព្រៃឈើនិងដីព្រៃឈើរួមផ្សំនឹងភាពក្រីក្ររបស់ប្រជាជនផងនោះ បានជំរុញឲ្យប្រជាជនកាប់រុករានទន្ទ្រានជាបន្តបន្ទាប់ទៅលើធនធាន និងដីព្រៃឈើ ដើម្បីដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃ។ដូច្នេះការបំលែងដីព្រៃឈើទៅជាដីកសិកម្ម និងដីលំនៅដ្ឋានសម្រាប់រស់នៅ ឬលក់បន្ត ការប្រមូល និងការលក់ផល អនុផលព្រៃឈើផ្សេងៗទៀតដែលជាហេតុបណ្តាលឲ្យធនធានព្រៃឈើថយចុះផងដែរ ។ ការថយចុះធនធាន និងដីព្រៃឈើធ្វើឲ្យខូចខាតប្រព័ន្ធអេកូឡូស៊ីព្រៃឈើ បានជះឥទ្ធិពលជាច្រើនទៅលើសង្គមនិងសេដ្ឋកិច្ចរបស់សហគមន៍មូលដ្ឋានដូចជាការធ្វើកសិកម្ម ការនេសាទ ការចិញ្ចឹមសត្វ ។ល។

ហេតុដូច្នេះ ដើម្បីកាត់បន្ថយនូវបញ្ហាប្រឈមខាងលើ យើងចាំបាច់ត្រូវធ្វើការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធវិស័យព្រៃឈើឲ្យបានទូលំទូលាយ ធ្វើការដាំដុះដើមឈើឡើងវិញ តាមក្រុមហ៊ុនវិនិយោគ មួយចំនួន និងនៅទីសាធារណៈ ជំរុញឲ្យមានការបង្កើតសហគមន៍ព្រៃឈើបន្ថែមនៅតំបន់ដែលមានសក្តានុពល និងធ្វើការបណ្តុះបណ្តាលជំនាញបន្ថែមដល់សហគមន៍មូលដ្ឋាន ដើម្បីបង្កើនមុខរបរ និងជីវភាពរស់នៅ ។

## ឃ.វិស័យរដ្ឋជលផល និងវារីវប្បកម្ម (និន្នន័យចាស់)

យោងតាមភាពជាក់ស្តែង ខេត្តកំពង់ស្ពឺគ្មានទន្លេ ឬ សមុទ្រឡើយ ហើយវិស័យជលផលក៏គ្រាន់តែសម្រាប់ជួយផ្គត់ផ្គង់ម្ហូបអាហារក្នុងគ្រួសារ។ ខេត្តកំពង់ស្ពឺមានស្រះចិញ្ចឹមត្រីជាលក្ខណៈគ្រួសារកើនឡើងពី ២,០៧៥ គ្រួសារ រហូតដល់ ៦,០០០គ្រួសារ សហគមន៍ស្រះជម្រកត្រី១៧៣កន្លែង ពង្រឹងសហគមន៍ស្រះជម្រកត្រីចំនួន ១៥កន្លែង អាងផលិតកូនត្រីពូជ ០៦កន្លែង ដកហូតឧបករណ៍បទល្មើសជលផល មានលូស្បៃមុងប្រវែង៥,១០២ម ឧបករណ៍ឆក់ត្រី៦៧៩គ្រឿង មងប្រវែង៣,៥០០ម របាំងសាច់អួនប្រវែង៦០០ម លបចំនួន ១៥លប (ធ្វើសកម្មភាពក្នុងរដូវបិទនេសាទ) រៀបចំប្រារព្ធទិវាមច្ឆជាតិ១កក្កដាសម្រាប់ថ្នាក់ជាតិចំនួន០២កន្លែង រៀបចំប្រារព្ធទិវាមច្ឆជាតិ១កក្កដា សម្រាប់ថ្នាក់ខេត្តចំនួន១៥កន្លែង និងផ្សព្វផ្សាយច្បាប់ ស្តីពីជលផលបាន១៥ឃុំ។

ចលនាឱ្យចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ការផលិតកូនត្រីពូជ រៀបចំពិធីទិវាមច្ឆជាតិ១កក្កដាថ្នាក់ខេត្ត និងការលែងត្រីក្នុងបឹងធម្មជាតិ ស្រះជម្រកត្រី ការផ្សព្វផ្សាយច្បាប់ ការចុះអនុវត្តច្បាប់ស្តីពីជលផលត្រូវបានចាប់ផ្តើមមានសកម្មភាពជាបណ្តើរៗ។

គម្រោងអភិវឌ្ឍវារីវប្បកម្មជនបទ និងគ្រប់គ្រងធនធានវារីសត្វថ្នាក់ខណ្ឌ ក្នុងនោះបានរៀបចំបង្កើតសហគមន៍ស្រះជម្រកត្រីចំនួន២៥កន្លែង ផ្តល់កូនត្រីពូជដល់ កសិករចិញ្ចឹមចំនួន ២០០គ្រួសារ សាលារៀនចំនួន២០សាលា ផ្សព្វផ្សាយច្បាប់ស្តីពីជលផល កំណត់ផែនទីស្រះជម្រកត្រីដែលបានទទួលការឧបត្ថម្ភគាំទ្រប្រភពជានីជាចំនួនថវិកាពី៦០,០០០ដុល្លារ ទៅ ៨០,០០០ដុល្លារ អាងបង្កាត់ភ្ញាស់កូនត្រី០១កន្លែង។ គម្រោងបង្កើនសន្តិសុខស្បៀងសម្រាប់គ្រួសារកសិករ ដែលរងឥទ្ធិពលដោយសារការឡើងថ្លៃស្បៀងអាហារ ខណ្ឌរដ្ឋបាលជលផល បានរៀបចំស្រះជម្រកត្រីចំនួន០៨កន្លែង ផ្តល់កូនត្រីពូជដល់កសិករចិញ្ចឹមត្រីចំនួន ២៥០គ្រួសារ បង្កង ២៥គ្រួសារ អាងបង្កាត់ភ្ញាស់កូនត្រីពូជចំនួន០១គ្រួសារ អាងបំប៉នកូនត្រីពូជ០១គ្រួសារ ដែលបានឧបត្ថម្ភថវិកាពីសហភាពអឺរ៉ុបចំនួន៦៤,០៩២ដុល្លារ និងគម្រោងរបស់អង្គការផ្សេងៗបានជួយរៀបចំបង្កើតស្រះជម្រកត្រីចំនួន៥៨កន្លែងថែមទៀត។

កត់សម្គាល់ឃើញថា ការបង្កើនផលិតភាពវិស័យកសិកម្មត្រូវបានលើកកម្ពស់ និងបច្ចេកវិទ្យាត្រូវបានបញ្ចូលទៅក្នុងការធ្វើពិពិធកម្មតាមប្រព័ន្ធកសិកម្មដោយបានប្រែក្លាយពីការធ្វើតែមួយមុខមកធ្វើកសិកម្មចម្រុះជាមួយការចិញ្ចឹមត្រីប្រភេទដំណាំស្រូវ និងការចិញ្ចឹមសត្វ ដោយកំណត់នូវវិធីសាស្ត្រ និងទីតាំងសមស្រប។

ការប្រែប្រួលនេះកើតឡើងដោយមានការផ្សព្វផ្សាយនូវចំណេះដឹងបច្ចេកវិទ្យា តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការផ្សារភ្ជាប់រវាងការស្រាវជ្រាវ និងការផ្សព្វផ្សាយតាមរូបភាព ការអភិវឌ្ឍសមត្ថភាពធនធាន មនុស្សក្នុងនោះរួមមាន ទិវាស្រះចិញ្ចឹមត្រីកសិករ សិក្ខាសាលា អង្គប្រជុំ វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និង មធ្យមជាបន្តបន្ទាប់គួបផ្សំនឹងកម្រិតភ្ញាក់រឭករបស់ប្រជាពលរដ្ឋ។

ទោះបីមានវឌ្ឍនភាពដូចបានរៀបរាប់ខាងលើក៏ដោយ ក៏វិស័យនេះនៅមានបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- ការយល់ដឹងផ្នែកបច្ចេកទេសកសិកម្មរបស់កសិករភាគច្រើននៅមានកម្រិត ខ្វះកម្លាំងពលកម្ម តម្លៃស្រូវ និងផលិត ផលសត្វធ្លាក់ចុះជាងបណ្ដាឆ្នាំ (គោ,ជ្រូក)។

- ចំណេះដឹងរបស់ថ្នាក់ដឹកនាំ និងសមាជិកសហគមន៍កសិកម្ម នៅមានកម្រិត, ការគ្រប់គ្រងសាច់ប្រាក់ និងការធ្វើ បញ្ជីគណនេយ្យមិនទាន់ត្រឹមត្រូវចូលរួមពីអាជ្ញាធរ

- ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារមានលក្ខណៈប្រពៃណី(ទម្លាប់ព្រលែងចោល)ជាយកថាផល

- ស្ថានភាពជម្ងឺសត្វនៅមានផ្ទុះ (អុតក្ដាម,បូសខ្យល់) សេវាសុខភាពសត្វភូមិនៅមានកម្រិត (ភ្នាក់ងារ, ចំណេះដឹង , ធនធាន,មធ្យោបាយ )

-ការយល់ដឹងរបស់កសិករការប្រើប្រាស់សម្ភារៈកសិកម្មឱ្យបានត្រឹមត្រូវតាមបច្ចេកទេសនិងការគ្រប់គ្រង ជីជាតិដី ក៏នៅតែជាបញ្ហាប្រឈមនៅឡើយដែលសកម្មភាពនានាពាក់ព័ន្ធបញ្ហានេះនិងត្រូវយកចិត្តទុកដាក់អនុ វត្តបន្តឱ្យបានខ្លាំងក្លា។

- ប្រជាជនដែលរស់នៅ ជាប់ដែនជម្រកព្រៃឈើ តែងពឹងផ្អែកអាស្រ័យលើអនុផល និងកាប់រានដែន ជម្រកព្រៃឈើ

-ផ្ទៃដីព្រៃឈើដែលមានសក្ដានុពលមានការថយចុះ ដោយសារមានការផ្ទេរដែនសមត្ថកិច្ចគ្រប់គ្រង ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅឲ្យក្រសួងបរិស្ថានគ្រប់គ្រង។

- អាជីវករលក់ដូរសម្ភារកសិកម្មមួយចំនួនតូច មិនទាន់យល់អំពីគោលការណ៍គ្រប់គ្រងសម្ភារកសិកម្ម មិនបាន សហការ ជាមួយមន្ត្រីចុះត្រួតពិនិត្យ និងមិនចូលរួមវគ្គបណ្ដុះបណ្ដាល បច្ចេកទេស គ្រប់គ្រងការធ្វើ អាជីវកម្មសម្ភារកសិកម្ម។

-ភូមិសាស្ត្រខ្លះមានលក្ខណៈស្មុគ្រស្មាញ បទល្មើសភាគច្រើនដឹកជញ្ជូនដោយរទេះគោ គោយន្តដោយ ប្រជា ពលរដ្ឋ ក្រីក្រនិងមួយចំនួនទៀតដឹកតាមរូបភាពបង្កប់ក្រោមទំនិញផ្សេងៗរថយន្តទំនើបៗអ្នកបើកបរខ្លះ ញៀនថ្នាំបញ្ជារថយន្តមិនខ្លាច
គ្រោះថ្នាក់ និងមានការគំរាមកំហែង ដល់មន្ត្រីរដ្ឋបាលព្រៃឈើពេលចុះប្រតិបត្តិការបង្ក្រាបបទល្មើស។

## ២. ការងារប្រព័ន្ធធារាសាស្ត្រ (ទិន្នន័យចាស់)

វឌ្ឍនភាពក្នុងវិស័យធនធានទឹកក្នុងខេត្ត មានការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធស្រោចស្រពបានផ្ដល់ នូវកំណើនផ្ទៃដីស្រោចស្រព និងកំណើនទិន្នផលដំណាំកសិកម្មព្រមទាំងបានផ្ដល់នូវការការពារពីគ្រោះមហន្តរាយ ដោយធម្មជាតិ (គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់) កាន់តែមានប្រសិទ្ធភាព។ នៅទូទាំងខេត្តមានប្រព័ន្ធស្រោច ស្រពសរុបចំនួន ៣៧៥ប្រព័ន្ធ ក្នុងនោះប្រព័ន្ធបានស្ដារហើយមានចំនួន ១៣០ប្រព័ន្ធ។ ប្រព័ន្ធស្រោចស្រពខ្នាត ធំដែលបានស្ដារហើយ គឺប្រព័ន្ធស្រោចស្រពរលាំងជ្រៃ ដែលបានស្រោចស្រពលើតំបន់កណ្ដាលនៃខេត្ត រួមមាន (ស្រុកសំរោងទង គងពិសី និងក្រុងច្បារមន) ប្រព័ន្ធស្រោចស្រពពាមពូល ស្រោចស្រពផ្នែកខាងលិចនៃខេត្ត (ស្រុកភ្នំស្រួច) ប្រព័ន្ធស្រោចស្រពតាសាល ពាមល្វា អន្លង់ជ្រៃ និងចាន់ថ្នាល ស្រោចស្រពនៅផ្នែកខាងជើងនៃ

ខេត្ត (ស្រុកឱរ៉ាល់ ថ្ពង និងស្រុកឧដុង្គ) ប្រព័ន្ធស្រោចស្រពស្វាយ អូរគ្រែង ខ្ពបគ្រួស តានួន-តាដែង អង្គតាកិប ស្រោចស្រពបាននៅផ្នែកខាងត្បូងនៃខេត្ត (ស្រុកបសេដ្ឋ)។ សំណង់សិល្បកាសរុបចំនួន ៧២៥កន្លែង ប្រឡាយមេចំនួន ២៣៧ខ្សែ ប្រវែងសរុប ៨២០,៩១៨ម៉ែត្រ និងប្រឡាយរង ៣៩៥ខ្សែ ប្រវែងសរុប ៤៦៧,៨៥២ម៉ែត្រ។ មកដល់បច្ចុប្បន្ន ប្រព័ន្ធស្រោចស្រពមានលទ្ធភាពស្រោចស្រពលើផ្ទៃដីស្រូវរដូវវស្សាចំនួន ៥៩,០៧២ហិកតា និងស្រូវរដូវប្រាំងចំនួន ១,៨៥៧ហិកតា ។

ជាទូទៅក្នុងឆ្នាំ២០១៦ កម្ពស់ទឹកភ្លៀងមធ្យមទូទាំងខេត្ត មានកម្ពស់១,៥៣០.៤មម ប្រៀបធៀបទៅនឹងឆ្នាំ ២០១៥ រយៈពេលដូចគ្នាខ្ពស់ជាង ៣៩០.៤មម ។ ស្រុកដែលទទួលទឹកភ្លៀងច្រើនជាងគេ គឺក្រុងច្បារមន ទឹកភ្លៀងមានកម្ពស់ ១,៦៨៣.២មម ស្រុកដែលទទួលទឹកភ្លៀងតិចជាងគេ គឺស្រុកបសេដ្ឋ ទឹកភ្លៀងមានកម្ពស់ ១,២៤៦មម។

**បញ្ហាប្រឈម រួមមានៈ**

- ការផ្តល់ថវិកាសម្រាប់ការងារជួសជុល ស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតទាប និងមានការយឺតយ៉ាវពុំទាន់ឆ្លើយតបតាមពេលវេលា និងសំណូមពររបស់ប្រជាពលរដ្ឋ
- នៅខ្វះទំនប់សណ្តូវតាមដងស្ទឹង ដែលជួយការពារបាននូវផលដំណាំ ពិសេសដំណាំស្រូវរបស់ប្រជាជននៅពេលមានទឹកជំនន់ម្តងៗ
- ពុំអាចផ្គត់ផ្គង់ទឹកសម្រាប់ការផលិតស្រូវរដូវប្រាំង និងស្រូវបង្កើនរដូវតាមសំណូមពររបស់ប្រជាកសិករនៅតាមប្រព័ន្ធស្រោចស្រពនៅឡើយ
- យន្តការគ្រប់គ្រង ចែកចាយការប្រើប្រាស់ទឹករបស់សហគមន៍កសិករប្រើប្រាស់ទឹក ពុំទាន់ឆ្លើយតបតាមតម្រូវការនៅឡើយ
- ការចូលរួមរបស់កសិករ និងអាជ្ញាធរមូលដ្ឋានលើការងារគ្រប់គ្រង ប្រើប្រាស់ ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រមិនទាន់បានសមស្រប
- ការយាយីនៃគ្រោះធម្មជាតិ ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុកាន់តែមានកម្រិតខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ពិសេសគឺគ្រោះរាំងស្ងួត
- កង្វះខាតឧបករណ៍ សម្ភារៈ សម្រាប់ផ្នែកធារាសាស្ត្រ និងផ្នែកឧតុនិយម និងជលសាស្ត្រ
- កង្វះខាតទិន្នន័យប្រភពទឹកក្រោមដី ក្នុងខេត្ត
- ភាពអាណាធិបតេយ្យលើវិស័យធនធានទឹកនៅតែកើតមានឡើង ទោះបីមានការទប់ស្កាត់យ៉ាងណាក៏ដោយ។

### ១.២.១.៣ វិស័យឧស្សាហកម្ម (ទិន្នន័យចាស់)

វិស័យឧស្សាហកម្ម និងសិប្បកម្ម គឺជាវិស័យមួយដែលមានសក្តានុពលសម្រាប់សេដ្ឋកិច្ចជាតិបច្ចុប្បន្ន វិស័យនេះមានការរីកចម្រើន និងឈានឡើងជាលំដាប់ ហើយបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ម្យ៉ាងទៀតបានចូលរួមចំណែកធ្វើឱ្យមានកំណើន

សេដ្ឋកិច្ចជាតិស្របទៅនឹងគោលនយោបាយចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥។

បច្ចុប្បន្នវិស័យឧស្សាហកម្ម និងសិប្បកម្ម មានការងារ ២ សំខាន់ៗចំពោះមុខរួមមាន ៖

១. ការងារឧស្សាហកម្ម និងសិប្បកម្ម (**ទិន្នន័យចាស់**)

បច្ចុប្បន្នខេត្តកំពង់ស្ពឺ មានសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម សរុបចំនួន ៦,១៤៨មូលដ្ឋានប្រើប្រាស់ពលកម្មសរុបចំនួន ១៧,១០៤នាក់ ស្រី ៦,២៤៤នាក់ ។

រោងចក្រធុនធំសរុបចំនួន ១៤៧ រោងចក្រ ប្រើប្រាស់ពលកម្មសរុប ៩៧,២១៩នាក់ ស្រី ៩៤,៥៧៤នាក់ ក្នុងនោះរួមមាន៖

- រោងចក្រកំពុងដំណើការ មានចំនួន ១១៧ រោងចក្រ
- រោងចក្រផ្អាកដំណើការ មានចំនួន ១២ រោងចក្រ
- រោងចក្រកំពុងសាងសង់ មានចំនួន ១៨ រោងចក្រ

២. ការងារស្តង់ដា និងមាត្រាសាស្រ្ត (**ទិន្នន័យចាស់**)

មាត្រាសាស្រ្ត គឺជាផ្នែកមួយមានសារៈសំខាន់ធ្វើឱ្យអ្នកប្រើប្រាស់ឧបករណ៍មាត្រាសាស្រ្តក្នុងវិស័យពាណិជ្ជកម្ម វិស័យឧស្សាហកម្ម និងវិស័យផ្សេងៗទៀតមានភាពត្រឹមត្រូវ និងយុត្តិធម៌ ។ បច្ចុប្បន្នខេត្តកំពង់ស្ពឺមានឧបករណ៍មាត្រាសាស្រ្ត កំពុងប្រើប្រាស់ចំនួន ៣៦,៣២០គ្រឿង ក្នុងនោះរួមមាន៖

- ជញ្ជីងគ្រប់ប្រភេទ មានចំនួន ២,៩៣១ គ្រឿង
- ដែរវ៉ែធុងប្រេងចំណុះ ៥ លីត្រ មានចំនួន ៨១ គ្រឿង
- ស្ថានីយ៍ប្រេងឥន្ធនៈ មានចំនួន ១៩១ ស្មើនឹង១៧៩៨ដៃបាញ់
- កុងទ័រទឹក មានចំនួន ៣១,៥១០ គ្រឿង

### ១.២.១.៤ វិស័យគមនាគមន៍

### ១. ការងារសាធារណការ និងដឹកជញ្ជូន

វិស័យគមនាគមន៍ គឺជាកត្តាសំខាន់បំផុតក្នុងផ្នែកសេដ្ឋកិច្ច ព្រោះគមនាគមន៍ជាសរសៃឈាមផ្នែកសេដ្ឋកិច្ច ដែលជួយជំរុញកំណើនសេដ្ឋកិច្ចប្រទេសជាតិឱ្យកាន់តែរីចម្រើនទៅមុខជានិច្ច។ ជាងនេះទៅទៀតវិស័យគមនាគមន៍ក៏បានតភ្ជាប់ពីជនបទដាច់ស្រយាលឆ្ងាយៗមកកាន់ទីក្រុង និងពីតំបន់មួយទៅតំបន់មួយទៀតទូទាំងប្រទេស។ជាពិសេសមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ស្ពឺជាអង្គភាពមូលដ្ឋានថ្នាក់ក្រោមជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរដែនដី និងការគ្រប់គ្រងជំនាញដោយក្រសួងសាធារណការ និងដឹកជញ្ជូន។មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ស្ពឺស្ថិតនៅផ្នែកខាងលិចនៃរាជធានីភ្នំពេញ ទទួលបានការអភិវឌ្ឍន៍លើវិស័យសាធារណការ និងដឹកជញ្ជូនលើការគ្រប់គ្រងផ្លូវ-ថ្នល់ ផ្លូវជាតិ និងផ្លូវខេត្ត ការត្រួតពិនិត្យផ្លូវ-លូ-ស្ពាន ព្រមទាំងសណ្តាប់ធ្នាប់សាធារណៈតាមដងផ្លូវជាតិ និងផ្លូវខេត្តដែលស្ថិតនៅភូមិសាស្រ្តខេត្តកំពង់ស្ពឺទាំងមូល។

លទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៧ នេះរួមមាន ៖ (**ទិន្នន័យចាស់**)

១- ផ្លូវជាតិ ១ លេខ : មាន ០៣ខ្សែ គឺលេខ ៣ ៤ និង៥

+ ផ្លូវជាតិលេខ ៣ អនុវត្តបាន ៤២ គីឡូម៉ែត្រ
+ ផ្លូវជាតិលេខ ៤ អនុវត្តបាន ៧៧,៥ គីឡូម៉ែត្រ
+ ផ្លូវជាតិលេខ ៥ អនុវត្តបាន ២ គីឡូម៉ែត្រ

សរុបបានប្រវែង ១២១,៥ គីឡូម៉ែត្រ

២- ផ្លូវជាតិ ២ លេខ : មាន ០៥ ខ្សែ គឺលេខ ៤១, ៤៣, ៤៤, ៤៦ និង៥១

+ ផ្លូវជាតិលេខ ៤១ អនុវត្តបាន ៤៤,៨ គីឡូម៉ែត្រ
+ ផ្លូវជាតិលេខ ៤៣ អនុវត្តបាន ២២,៥ គីឡូម៉ែត្រ
+ ផ្លូវជាតិលេខ ៤៤ អនុវត្តបាន ១៩០ គីឡូម៉ែត្រ
+ ផ្លូវជាតិលេខ ៤៦ អនុវត្តបាន ២២ គីឡូម៉ែត្រ
+ ផ្លូវជាតិលេខ ៥១ អនុវត្តបាន ៣៨,១ គីឡូម៉ែត្រ

**សរុបបានប្រវែង ៣១៧,៤ គីឡូម៉ែត្រ**

៣- ផ្លូវជាតិ ៣ លេខ : មាន ១២ ខ្សែ គឺ លេខ ១៣០, ១៤០, ១៤១, ១៤៣, ៤៨-៤, ១៤៧, ១៤៩, ១KS១, ១KS២, ១KS៣, ១KS៤ និង១៤៤០ អនុវត្តសរុបបានប្រវែង ២៩៣,៣ គីឡូម៉ែត្រ

៤- ផ្លូវក្នុងក្រុងមានចំនួន ១១ ខ្សែ គឺ លេខ ១០១, ១០២, ១០៣, ១០៤, ១០៥, ១០៦, ១០៧, ១០៨, ១០៩, ១១០ និង១១១ អនុវត្តសរុបបានប្រវែង ២៦,៣៩ គីឡូម៉ែត្រ

## ២. ការងារអភិវឌ្ឍន៍ជនបទ

ចំពោះការងារអភិវឌ្ឍន៍ជនបទឆ្នាំ២០១៨ ក្នុងខេត្តកំពង់ស្ពឺ មានការរីកចម្រើនគួរកត់សម្គាល់ដូចជា៖ គម្រោងកែលម្អផ្លូវជនបទដំហ៊ានទី២ចំនួន៣ខ្សែ ប្រវែង ៧៥.គ២,មអនុវត្តហើយ១០០ខ្សែ ប្រវែង៧និង % ៨៨,៥០គ២.ខ្សែ ប្រវែង ១កំពុងដំណើរការ ជួសជុលផ្លូវក្រាលខ្សាច់ក្រួស ម.៥គម ថែទាំលក្ខណៈខួបអនុវត្តបាន. ម ថែទាំលក្ខណៈប្រចាំអនុវត្តបានប.គ៤៥ប្រវែង រវែង ៧០គម ចុះស្រង់.គ៥ម ជួសជុលបន្ទាន់អនុវត្តបាន. ម .គ៦៣១ប្រវែង ខ្សែ៧៥ម ធ្វើបច្ចុប្បន្នភាពផ្លូវជនបទបានចំនួន.គ៦២ខ្សែ ប្រវែង៣៣ទិន្នន័យផ្លូវជនបទបាន អណ្តូង អនុវត្តន៍ការងារលើក៦៥អណ្តូង ជួសជុលអណ្តូងស្នប់បានចំនួន ១០សាងសង់អណ្តូងស្នប់បានចំនួន ភូ២១៩កម្ពស់អនាម័យបានចំនួន មិ ផ្គត់ផ្គង់សម្ភារៈសាងសង់បង្គន់អនាម័យបានចំនួន៣០០បង្គន់ បើកវគ្គបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈបានចំនួន៨មុខជំនាញ ដែលមានសិក្ខាកាមចំនួន ៧៣៣នាក់ ស្រី ៣៣៥នាក់ និងបណ្តុះបណ្តាលគនាក់ អនុវត្តសាក៣៣៧នាក់ ស្រី១៤០ភចូលរួម ចំនួន.អ.ភូមិ គ៨៤វគ្គមកពី៤ភបានចំនួន.អ. ល្បងគម្រោងចលនាភូមិថ្មី ចំនួន១០ភូមិ និងបានចុះធ្វើបច្ចុប្បន្នភាពជនជាតិដើមភាគតិចស្ទួយ នៅឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ចំនួន៥ភូមិ។

**បញ្ហាប្រឈមមួយ រួមមាន៖**

- ការបម្រែបម្រួលអាកាសធាតុ ដែលធ្វើឲ្យប៉ះពាល់ដល់ គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ

- កំណើនយាន្តយន្តការដឹកលើសទម្ងន់កំណត់ និងបើកលើសល្បឿនកំណត់ ធ្វើឲ្យផ្លូវជនបទឆាប់ខូច និងមានគ្រោះថ្នាក់ចរាចរណ៍កើនឡើងជាញឹកញាប់
- ខ្វះការចូលរួមថែទាំផ្លូវជនបទពីថ្នាក់សហគមន៍ និងអ្នកប្រើប្រាស់ផ្លូវ
- ការចូលរួមថែទាំអណ្តូងទឹក ស្រះទឹកពីសហគមន៍នៅមានកម្រិត
- ការយល់ដឹងពីអនាម័យនៅតាមជនបទនៅមានកម្រិត
- ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋជនបទបានធ្វើឲ្យមានការខ្វះកម្រាំងពលកម្មនៅតំបន់ជនបទ
- ធនធានមនុស្សសម្រាប់ប្រើការអភិវឌ្ឍនៅមានកម្រិត
- ការបែងចែកថវិកាសម្រាប់វិស័យសំខាន់ៗ(ផ្លូវជនបទទឹកស្អាត និងអនាម័យ)ពុំទាន់ទៅតាមតម្រូវការ
- ថវិកាដែលរដ្ឋបានផ្តល់ជូននៅមានកម្រិត

### ១.២.១.៥ វិស័យសេវាកម្ម (ទិន្នន័យចាស់)

### ១. ការងារទឹកស្អាត

ខេត្តកំពង់ស្ពឺ មានអាជីវកម្មផលិត និងផ្គត់ផ្គង់ទឹកស្អាតចំនួន ៤២ ក្រុមហ៊ុន ក្នុងនោះរួមមាន ៖

- មានប្រកាសក្រសួង ចំនួន ២៤ ក្រុមហ៊ុន
- មានគោលការណ៍អនុញ្ញាតពីក្រសួង ចំនួន ១៦ ក្រុមហ៊ុន
- គម្រោងស្នើសុំធ្វើការសិក្សាសមិទ្ធិលទ្ធភាព ធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ចំនួន ០២ ក្រុមហ៊ុន

### ២. ការងារអគ្គិសនី/ថាមពល (ទិន្នន័យចាស់)

វិស័យថាមពល គឺជាវិស័យមួយដែលមានសក្តានុពលក្នុងការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៅមូលដ្ឋាន បច្ចុប្បន្នវិស័យនេះកំពុងមានការអភិវឌ្ឍន៍ និងជាប្រភពចំណូលយ៉ាងសំខាន់ក្នុងការជួយលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។ ម្យ៉ាងទៀតវិស័យថាមពលបានចូលរួមចំណែក ពង្រីកសេដ្ឋកិច្ចជាតិស្របទៅនឹងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលអាណត្តិទី៣។

គោលបំណងសំខាន់ៗចំពោះមុខលើការគ្រប់គ្រងការធ្វើអាជីវកម្ម ការសិក្សាស្រាវជ្រាវរុករករ៉ែគ្រប់ប្រភេទ និងការងារអភិវឌ្ឍន៍ថាមពល (ថាមពលកកើតឡើងវិញ ថាមពលថ្មី) ថាមពលវារីអគ្គិសនី ថាមពលពន្លឺព្រះអាទិត្យ ដែលកំពុងប្រតិបត្តិការឱ្យមានភាពប្រសើរឡើង និងការជំរុញ ធានាដំណើរការប្រេងឥន្ទនៈប្រកបដោយសុវត្ថិភាព និងគុណភាព។

ខេត្តមានវារីអគ្គិសនីគីរីរម្យទី១ -១២MW វារីអគ្គិសនីគីរីរម្យទី៣ -១៨MW រោងចក្រផលិតអគ្គិសនីដោយជីវម៉ាស់ ៥២MW អនុស្ថានី (GS) ចំនួន ០៣ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ៥០០KV ខ្សែបញ្ជូនតង់ស្យុង ២៣០KV ចំនួន ០២ ខ្សែ និងមួយខ្សែទៀតកំពង់ដំណើការសិក្សាភ្ជាប់ពីខេត្តកោះកុង មកក្នុងស្រុកឧដុង្គ និងក្រុមហ៊ុនធ្វើប្រតិបត្តិការចែកចាយអគ្គិសនីទាំងរដ្ឋ និងឯកជនមានចំនួន ២១ ទាំងអស់នេះវាជាអំណោយផលជំរុញអោយមានការអភិវឌ្ឍន៍យ៉ាងខ្លាំងក្នុងការ ស្តារពង្រឹងវិស័យថាមពល ដើម្បីបំពេញតម្រូវការ ប្រើប្រាស់ជូនប្រជាពលរដ្ឋ

ក្នុងខេត្ត និងវិស័យនេះជាស្នូលនៃកិច្ចគាំទ្រលើការវិនិយោគ ផ្នែកឧស្សាហកម្ម និងសេវាកម្មដើម្បីបង្កើនចំណូលសេដ្ឋកិច្ច។

ថាមពលជាផ្នែកមួយដ៏មានសារៈសំខាន់អាចឱ្យអាជីវករ សេវាករ អ្នកប្រើប្រាស់ថាមពលកំពុងធ្វើការចែកចាយ និងផ្គត់ផ្គង់អគ្គិសនីជូនប្រជាពលរដ្ឋនៅទីប្រជុំជន និងជនបទ សម្រាប់ប្រើប្រាស់ទៅតាមតម្រូវការ ។

បច្ចុប្បន្ននៅទូទាំងខេត្តមានសេវាករចែកចាយ និងផ្គត់ផ្គង (រដ្ឋ និងឯកជន) សរុប ២១ក្រុមហ៊ុន ក្នុងនោះរួមមាន៖

- អាជ្ញាប័ណ្ណចំនួន ១,៣២៥/១,៣៧៩ ភូមិ ស្មើនឹង ៩៦,០៨%
- បណ្តាញចូលដល់ចំនួន ១,២៦៨/១៣៧៩ភូមិ ស្មើនឹង ៩១,៩៥%
- អ្នកប្រើប្រាស់សរុប ១៤៩,៧៩១/១៧៩,៦២៧គ្រួសារ ស្មើនឹង ៨៣,៣៩%

### ៣. **ការខារ៉ែ**

មានថ្មសំណង់ ខ្សាច់ ថ្មអា និងប្រភេទរ៉ែលោហៈផ្សេងៗទៀត ជាក់ស្តែងយើងបានទាញយកចំណូលថវិកាជាតិ តាមរយៈការវិនិយោគរបស់ក្រុមហ៊ុនឯកជនមានដូចជា៖

- ក្រុមហ៊ុនធ្វើអាជីវកម្មថ្មសំណង់ មានចំនួន ២៧ ការដ្ឋាន
- ក្រុមហ៊ុនធ្វើអាជីវកម្ម ខ្សាច់ស្ទឹង មានចំនួន ១៣ ការដ្ឋាន
- ក្រុមហ៊ុនធ្វើអាជីវកម្ម ខ្សាច់បក មានចំនួន ០១ ការដ្ឋាន
- សិប្បកម្មខ្សាច់បកចំនួន ៣៤ ការដ្ឋាន
- ក្រុមហ៊ុនធ្វើអាជីវកម្មថ្មអារ ចំនួន០៣ ក្រុមហ៊ុន
- ក្រុមហ៊ុនរ៉ែលោហៈដែលបាននិងកំពុងធ្វើការសិក្សាចំនួន ០៤ ការដ្ឋាន

### ៤. **ការខារទេសចរណ៍**

មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ ជាសេនាធិការឱ្យក្រសួងទេសចរណ៍ក្នុងការដឹកនាំ គ្រប់គ្រងវិស័យទេសចរណ៍ និងអនុវត្តសារាចរណែនាំ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិនានារបស់រាជរដ្ឋាភិបាល និងក្រសួងទេសចរណ៍ ក៏ដូចជាអាជ្ញាធរខេត្ត ដើម្បីផ្តល់ការណែនាំ អប់រំ និងពង្រឹងដល់ប្រតិបត្តិករទេសចរណ៍ទាំងអស់ដែលមានទីតាំងក្នុងខេត្ត។

ទេសចរណ៍ជាវិស័យមួយ ដែលមានលក្ខណៈជាប្រព័ន្ធនិងជាវិស័យអាទិភាពមួយក្នុងចំណោមអាទិភាពផ្នែកសេដ្ឋកិច្ចសំខាន់ៗ ដោយចូលរួមចំណែកកសាងសេដ្ឋកិច្ចសង្គម។ បច្ចុប្បន្នខេត្តកំពង់ស្ពឺ មានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន សេវាកម្ម និងមានតំបន់ទេសចរណ៍សំខាន់ៗចំនួន៩កន្លែង រួមមាន៖ រមណីយដ្ឋានអំពៃភ្នំ រមណីយដ្ឋានដើមស្រល់ ( V kirirom pine Resort ) រមណីយដ្ឋានគីរីរម្យ ឧទ្យានជាតិគីរីរម្យ សហគមន៍ទឹកធ្លាក់ចំបក់ ទឹកធ្លាក់ភ្នំជ្រាវឱរ៉ាល់ តំបន់តេទឹកពុះ រមណីយដ្ឋានបុរាណវិទ្យាភ្នំចាស់ ភ្នំព្រះ និងកីឡាវាយកូនហ្គោល១កន្លែង។ កីឡា និងតំបន់ទេសចរណ៍ទាំងនេះបានទាក់ទាញភ្ញៀវទេសចរជាច្រើនចូលមកទស្សនាប្រមាណ២៣៥,៣៥១ នាក់ បើប្រៀបធៀបឆ្នាំ២០១៦រយៈពេលដូចគ្នា ២២៩,១៧៩ នាក់ កើន២.៦% និងកើនដល់ ៦១៧,៥៧៦ នាក់ នៅឆ្នាំ២០២០។ ពិសេសតំបន់ឧទ្យានជាតិគីរីរម្យ ដែលមានបរិយាកាសត្រជាក់ស្រួល

ហើយសម្បូរទៅដោយដើមស្រស់ ទន្ទឹមនិងនោះដែរ យើងមានសេវាកម្មម្ហូបអាហារ សេវាស្នាក់នៅ និងសេវាកម្សាន្តមួយចំនួនទៀត។

**បញ្ហាប្រឈមរួមមាន៖**

- មូលដ្ឋានអាជីវកម្មសេវាកម្មមួយចំនួនមិនទាន់មានលក្ខណៈបច្ចេកទេសទៅតាមស្តង់ដារតម្រូវ
- ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍មិនទាន់បានប្រសើរ គ្រប់ជ្រុងជ្រោយ ដែលធ្វើឱ្យអាជីវកម្មមួយចំនួនមានភាពអាណាធិបតេយ្យ
- ខ្វះការចូលរួមពីអ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការជំរុញ និងលើកស្ទួយវិស័យទេសចរណ៍
- ការផ្សព្វផ្សាយអំពីសក្តានុពលទេសចរណ៍ពុំទាន់មានលក្ខណៈទូលំទូលាយនៅឡើយ
- សេវាកម្មមួយចំនួនមិនទាន់យល់អំពីការធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវឱ្យបានល្អ
- ការផ្សព្វផ្សាយច្បាប់ទេសចរណ៍ និងបទដ្ឋានគតិយុត្តឱ្យបានទូលំទូលាយដល់មូលដ្ឋានអាជីវកម្ម
- មន្ទីរពុំមានថវិកាសម្រាប់ការបើកវគ្គបណ្តុះបណ្តាល ក៏ដូចជាការផ្សព្វផ្សាយច្បាប់ និងការបើកវគ្គបដិសណ្ឋារកិច្ចជូនដល់មូលដ្ឋានអាជីវកម្ម។

### ១.២.១.៦ ការវិនិយោគ (ទិន្នន័យចាស់)

### ១. ការងារអភិវឌ្ឍន៍ផ្សារ

ខេត្តកំពង់ស្ពឺមានផ្សារសរុបចំនួន ១១ ក្នុងនោះមានផ្សារកញ្ច្រែងចំនួន ០២។

- ផ្សារវិនិយោគមានចំនួន ០៤ផ្សារ
  1. ផ្សារកំពង់ស្ពឺ
  2. ផ្សារឧដុង្គ-បាត់ដឹង
  3. ផ្សារកញ្ច្រែងមាត់ស្ទឹង
  4. ផ្សារកញ្ច្រែងនាគព័ន្ធ
- ផ្សារដែលដេញថ្លៃប្រចាំឆ្នាំមានចំនួន ០៧ផ្សារ
  1. ផ្សារត្រពាំងក្រឡឹង
  2. ផ្សារត្រែងត្រយឹង
  3. ផ្សារថ្នល់ទទឹង
  4. ផ្សារតាឡាត់
  5. ផ្សារស្លាបលែង
  6. ផ្សារក្រាំងចេក
  7. ផ្សារព្រៃផ្តៅ

### ២. ការងារសត្តឃាត (ទិន្នន័យចាស់)

ខេត្តកំពង់ស្ពឺមានកន្លែងសត្តឃាតសរុបចំនួន ១២កន្លែង

1. គោ-ជ្រូក (ច្បារមន)

2. គោ-ជ្រូក ត្រពាំងក្រឡឹង (ភ្នំស្រួច)
3. គោ-ជ្រូក ត្រាំខ្នារ (គងពិសី)
4. គោ-ជ្រូក វាំងចាស់ (ឧដុង្គ)
5. គោ-ជ្រូក (បសេដ្ឋ)
6. គោ-ជ្រូក ត្រែងត្រយឹង (ភ្នំស្រួច)
7. គោ-ជ្រូក ក្រាំងចេក (ឧដុង្គ)
8. ជ្រូក បាត់ដឹង (ឧដុង្គ)
9. គោ បាត់ដឹង (ឧដុង្គ)
10. ជ្រូក តាឡាត់ (ភ្នំស្រួច)
11. គោ-ជ្រូក អង្គមេត្រី (សំរោងទង)
12. ជ្រូក ថ្នល់ទទឹង (សំរោងទង)

### ១.២.១.៧ វិស័យពន្ធដារ (វិន័្ធន័យចាស់)

ស្របតាមបរិបទថ្មីនៃគោលនយោបាយកែទម្រង់ស៊ីជម្រៅ និងមុតស្រួចរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈគោលនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ជាពិសេសដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម និងគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជាសាខាពន្ធដារខេត្តកំពង់ស្ពឺ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធ និងចូលរួមអនុវត្តការងារកែទម្រង់ តាមរយៈការពង្រឹងគោលនយោបាយសារពើពន្ធ ព្រមទាំងរដ្ឋបាលសារពើពន្ធ សំដៅធានាឱ្យបាននូវតម្លាភាព សមភាព និងប្រសិទ្ធភាពខ្ពស់នូវកិច្ចការប្រមូលចំណូលពន្ធ។ បច្ចុប្បន្នការប្រមូលពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុវត្ត របបតែមួយគឺ របបស្វ័យប្រកាស ដែលតម្រូវឱ្យអ្នកជាប់ពន្ធធ្វើការគណនាប្រាក់ពន្ធ និងដាក់លិខិតប្រកាសពន្ធដោយខ្លួនឯង ហើយអ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាសត្រូវបានបែងចែកជា ០៣ប្រភេទគឺ៖

១.អ្នកជាប់ពន្ធតូច

២.អ្នកជាប់ពន្ធមធ្យម

៣.អ្នកជាប់ពន្ធធំ

ដោយឡែកចំពោះស្ថានភាពការប្រមូលពន្ធក្នុងសាខាពន្ធដារខេត្តកំពង់ស្ពឺវិញ គឺមានលក្ខណៈល្អប្រសើរ ទោះជាខេត្តពុំសូវមានមូលដ្ឋានអាជីវកម្មច្រើន ឬធំដុំយ៉ាងណាក៏ដោយក៏បច្ចុប្បន្នសាខាពន្ធដារខេត្តខិតខំប្រមូលពន្ធឱ្យអស់ពីលទ្ធភាព និងឱ្យបានគ្រប់តាមផែនការ ដែលច្បាប់បានកំណត់។ បច្ចុប្បន្នសាខាពន្ធដារខេត្តបាននិងកំពុងគ្រប់គ្រងអ្នកជាប់ពន្ធពីរប្រភេទគឺ អ្នកជាប់ពន្ធតូច និងអ្នកជាប់ពន្ធមធ្យម។ ចំណែកអ្នកជាប់ធំ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយដ្ឋានពន្ធដារ។

រយៈពេលកន្លងមកសាខាពន្ធដារបានប្រមូលចំណូលលើប្រភេទពន្ធដូចជា៖

**១.ចំណូលថវិការដ្ឋមាន៖** ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ពន្ធលើប្រាក់ចំណូលនីតិបុគ្គល ពន្ធលើប្រាក់បៀវត្ស អាករលើផលរបរ អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញមួយចំនួន អាករពិសេសលើសេវាមួយចំនួន ពន្ធតែមប្រ៊ី។

**២.ចំណូលថវិកាខេត្តមាន៖** ពន្ធលើឈ្នួលអចលនទ្រព្យរូបវន្តបុគ្គល ពន្ធលើឈ្នួលអចលនទ្រព្យនីតិបុគ្គល អាករសម្រាប់បំភ្លឺសាធារណៈ អាករលើការស្នាក់នៅ ពន្ធប៉ាតង់ ពន្ធមធ្យោបាយដឹកជញ្ជូន ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យរូបវន្តបុគ្គល ពន្ធលើអចលនទ្រព្យនីតិបុគ្គល និងពន្ធលើដីធ្លីមិនប្រើប្រាស់។

ផែនការសរុបឆ្នាំ២០១៧ របស់ខេត្តមានចំនួន ២៣,៤៤៣,០០០,០០០រៀល ក្នុងនោះ៖

- ថវិការដ្ឋ ១៥,៩៥៨,០០០,០០០ រៀល
- ថវិកាខេត្ត ៧,៤៨៥,០០០,០០០ រៀល

**អនុវត្តបាន៖**

- ថវិការដ្ឋ ១៤,៨២៣,៤៤៧,៣៨៤ រៀល ស្មើនឹង ៩២.៨៩%
- ថវិកាខេត្ត ១២,០៧៤,៣៥១,៨០៧ រៀល ស្មើនឹង ១៦១.៣១%

**សរុប៖** ២៦,៨៩៧,៧៩៩,១៩១ រៀល ស្មើនឹង ១១៤.៧៤%

**បញ្ហាប្រឈមរួមមាន៖ (ទិន្នន័យចាស់)**

ទន្ទឹមនឹងការប្រមូលចំណូលពន្ធរបស់សាខាពន្ធដារខេត្តកំពង់ស្ពឺ បានលើសផែនការ សាខាពន្ធដារក៏មាននូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- អ្នកជាប់ពន្ធមានការយល់ដឹងអំពីច្បាប់ និងបទបញ្ញត្តិស្តីពីសារពើពន្ធនៅមានកម្រិត
- សហគ្រាសមួយចំនួនមិនបានបំពេញកាតព្វកិច្ចក្នុងការដាក់លិខិតប្រកាសប្រចាំខែ ប្រចាំឆ្នាំបានត្រឹមត្រូវ។
- សហគ្រាសមួយចំនួនបាត់ខ្លួនដោយមិនដាក់លិខិតប្រកាសបិទសហគ្រាស។
- សហគ្រាសមួយចំនួនមិនបានមកធ្វើបច្ចុប្បន្នភាព ទោះបីជាសាខាពន្ធដារខេត្តកំពង់ស្ពឺបានធ្វើលិខិតរំលឹកច្រើនដងក៏ដោយ។
- សហគ្រាសមួយចំនួនមិនចង់កាន់កាប់កត់ត្រាបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច។
- សហគ្រាសមួយចំនួនមិនបានផ្តល់កិច្ចសហការជាមួយមន្ត្រីជំនាញសម្រាប់ការអនុវត្តការប្រមូលចំណូលពន្ធ។

### ១.២.១.៨ វិស័យធនាគារជាតិ (ទិន្នន័យចាស់)

ក្រោយថ្ងៃរំដោះពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី៧ មករា ១៩៧៩ រដ្ឋាភិបាលបានការពារ និងកសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមឡើងវិញ ក្នុងនោះធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩។ ការបង្កើតធនាគារកណ្តាល និងការបោះពុម្ពរូបិយវត្ថុជាតិដាក់ឱ្យចរាចរឡើងវិញរបស់ប្រទេសកម្ពុជា គឺជាផ្នែកមួយនៃការចូលរួមចំណែកកសាងអធិបតេយ្យភាព និងអំណាចខាងសេដ្ឋកិច្ច

របស់រដ្ឋ។ មុននឹងឈានចូលដំណាក់កាលអភិវឌ្ឍន៍រីកចម្រើនដូចសព្វថ្ងៃនេះ ប្រព័ន្ធរូបិយវត្ថុ និងធនាគារក៏ដូចជាធនាគារជាតិនៃកម្ពុជា បានឆ្លងកាត់ដំណាក់កាលដ៏វែងឆ្ងាយពោរពេញដោយឧបសគ្គ និងការផ្លាស់ប្តូរជាច្រើនដំណាក់កាល។ ជាពិសេសវិស័យធនាគារបច្ចុប្បន្ន ដែលបាននិងកំពុងវិវឌ្ឍន៍រីកចម្រើនស្របនឹងការប្រែប្រួល នៃនិម្មាបនកម្មហិរញ្ញវត្ថុ និងអភិក្រមអន្តរជាតិ និងនិន្នាការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជាបានខិតខំបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនសម្រេចសមិទ្ធផលជាច្រើនជូនប្រទេស និងសង្គម។ សមិទ្ធផលទាំងនេះអាចឆ្លុះបញ្ចាំងតាមរយៈស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចជាតិ ដែលធនាគារជាតិបានកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន និងទន់ភ្លន់ ដើម្បីរក្សាស្ថិរភាពថ្លៃឆ្ពោះទៅរួមចំណែកគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមប្រកបដោយចីរភាព។ ជាមួយគ្នានោះ យើងខិតខំលើកកម្ពស់ជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល ដោយរក្សាស្ថិរភាពតម្លៃប្រាក់រៀលយ៉ាងល្អប្រសើរ និងគ្រប់គ្រងអតិផរណាឱ្យប្រែប្រួលក្នុងកម្រិតមួយទាប ស្របតាមការកំណត់គោលដៅរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ យើងក៏បានគ្រប់គ្រងទុនបម្រុងអន្តរជាតិឱ្យបន្តកើនឡើងជាលំដាប់ ដែលអាចធានាបានការនាំចូលទំនិញ និងសេវាប្រមាណ ៦ខែខ្ពស់ជាង២ដងនៃកម្រិតដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។

បច្ចុប្បន្នប្រព័ន្ធធនាគារនៅកម្ពុជារួមមាន៖ ធនាគារពាណិជ្ជចំនួន ៣៩ ធនាគារឯកទេសចំនួន ១៥ គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើសាធារណជនចំនួន ០៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៦៦ ប្រតិបត្តិករឥណទានជនបទចំនួន ២៦៧ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន ១២ អ្នកដំណើរការតតិយភាគី ១៣ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា១ ការិយាល័យតំណាងធនាគារបរទេស៦ និងអាជីវករប្តូរប្រាក់២,៤៣៧។ វិស័យធនាគារដែលគ្របដណ្តប់លើវិស័យហិរញ្ញវត្ថុបន្តស្ថិរភាពនិងអភិវឌ្ឍល្អប្រសើរទាំងផ្នែកវិសាលភាព និងផលិតផលហិរញ្ញវត្ថុ និងបណ្តាញសេវា វិស័យនេះ ត្រូវបានចាត់ទុកថាជាវិស័យគន្លឹះ និងបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា បានពង្រឹងសុខភាពហេដ្ឋារចនា សម្ព័ន្ធ និងអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការអភិវឌ្ឍរីកចម្រើន។ យ៉ាងណាមិញ ដើម្បីបន្តរួមចំណែកការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចកំណើនប្រកបដោយចីរភាព សមភាពបរិយាប័ន្ន និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជាស្របតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ និងយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ២០១៦-២០២៥ ធនាគារជាតិនៃកម្ពុជាមានទិសដៅរយៈពេលមធ្យម និងវែងខាងមុខ រួមមាន៖

១- រក្សាស្ថិរភាពថ្លៃ និងតម្លៃប្រាក់រៀលឱ្យបានល្អប្រសើរ
២- លើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយរូបិយវត្ថុ
៣- អភិវឌ្ឍវិស័យធនាគារប្រកបដោយប្រសិទ្ធិភាព ភាពរឹងមាំ ភាពប្រកួតប្រជែង និងសមាហរណកម្ម
៤- លើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងការអប់រំផ្នែកហិរញ្ញវត្ថុ
៥- គ្រប់គ្រងចរាចរណ៍រូបិយវត្ថុប្រកបដោយប្រសិទ្ធភាព
៦- លើកកម្ពស់ប្រសិទ្ធភាពការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
៧- ពង្រឹងសុវត្ថិភាពបច្ចេកវិទ្យា និងទំនើបកម្មប្រព័ន្ធទូទាត់
៨- បន្តអភិវឌ្ឍធនធានមនុស្ស និងអភិបាលកិច្ចល្អ និង

៩- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី។

### ១.២.១.៩ វិស័យហិរញ្ញវត្ថុ

រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥ បាននិងកំពុងយកចិត្តទុកដាក់ជាខ្លាំងលើកម្មវិធីកំណែទម្រង់សំខាន់ៗក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រចតុកោណ ជាពិសេសកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងលំដាប់បញ្ជីជួរទី១ នៃបញ្ហាអាទិភាព ដែលគ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្តទាំងអស់ត្រូវចូលរួមយ៉ាងសកម្ម និងដើរតួនាទីជាម្ចាស់សម្រាប់ផ្សាភ្ជាប់ការអភិវឌ្ឍន៍ទៅនឹងកំណែទម្រង់ដ៏ទៃទៀតឱ្យកាន់ស្អិតរមួតប្រទាក់ក្រឡាគ្នាស៊ីសង្វាក់គ្នា និងមានសង្គតិភាព។ នេះជាប្រការសំខាន់ចាំបាច់មិនអាចខ្វះបាន ដើម្បីធានាប្រសិទ្ធភាព និងភាពជោគជ័យនៃកំណែទម្រង់សំខាន់ៗនៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រចតុកោណ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអគ្គបញ្ជាការក្នុងការអនុវត្តន៍កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបញ្ចប់ជាសារវន្តប្រកបដោយជោគជ័យនូវគោលបំណងដំណាក់កាលទី១ គឺការបង្កើនភាពជឿទុកចិត្តលើថវិកា ដំណាក់កាលទី២ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និងសម្របសម្រួលក្នុងនាមជាកាតាលីករអនុវត្តនូវគោលបំណងដំណាក់កាលទី៣ គឺការផ្សាភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ពីឆ្នាំ២០១៦-២០២០ សំដៅបង្កើនការរៀបចំនិងអនុវត្តថវិកាត្រូវគាំទ្រនិងផ្សារភ្ជាប់ទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងទីបញ្ចប់ គឺគណនេយ្យភាពចំពោះសមិទ្ធកម្ម របស់អ្នកគ្រប់គ្រងថវិកាដែលជាគោលបំណងនៃដំណាក់កាល ទី ៤ ដើម្បីឈានទៅបង្កើននូវកម្រិតស្តង់ដារ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាឱ្យស្របទៅនឹង ស្តង់ដារអន្តរជាតិ ដែលជាចក្ខុវិស័យរយៈពេលវែងរបស់កម្មវិធីកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវចាប់អនុវត្តនៅឆ្នាំ២០២១-២០២៥។

សមិទ្ធផលនៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានជួយរួមចំណែកយ៉ាងសកម្ម និងធំធេងក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។ កម្មវិធីនេះបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានកំណើនប្រកបដោយចីរភាព ហើយក៏បានជួយជំរុញការអនុវត្តគោលនយោបាយរិមជ្ឈការ និងវិសហមជ្ឈការ និងគោលនយោបាយផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ព្រមទាំងបានជួយពង្រឹងសមត្ថភាពមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពជាប្រចាំទាំងនៅក្នុងប្រទេស និងក្រៅប្រទេសរហូតទទួលបានការកោតសរសើរពីប្រមុខរាជរដ្ឋាភិបាល និងបណ្តាដៃគូអភិវឌ្ឍន៍ជាច្រើន។

ក្នុងន័យនេះ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ស្ពឺក៏បាននិងកំពុងអនុវត្ត និងត្រៀមខ្លួនយ៉ាងល្អដោយបានខិតខំពង្រឹងសមត្ថភាព លើកកម្ពស់កម្រិតការងារ សម្របសម្រួលជាមួយមន្ទីរ អង្គភាពនានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើការកែសម្រួលរចនាសម្ព័ន្ធ ដែលមានស្រាប់ និងអនុវត្តតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាលអាណត្តិទី៥ និងអាណត្តិក្រោយទៀត ដើម្បីឈានសម្រេចតាមអភិក្រម ៤ យ៉ាងគឺ ងូតទឹក ដុះក្អែល ផ្លុះកញ្ចក់ និងព្យាបាល។

### ១.២.២. ស្ថានភាពសង្គមកិច្ច (ទិន្នន័យចាស់)

វឌ្ឍនភាពគួរកត់សម្គាល់បានសម្ដែងឱ្យឃើញថា ស្ថានភាពសង្គមកិច្ចនៅក្នុងខេត្តកំពង់ស្ពឺហាក់ដូចជាមានការប្រែប្រួលច្រើនលើគ្រប់វិស័យ តាមរយៈការយកចិត្តទុកដាក់របស់ខេត្តលើការអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងគុណភាពអប់រំ ការលើកកម្ពស់សេវាសុខាភិបាល សមភាពយេនឌ័រ និង ការអនុវត្តគោលនយោបាយប្រជាជន។ ទន្ទឹមនឹងការរីកចម្រើននេះដែរ រដ្ឋបាលខេត្តនៅតែមានបញ្ហាប្រឈម និងកង្វះខាតជាច្រើនដែលតម្រូវឱ្យមានការគាំទ្រពីគ្រប់មជ្ឈដ្ឋានអ្នកពាក់ព័ន្ធ ដើម្បីជំរុញវិស័យសំខាន់ៗក្នុងផ្នែកសង្គមកិច្ចដែលស្ដែងចេញនូវស្ថានភាពតាមវិស័យផ្សេងៗនាពេលបច្ចុប្បន្នតាមរយៈសូចនាករជាក់ស្ដែង ដែលប្រមូលបានទាក់ទងនឹងការកើនឡើង និងការថយចុះនូវតួលេខសំខាន់ៗ ព្រមទាំងបញ្ហាប្រឈមនានាដែលខេត្តមាន។

#### ១.២.២.១ វិស័យអប់រំ

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ មានទីតាំងនៅភូមិត្រពាំងលើក សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ សម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ មាន ៦០៣សាលា/កន្លែង ៤១៦២ថ្នាក់ សិស្សសរុប ១៧០,២២២នាក់ ស្រី ៨៣,៩៧១នាក់ បុគ្គលិកសរុប ៥២២២នាក់ ស្រី ២១១០នាក់ បុគ្គលិកបង្រៀន ៤,៤៦៥នាក់ ស្រី ១,៩៦៥នាក់ ក្នុងនោះមត្តេយ្យសិក្សាមាន ១៩៥សាលា/កន្លែង(មត្តេយ្យជាច់ដោយឡែក៣កន្លែង) ២៩៦ថ្នាក់ កុមារសរុប៩,៨៨៦នាក់ ស្រី ៤,៩៩២នាក់ បុគ្គលិកសរុប ២៨៣នាក់ ស្រី២៧៤នាក់ ។

សាលាបឋមសិក្សារដ្ឋមានចំនួន៣១៣ ។សាលាមិនគ្រប់កម្រិតមាន៣កន្លែង ។ សាលាកុមារមេត្រីកម្រិតមធ្យមនិងអភិវឌ្ឍន៍មានចំនួន២៨៧កើន ៩៤។ សាលាបឋមសិក្សាឯកជនមានចំនួន១៧។ ថ្នាក់រៀននៅសាលារដ្ឋចំនួន២ ៩០៣ និងបន្ទប់រៀន ២ ១៣០ ។ សិស្សបឋមសិក្សារដ្ឋចំនួន ១១០ ៨៧៤ នាក់ ស្រី ៥៣ ៥៧៣ នាក់ និងឯកជន ៤ ៤០៤នាក់ ស្រី២ ២៤៨ នាក់ ។ បុគ្គលិកបឋមសិក្សារដ្ឋចំនួន២,៦៨៧នាក់ ស្រី ១ ០៩៨នាក់ ក្នុងនោះបុគ្គលិកបង្រៀន ២ ២២៥នាក់ ស្រី ១ ០១៩នាក់ គ្រូបង្រៀនពីរពេល ៩៨៨នាក់ និងគ្រូបង្រៀនថ្នាក់គួប ៦៦នាក់ ។

គ្រឹះស្ថានមធ្យមសិក្សារដ្ឋចំនួនមាន ៩៥ ក្នុងនោះ អនុវិទ្យាល័យ ចំនួន ៧១ និងវិទ្យាល័យ២៤ (វិទ្យាល័យធនធាន១កន្លែង) ។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ទី១២ មាន២២ និងកម្រិតថ្នាក់ចាប់ពីថ្នាក់ទី១០ ដល់ទី១២មានពីរកន្លែង ។

គ្រឹះស្ថានសិក្សាឯកជនមាន ៨ ក្នុងនោះអនុវិទ្យាល័យ៣ និងវិទ្យាល័យ៥។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ទី១២មាន៥ ។

បុគ្គលិកអប់រំមាន២ ២៤៨នាក់ ស្រី៧២៧នាក់ក្នុងនោះមធ្យមសិក្សាបឋមភូមិ១ ៥១៣នាក់ ស្រី៥២៤នាក់។ បុគ្គលិកបង្រៀនមាន ១ ៩៧៦នាក់ ស្រី៦៨៥នាក់ ក្នុងនោះមធ្យមសិក្សាបឋមភូមិ១ ៤១៩នាក់ ស្រី៤៩៦នាក់ និងមធ្យមសិក្សាទុតិយភូមិ៥១៣នាក់ ស្រី១៦៥នាក់ ។

សិស្សមធ្យមសិក្សាបឋមភូមិសាធារណៈមាន ៣៤,០៣៤នាក់ ស្រី១៧ ៥០៥នាក់ ថយ១,០២៧នាក់ ស្រី ៧៤០ នាក់ និងមធ្យមសិក្សាបឋមភូមិឯកជនមានចំនួន ៧៤៣នាក់ ស្រី៣៨៣នាក់ ។

សិស្សមធ្យមសិក្សាទុតិភូមិសាធារណៈមាន ១៥,៤២៨នាក់ ស្រី៧,៨៧៨នាក់ កើន៦៣៧នាក់ ស្រី៤៩៦នាក់ និងសាលាឯកជនមាន ២០១នាក់ ស្រី១០៥នាក់ ។

**បញ្ហាប្រឈម រួមមាន៖**

ទោះបី មានវឌ្ឍនភាពកើនឡើងគួរឱ្យកត់សម្គាល់ ក៏នៅមានចំណុចមួយចំនួនត្រូវបន្តពង្រឹង និងកែលម្អថែមទៀត ដើម្បីសម្រេចគោលដៅនានាខាងមុខ។

- **ការអប់រំកុមារតូច** ៖ ការចូលរៀនរបស់កុមារតូចនៅតាមតំបន់ជនបទ កុមារងាយរងគ្រោះ និងកុមារដែលមានកម្រិតស្ថានភាពសេដ្ឋកិច្ច-សង្គមទាបមិនទាន់បានឆ្លើយតប។ ការរក្សាស្ថេរភាពថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះពុំទាន់បានល្អ ។
- **ការអប់រំបឋមសិក្សា** នាយកសាលាថ្មីពុំសូវយល់ច្បាស់ពីការងារដឹកនាំគ្រប់គ្រង កង្វះគ្រូបង្រៀន អត្រាត្រួតថ្នាក់ របស់សិស្សថ្នាក់ទី១មានកម្រិតខ្ពស់ និងបោះបង់ខ្ពស់នៅថ្នាក់ទី៦កង្វះសៀវភៅសិក្សាគោលអគារសិក្សាមួយចំនួនទ្រុឌទ្រោមពុំមានថវិកាជួសជុល និងកង្វះអគារសិក្សានៅតំបន់ជួបការលំបាកនិងបង្គន់អនាម័យនៅតាមសាលារៀនមួយចំនួន។
- **ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស** ៖ ការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិនិងមធ្យមសិក្សាទុតិយភូមិនៅមានកម្រិតខ្ពស់នៅឡើយ។ កង្វះសម្ភាររូបវ័ន្តតាមសាលារៀនជាកត្តាធ្វើឱ្យមានអត្រារួមនៃការសិក្សាចុះទាប ក៏ដូចជាកង្វះគ្រូបង្រៀន ជាពិសេស កង្វះគ្រូបង្រៀនឯកទេសតាមមុខវិជ្ជា ដូចជាមុខវិជ្ជាវិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា បច្ចេកវិទ្យា ព័ត៌មាននិងសារគមនាគមន៍ និងមុខវិជ្ជាភាសាបរទេស។
- **ការអប់រំក្រៅប្រព័ន្ធ** ៖ បុគ្គលិកខ្វះជំនាញ និងធនធានសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅមានកម្រិត មុខជំនាញមិនទាន់ឆ្លើយតបនឹងតម្រូវការអ្នកសិក្សា
- **ការអភិវឌ្ឍយុវជន** ៖ កម្មវិធីបណ្តុះបណ្តាលជំនាញទន់ ការអប់រំបណ្តុះបណ្តាលសហគ្រិនភាព ការបណ្តុះបណ្តាលជំនាញបច្ចេកទេសមិនទាន់មានសម្ភារបរិក្ខារគ្រប់គ្រាន់សម្រាប់គាំទ្រ។ ធនធានមនុស្ស និងមជ្ឈមណ្ឌលគ្រប់គ្រងយុវជនគ្របដណ្តប់ទូ នៅមានកម្រិត។ ក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជនមិនទាន់ដំណើរការសមស្រប និងខ្វះការគាំទ្រពីអ្នកពាក់ព័ន្ធ។
- **ការអប់រំកាយនិងកីឡា** ៖ ហេដ្ឋារចនាសម្ព័ន្ធកីឡានៅមានកម្រិត។ សមត្ថភាពមន្ត្រីអប់រំកាយនិងកីឡាកីឡាករគ្រូបង្វឹកនិងអាជ្ញាកណ្តាលនៅមានកម្រិតគ្រូបង្រៀនកម្រិតបឋមសិក្សាយល់ដឹងពីងារអប់រំកាយនិងកីឡា។

### ១.២.២.២ វិស័យសុខាភិបាល (ទិន្នន័យចាស់)

វិស័យសុខាភិបាល ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលដាក់ចេញជាគោលដៅអភិវឌ្ឍន៍ជាតិក្នុងការកាត់បន្ថយមរណភាពរបស់កុមារក្រោម ៥ឆ្នាំ ការលើកកម្ពស់សុខភាពមាតា និងការប្រយុទ្ធនឹងជំងឺអេដស៍ របេង គ្រុនចាញ់ និងជំងឺឆ្លងដទៃទៀត។

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍជាតិ នឹងចូលរួមចំណែកកែលម្អរសូចនាករសុខភាពសំខាន់ៗមន្ទីរសុខាភិបាល ដែលជាអង្គភាពប្រតិបត្តិបានអនុវត្តតាមផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយផ្តោតជាពិសេសទៅលើកម្មវិធីចម្បងៗទាំងបួនរួមមាន ៖ **កម្មវិធីសុខភាពបន្តពូជមាតា-ទារក-កុមារអាហារូបត្ថម្ភ កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លងកម្មវិធីប្រយុទ្ធនឹងជំងឺមិនឆ្លង និងកម្មវិធីពង្រឹងប្រព័ន្ធសុខាភិបាល។**

បច្ចុប្បន្នវិស័យសុខាភិបាលមានការរីកចម្រើនគួរជាទីមោទន ដោយមន្ទីរសុខាភិបាលខេត្តអនុវត្តតាមផែនការគ្របដណ្តប់របស់ខ្លួនបង្កើតបានហេដ្ឋារចនាសម្ព័ន្ធដូចជា ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន ០៤ កន្លែង មន្ទីរពេទ្យបង្អែកចំនួន ០៤កន្លែង មណ្ឌលសុខភាពចំនួន ៥៩កន្លែង ប៉ុស្តិ៍សុខភាពចំនួន ០៣កន្លែង និងមានមន្ត្រីសុខាភិបាលជាវេជ្ជបណ្ឌិត គ្រូពេទ្យ គិលានុប្បដ្ឋាកយិកា និងឆ្មបសម្រាប់បម្រើសេវាជូនប្រជាពលរដ្ឋ ដែលមានតម្រូវការផ្នែកព្យាបាល និងថែទាំសុខភាពនៅតាមសេវាសុខភាពនានានៅទូទាំងខេត្តកំពង់ស្ពឺ។ ជាមួយនេះដែរ មន្ទីរសុខាភិបាលមានកិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ និងគ្រប់ដៃគូសុខាភិបាលទាំងអស់ ដើម្បីសហការក្នុងការអនុវត្តទៅតាមយុទ្ធសាស្ត្រ ជាតិនៃកម្មវិធីទាំងបួនរួមមាន សុខភាពមាតា-ទារក-កុមារអាហារូបត្ថម្ភ ការប្រយុទ្ធនឹងជំងឺឆ្លង-ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត និងកម្មវិធីពង្រឹងប្រព័ន្ធសុខាភិបាល ដើម្បីឈានទៅសម្រេចផែនការយុទ្ធសាស្ត្រជាតិឆ្នាំ២០១៦ ដល់ ២០២០។ ទន្ទឹមនឹងការរីកចម្រើននេះ ក៏នៅមានបញ្ហាមួយចំនួនដូចជា ហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាលរួមមាន ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពដែលពុំទាន់គ្របដណ្តប់ឱ្យសមស្របទៅនឹងចំនួនប្រជាជនដែលកំពុងមានការកើនឡើង។

## វឌ្ឍនភាពកម្មវិធីសុខភាពបន្តពូជមាតា ទារក កុមារ អាហារូបត្ថម្ភ

### ក.អាហារូបត្ថម្ភៈ (ទិន្នន័យចាស់)

ដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភនៅខេត្តកំពង់ស្ពឺឱ្យបានល្អ ក្នុងគោលបំណងកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភចំពោះកុមារក្រោម៥ឆ្នាំនិងបញ្ហាកង្វះមីក្រូសារជាតិចំពោះស្ត្រីនិងកុមារ មន្ទីរសុខាភិបាលខេត្តបានអនុវត្តនូវអន្តរាគមន៍មួយចំនួនមានដូចជា សហគមន៍ស្រឡាញ់ទារក យុទ្ធនាការអាហារបន្ថែម មន្ទីរពេទ្យស្រឡាញ់ទារក ការផ្តល់បន្ថែមមីក្រូសារជាតិដល់ស្ត្រីនិងកុមារ ការថែទាំព្យាបាលបញ្ហាកង្វះអាហារូបត្ថម្ភទាំងនៅមន្ទីរពេទ្យ និងនៅមណ្ឌលសុខភាព។

### ខ.ការថែទាំសុខភាពមាតា និងទារក (ទិន្នន័យចាស់)

- ភាគរយស្ត្រីដែលសម្រាលកូននៅមូលដ្ឋានសុខាភិបាលប្រមាណ ៥១% នៅឆ្នាំ២០១៦ ធៀបទៅនឹងគោលដៅ ៥៦% ដែលអាចបណ្តាលមកពីការប្រមូលរបាយការណ៍ពីសេវាឯកជនមិនបានអស់ និង

ចំនួនស្ត្រីប៉ាន់ស្មានរំពឹងទុកថាសម្រាលនិងមានផ្ទៃពោះមានចំនួនច្រើនជាងជាក់ស្តែង ម្យ៉ាងទៀត ចំនួនស្ត្រីវ័យបន្តពូជដែលបានទទួលសេវាពន្យាកំណើតមានការកើនឡើងច្រើន។

- នៅក្នុងឆ្នាំ២០១៣ អត្រាមរណភាពមាតាក្រោយពេលសម្រាលកូន ( ទិន្នន័យក្រសួងសុខាភិបាល ) ១៧០លើ១០០០០០កំណើត។ ជាគោលដៅរបស់ក្រសួងសុខាភិបាលបានកំណត់ថានៅឆ្នាំ២០២០ អត្រាមរណភាពមាតានេះគឺឱ្យនៅត្រឹម ១៣០លើ១០០០០០កំណើត។ អត្រាមរណភាពនេះបើពិនិត្យជារួមបណ្តាលមកពី (១) ភាពទ្រុឌទ្រោមសុខភាពពេលមានផ្ទៃពោះ ដោយសារការធ្វើការងារធ្ងន់ និងកង្វះអាហារូបត្ថម្ភ (២) ការសម្រាលកូនដោយមានការឆ្លងរោគ (៣) ការយឺតយ៉ាវក្នុងការសម្រេចចិត្តបញ្ជូនទៅរកសេវាសម្រាលដែលមានសុវត្ថិភាព (៤) ការប្រកាន់យកនូវទម្លាប់ចាស់បុរាណមិនសមស្រប (៥) នៅមានតិចតួចនៅឡើយការសម្រាលកូនដោយឆ្មបបុរាណ ដែលកត្តានេះគួរមានការយកចិត្តទុកដាក់បន្ថែមទៀត (៦) ការមិនយល់ដឹងពីវិធីថែទាំខ្លួនក្រោយពេលសម្រាល។ល។
- ចំពោះអត្រាមរណភាពទារកអាយុ (០-១ខែ)ក្នុង១,០០០កំណើតរស់ បច្ចុប្បន្នតាមទិន្នន័យរបស់ក្រសួងសុខាភិបាលគឺ ១៨លើ១០០០កំណើតរស់។ ជាគោលដៅរបស់ក្រសួងសុខាភិបាលបានកំណត់ថានៅឆ្នាំ២០២០ អត្រាមរណភាពនេះគឺឱ្យនៅត្រឹម ១៤លើ១០០០កំណើតរស់។

## គ-ការចាក់ថ្នាំបង្ការជំងឺ ១១មុខដល់កុមារ (ទិន្នន័យចាស់)

អន្តរាគមន៍ដែលបានអនុវត្តនៅក្នុងផ្នែកសុខភាពកុមារបានផ្តោតលើសកម្មភាពចម្បង ដូចជា៖

- សមាហរណកម្មការអនុវត្តយុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការជំងឺ ១១មុខដល់កុមារនៅមណ្ឌលសុខភាព និងចុះផ្ទាល់ដល់មូលដ្ឋាន
- ពង្រឹងការតាមដានជំងឺដែលអាចការពារបានដោយវ៉ាក់សាំង
- ជាលទ្ធផលនៅក្នុងឆ្នាំ២០១៦ កុមារអាយុក្រោម ១ឆ្នាំបានទទួលវ៉ាក់សាំងការពារជំងឺ ១១មុខ ស្មើនឹង ៧៨%។ ចំនួននេះនៅមានកម្រិតមធ្យមនៅឡើយបើធៀបទៅនឹងគោលដៅ ៩៦%។ មានមូលហេតុមួយចំនួនដែលធ្វើឱ្យសម្រេចមិនបាននូវលទ្ធផលនេះ គឺបណ្តាលមកពីកត្តា ដូចជា៖
  - ប្រជាពលរដ្ឋខ្លះមានទីលំនៅឆ្ងាយពីមណ្ឌលសុខភាព
  - មាតាបិតាខ្លះគ្មានឆន្ទៈក្នុងការយកកូនទៅទទួលថ្នាំបង្ការ និងខ្លះទៀតមានការស្ទាក់ស្ទើរក្នុងការឱ្យកូនទទួលថ្នាំបង្ការ
  - អ្នកស្ម័គ្រចិត្តភូមិមិនសូវទទួលបានការលើកទឹកចិត្ត ដូចជាប្រាក់ឧបត្ថម្ភ និងមធ្យោបាយជាដើម ដែលនាំឱ្យការប្រមូលផ្តុំកុមារមានការលំបាក
  - បុគ្គលិកពេទ្យទទួលបានថវិកាមិនគ្រប់គ្រាន់ និងមិនទៀងទាត់ និងខ្វះមធ្យោបាយធ្វើដំណើរ
  - បញ្ហាចំណាកស្រុក និងកត្តាភូមិសាស្ត្ររួមផ្សំ
  - ចំនួនកុមារដែលធ្វើការប៉ាន់ស្មានមានចំនួនច្រើនជាងចំនួនកុមារជាក់ស្តែង

- ទាក់ទងនឹងការកង្វះអាហារូបត្ថម្ភចំពោះកុមារមួយចំនួនគឺបណ្តាលមកពីម្តាយមួយចំនួននៅពេលបច្ចុប្បន្ននេះបានស្វែងរកការងារធ្វើនៅតាមរោងចក្រសហគ្រាស និងនៅតាមកន្លែងផ្សេងៗទៀតដោយទុកកូនតូចៗឱ្យនៅក្រោមការគ្រប់គ្រង ថែទាំ និងផ្តត់ផ្គង់ចំណីអាហារជាមួយជីដូនជីតា ចាស់ៗដែលនេះជាបញ្ហានៃការថែទាំសុខភាពកុមារមិនបានដិតដល់ និងនាំដល់កង្វះអាហារូបត្ថម្ភចំពោះកុមារមួយចំនួន។

## ឃ-ការផ្តល់វ៉ាក់សាំងដល់ស្ត្រីក្នុងវ័យបន្តពូជ៖ (ទិន្នន័យចាស់)

បច្ចុប្បន្នក្រសួងសុខាភិបាលបាននិងកំពុងជំរុញយុទ្ធនាការផ្តល់បន្ថែមថ្នាំបង្ការជំងឺតេតាណូស ដល់ស្ត្រីក្នុងវ័យបន្តពូជអាយុ ១៥ ដល់ ៤៩ឆ្នាំ។ ជាលទ្ធផល ៤៨%នៃស្ត្រីក្នុងវ័យបន្តពូជមានផ្ទៃពោះទទួលបានវ៉ាក់សាំង។ អត្រានេះនៅមានកម្រិតបើធៀបទៅនឹងផែនការ ៧៨%។

## កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លង៖

### ១. កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ (ទិន្នន័យចាស់)

ក. អ្នកជំងឺអេដស៍បាននិងកំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំនួន ១,៨៤៦នាក់ ក្នុងនោះមនុស្សពេញវ័យ ១,៥៩៣នាក់ និងកុមារចំនួន ២៥៣នាក់។ អត្រាអ្នកផ្ទុកមេរោគអេដស៍ដែលកំពុងប្រើឱសថប្រឆាំងមេរោគអេដស៍បាននៅរស់រានក្រោយការព្យាបាលរយៈពេល ១២ខែ រក្សាបានលើសពី ៩០%។

ខ. មណ្ឌលផ្តល់ប្រឹក្សាធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់៖
បច្ចុប្បន្នចំនួនមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ (VCCT) មានចំនួន ០៣កន្លែង និងមណ្ឌលសុខភាពធ្វើតេស្តរហ័សចុងម្រាមដៃ (HTC) ចំនួន ៥៤កន្លែង។

គ. គោលដៅកាត់បន្ថយជំងឺអេដស៍៖
នៅឆ្នាំ២០២០ ជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលគឺត្រូវសម្រេចឱ្យបានគោលដៅ ៩០,៩០,៩០ (៩០% ទី១. គ្រប់អ្នកដែលប្រឈមទៅនឹងបញ្ហាអេដស៍ទាំងអស់ត្រូវបានពិនិត្យឈាមរកមេរោគអេដស៍។ ៩០%ទី២. គឺអ្នកដែលបានពិនិត្យឈាមមានផ្ទុកមេរោគអេដស៍ត្រូវបានទទួលឱសថប្រឆាំងមេរោគអេដស៍ និង៩០%ទី៣. គឺអ្នកជំងឺអេដស៍ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ ទាំងអស់ត្រូវបានពិនិត្យបន្ទុកមេរោគឱ្យនៅកម្រិតទាបបំផុត)។

### ២.កម្មវិធីប្រយុទ្ធនឹងជំងឺរបេង៖ (ទិន្នន័យចាស់)

**ក.ការព្យាបាលជំងឺរបេង៖**

- អត្រាព្យាបាលជំងឺរបេងនៅមូលដ្ឋានសុខាភិបាលសាធារណៈជាសះស្បើយលើសផែនការ គឺស្មើនឹង ៩០% បើប្រៀបធៀបនឹងផែនការគឺ ៨៥%

- បង្កើនអត្រាព្យាបាលជាសះស្បើយជំងឺរបេងនៅសហគមន៍លើសពី៨២%។

**ខ.គោលដៅកាត់បន្ថយជំងឺរបេង៖**

- អត្រាអ្នកជំងឺរបេងគ្រប់សណ្ឋានសរុបបានថយចុះពីកម្រិត ១៦៧០លើ១០០០០០នាក់ នៅឆ្នាំ ១៩៩៩ មកនៅត្រឹម ៧៦៤លើ១០០០០០នាក់ នៅឆ្នាំ២០១២ ស្មើនឹង៥៤% បើធៀបទៅនឹងផែនការ៥០% គឺសម្រេចបានមុនគោលដៅសហសវត្សរ៍ឆ្នាំ២០១៥
- អត្រាស្លាប់អ្នកជំងឺរបេងបានកាត់បន្ថយពី ១៥៧លើ១០០០០០នាក់ នៅឆ្នាំ១៩៩៩ មកនៅត្រឹម ៦៣លើ១០០០០០នាក់ នៅឆ្នាំ២០១២ ស្មើនឹង៦០% បើធៀបទៅនឹងផែនការ៥០% គឺសម្រេចបានមុនគោលដៅសហសវត្សរ៍ឆ្នាំ២០១៥។

### ៣. កម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់៖

- អត្រាគ្រោះថ្នាក់ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរបានថយចុះពី ០៦ករណី មកនៅត្រឹម ០២ករណី បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ (ចំពោះករណីស្លាប់គ្មាន)។
- គោលដៅរបស់ក្រសួងសុខាភិបាល គឺលុបបំបាត់ឱ្យអស់ជំងឺគ្រុនចាញ់នៅឆ្នាំ២០២៥។

### ៤. កម្មវិធីប្រយុទ្ធនឹងគ្រុនឈាម៖

- ករណីជំងឺគ្រុនឈាមមកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យមានការថយចុះពី ១២ករណី មកនៅ ០៣ករណី បើធៀបទៅនឹងរយៈពេលដូចគ្នានៅក្នុងឆ្នាំ២០១៦ (ករណីស្លាប់គ្មាន)។

## កម្មវិធីប្រយុទ្ធនឹងជំងឺមិនឆ្លង៖ (ទិន្នន័យចាស់)

សកម្មភាពប្រយុទ្ធនឹងជំងឺមិនឆ្លងដែលគួរឱ្យកត់សម្គាល់មានការថែទាំភ្នែក ការបង្ការភាពងងឹតភ្នែក ជំងឺបេះដូងនិងសរសៃឈាម ទឹកនោមផ្អែម គ្រោះថ្នាក់ចរាចរណ៍ និងរបួស ដែលចាំបាច់ត្រូវយកចិត្តទុកដាក់អប់រំផ្សព្វផ្សាយផ្តល់ចំណេះដឹងជាសាធារណជូនដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងពីសុខភាពនិងការបង្ការខ្លួន។

## កម្មវិធីពង្រឹងប្រព័ន្ធសុខាភិបាល៖

### ការងារគ្រប់គ្រងបុគ្គលិក៖ (ទិន្នន័យចាស់)

យោងតាមការណែនាំរបស់ក្រសួងសុខាភិបាល មន្ទីរសុខាភិបាលខេត្ត បានរៀបចំកែសម្រួលបុគ្គលិកបម្រើការងារនៅតាមថ្នាក់មានដូចជា នៅថ្នាក់ខេត្តចំនួន ១០% ថ្នាក់ស្រុកប្រតិបត្តិចំនួន ៦% នៅមន្ទីរពេទ្យបង្អែកទាំងបួនចំនួន ២៩% និងនៅថ្នាក់មណ្ឌលសុខភាពចំនួន ៥៥%។ ដោយឡែកការពង្រាយបុគ្គលិកឆ្មបនៅតាមមណ្ឌលសុខភាពមានការកើនឡើងដល់ ៥៤/៥៥មណ្ឌលសុខភាព ស្មើនឹង៩៩% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦។ បុគ្គលិកសរុបចំនួន ៨៣៩នាក់ ក្នុងនោះមានវេជ្ជបណ្ឌិត ៨៣នាក់ គ្រូពេទ្យមធ្យម ១៦នាក់ ឱសថការីឧត្តមនិងមធ្យម ១៥នាក់ ទន្តបណ្ឌិត-ទន្តពេទ្យ ០៤នាក់ បរិញ្ញាបត្រឆ្មប ១០នាក់ ឆ្មបមធ្យម ១៣៩នាក់ ឆ្មបបឋម ១១៨នាក់ បរិញ្ញាបត្រគិលានុប្បដ្ឋាកយិកា ០៦នាក់ គិលានុប្បដ្ឋាកយិកាមធ្យម ១៩៣នាក់ គិលានុប្បដ្ឋា

កយិកាបឋម ២០០នាក់ បច្ចេកទេសមន្ទីរពិសោធន៍ ២៣នាក់ ព្យាបាលដោយចលនា ០៧នាក់ គណនេយ្យឧត្តម ០៦នាក់ ព័ត៌មានវិទ្យា០៣នាក់ វិទ្យុសាស្ត្រ ០៣នាក់ និងបុគ្គលិកផ្សេងៗទៀតចំនួន០៨នាក់។

### គោលដៅអទិភាពនៃមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺឆ្នាំ ២០១៦ ដល់ ២០២០ (ទិន្នន័យចាស់)

- បន្តយុទ្ធសាស្ត្រចតុកោណ និងសមាហរណកម្មអាស៊ាន
- បន្តពង្រឹង និងលើកកម្ពស់កម្មវិធីចម្បងៗទាំង ៥
- លើកកម្ពស់ការងារសុខភាពផ្លូវចិត្ត និងការផ្តាច់គ្រឿងញៀន
- សុខភាពអនាម័យសាធារណៈ ដូចជាការងារសេវាឯកជនស្របច្បាប់ ច្បាប់ជក់បារី ជាដើម ។ល។
- ធានាឱ្យបានសេវាសុខភាពសាធារណៈ មានប្រសិទ្ធភាព ស័ក្តសិទ្ធិភាព កាត់បន្ថយការចំណាយប្រាក់ហោប៉ៅប្រជាជន និង តបតាមតម្រូវការឆាប់រហ័សដោយអនុវត្តផែនការសកម្មភាព៖
  - ការងារផែនការ និងសកម្មភាពតាមកម្មវិធី
  - ការពង្រឹងមូលដ្ឋានសុខាភិបាល
  - បុគ្គលិក៖ ក្រមសីលធម៌ និងបច្ចេកទេសផ្តល់សេវា
  - មូលនិធិសមធម៌ និងធានារ៉ាប់រងសុខភាពបុគ្គលិកមន្ត្រីរាជការនិងហេដ្ឋារចនាសម្ព័ន្ធ។

#### ១.២.២.៣ វិស័យយេនឌ័រ

បច្ចុប្បន្ននេះ សមាសភាពក្រុមប្រឹក្សាខេត្ត ក្រុង ស្រុកជាស្ត្រីមានចំនួន ១៦ រូប ក្នុងចំណោមសមាជិកសមាជិកាចំនួន ១៥៤ រូប ក្នុងនោះក្រុមប្រឹក្សាខេត្ត ០២ រូប ក្រុងច្បារមន ០២ រូប ស្រុកសំរោងទង ០៣ រូប ស្រុកបសេដ្ឋ ០២ រូប ស្រុកគងពិសី ០២ រូប ស្រុកឧដុង្គ ០២ រូប ស្រុកថ្ពង ០២ រូប ស្រុកឱរ៉ាល់ ០១ រូប និងស្រុកភ្នំស្រួច០១ ។ តួនាទីរបស់ស្ត្រីក្នុងគណៈអភិបាលខេត្ត ក្រុង និងស្រុកមានចំនួន ០៨ រូប ក្នុងចំណោម ៤៥ រូប គិតមកដល់ឆ្នាំ ២០១៩ នេះ។ ចំនួនស្ត្រីជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់មាន ៦៨ រូបក្នុងចំណោមសមាជិកសមាជិកាសរុប ៦០៩ នាក់ ក្នុងនោះស្ត្រីជាមេឃុំមាន ០៥ រូប ជំទប់ទី ០១ មាន ១០ រូប និងជំទប់ទី២ មាន ១៣ រូប(អាណត្តិទី ៣) និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មាន ២០ នាក់ ក្រៅពីក្រុមប្រឹក្សាឃុំ សង្កាត់ ។ ចំនួនថ្នាក់ដឹកនាំភូមិជាស្ត្រីមានចំនួន ១១៧៩ នាក់ ក្នុងចំណោមថ្នាក់ដឹកនាំភូមិចំនួន ៤០៤៧ នាក់ ដែលក្នុងនោះមេភូមិជាស្ត្រីមានចំនួន ៤២ នាក់ អនុភូមិជាស្ត្រីមាន ១៣០ នាក់និងជំនួយការភូមិជាស្ត្រីមានចំនួន ១០០៧ នាក់ ទិន្នន័យខាងលើនេះបានបង្ហាញថា ចំនួនស្ត្រីដែលចូលរួមក្នុងការសម្រេចចិត្តមានចំនួនតិចនៅឡើយ បើប្រៀបធៀបនឹងចំនួនបុរស។

អនុវត្តតាមអនុសាសន៍ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំខេត្ត ដែលមានមន្ទីរកិច្ចការនារី នឹងមន្ទីរនានា ដែលមានការពាក់ព័ន្ធជាសេនាធិការបានយកចិត្តទុកដាក់លើកកម្ពស់សិទ្ធិរបស់ស្ត្រីតាមរយៈការតែង

តាំង ថ្នាក់ដឹកនាំស្ត្រីនៅតាមមន្ទីរ និងអង្គភាពនានារបស់ខេត្តដូចជា ស្ត្រីក្នុងក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក នឹងក្រុមប្រឹក្សាឃុំ សង្កាត់ គណៈអភិបាលខេត្ត គណៈអភិបាលក្រុង ស្រុក ប្រធាន នឹងអនុប្រធានមន្ទីរជាដើម ដើម្បីផ្តល់ឱកាសឲ្យស្ត្រីបានបញ្ចេញសមត្ថភាពរបស់ខ្លួនក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការធ្វើសេចក្តីសម្រេចចិត្ត នឹងការអនុវត្តសេចក្តីសម្រេចចិត្តលើគ្រប់សកម្មភាព នឹងវិស័យរបស់ខេត្ត។ ជាពិសេសស្ត្រីថ្នាក់ដឹងនាំអាចធ្វើជាគំរូដល់ស្ត្រីជំនាន់ក្រោយនឹងជួយជំរុញលើកទឹកចិត្តស្ត្រីឲ្យមានភាពក្លាហានហ៊ានបញ្ចេញសមត្ថភាពដូចបុរសដែរ។ លើសពីនេះ យើងសង្កេតឃើញថាចំនួនមន្ត្រីរាជការស៊ីវិលនៅតាមមន្ទីរ នឹងអង្គភាពជាស្ត្រីមានការកើនឡើងគួរឲ្យកត់សំគាល់ ដោយសារមានការជំរុញ នឹងការជួយជ្រោមជ្រែងផ្តល់ថវិកាពី គ.ជ.អ.ប កម្មវិធីសិទ្ធិកុមារ អង្គការជាតិ នឹងអន្តរជាតិនានា ខេត្តបានធ្វើការចុះអប់រំ ផ្សព្វផ្សាយពីបញ្ហាយេនឌ័រទៅដល់ប្រជាពលរដ្ឋចាប់ពីទីក្រុងដល់សហគមន៍ជនបទដែលធ្វើឲ្យយើងបានទទួលស្គាល់ថា គំលាតរវាងស្ថានភាពស្ត្រី នឹងបុរសត្រូវបានកាត់បន្ថយក្នុងកម្រិតមួយដ៏ល្អ ប៉ុន្តែពុំមានសូចនាករ នឹងតួលេខច្បាស់លាស់នៅឡើយ។

មានបុរសជាច្រើនបានទទួលស្គាល់ពីតម្លៃស្ត្រីជាមេផ្ទះ នឹងបានចាត់ទុកថា ការងារក្នុងផ្ទះ នឹងការមើលថែទាំកូនជាការងាររួមដោយមិនប្រកាន់ឡើយ ។ ប៉ុន្តែក៏មានគ្រួសារខ្លះប្តីនៅប្រកាន់គំនិតចាស់គំរិលនៅមានការបែងចែកការងារខាងក្រៅ នឹងខាងក្នុងផ្ទះ ដែលពេលខ្លះបង្កឲ្យមានការឈ្លោះទាស់ទែងគ្នានាំឲ្យកើតមានអំពើហិង្សាក្នុងគ្រួសារ ។ ចំនួនសិស្សស្រីនៅតាមភូមិសិក្សាក៏មានការកើនឡើងផងដែរ មានសិស្សស្រីជាច្រើនត្រូវបានចាត់តាំងធ្វើជាប្រធានថ្នាក់ នឹងរៀនសូត្របានទទួលចំណាត់ថ្នាក់ល្អក្នុងការសិក្សាទៀតផង ។ ទន្ទឹមនឹងនេះក៏មានបញ្ហាប្រឈមខ្លះៗ ដូចជាសិស្សស្រីក្រីក្រនៅតាមជនបទមួយចំនួនត្រូវបានឪពុកម្តាយបង្ខំឲ្យឈប់រៀនដើម្បីនៅផ្ទះដាំបាយ មើលប្អូនតូច ទៅធ្វើការជាកម្មការនីរោងចក្រ ឬ សំណង់ធ្វើចំណាកស្រុករហូតមានស្ត្រីវ័យក្មេងខ្លះចាញ់បោកគេធ្លាក់ខ្លួនប្រកបរបរពេស្យាចារក៏មាន ។

ជាទូទៅចំនួនស្ត្រីមានចំណេះដឹង មានតិចជាងបុរសដោយឱកាសនៃការសិក្សាមានតិចជាងបុរសជាហេតុធ្វើឲ្យសមត្ថភាពបំពេញការងារទាំងឡាយនៅតាមសហគមន៍ឬ នៅតាមស្ថានភាពរដ្ឋាភិបាលមានចំនួនតិចជាងបុរសផងដែរ។ ប៉ុន្តែកន្លងមកខេត្តបានយកចិត្តទុកដាក់ក្នុងការបំពាក់បំប៉ន សមត្ថភាពដល់ស្ត្រីនៅតាមសហគមន៍បានច្រើនបង្គួរផងដែរ ដែលអាចឲ្យស្ត្រីមួយចំនួនបានចូលប្រឡូកក្នុងការងារសហគមន៍ក៏ដូចជាក្នុងជួរក្រុមប្រឹក្សាឃុំ សង្កាត់ នឹងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ ដែលជាចំណុចផ្តើមដ៏ល្អក្នុងការពង្រឹងសមត្ថភាពរបស់ស្ត្រី នឹងជំរុញការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច នឹងវប្បធម៌បានយ៉ាងសកម្ម ។

ម្យ៉ាងទៀត យើងសង្កេតឃើញមានស្ត្រីជាច្រើនបានដើរតួយ៉ាងសំខាន់ក្នុងការរកចំណូលសម្រាប់គ្រួសារដោយបានទៅប្រកបមុខរបរក្រៅពីមេផ្ទះ ដូចជាកម្មកការនីរោងចក្រ កម្មករសំណង់ បុគ្គលិកក្រុមហ៊ុននានា ចិញ្ចឹមជ្រូក មាន់ជា

កសិដ្ឋានខ្នាតតូច ជាអាជីវករ នឹងឆ្លៀតពេលជាមេផ្ទះ មានស្ត្រីមួយចំនួនបានរៀបចំជាក្រុមផលិតនៅសហគមន៍ (ស្រុកបសេដ្ឋ) ដើម្បីត្បាញក្រម៉ាសម្រាប់លក់បោះដុំ លក់រាយ នឹងទទួលត្បាញឲ្យមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដែលអាចទទួលកម្រៃចិញ្ចឹមជីវិតផ្ទាល់ខ្លួនរបស់ពួកគេ នឹងគ្រួសារទាំងមូលទៀតផង ។

### ១.២.២.៤ ស្ថានភាពក្រីក្រ (ទិន្នន័យចាស់)

**លំដាប់ថ្នាក់ពិន្ទុភាពក្រីក្រ**




*សម្គាល់ ៖ អត្រាភាពក្រីក្រនៅថ្នាក់ក្រោមជាតិត្រូវបានផលិតចេញពីសូចនាករជាច្រើន តែមិនបានបង្ហាញពីសមាសភាគលម្អិតនៅទីនេះទេ វាជាព័ត៌មានសម្រាប់ឱ្យឃុំដឹងពីពិន្ទុ ឬអត្រាភាពក្រីក្រមានកំរឹតត្រឹមណាតែប៉ុណ្ណោះ។*

### ២.២.៥ វិស័យសាសនា (ទិន្នន័យចាស់)

- នៅទូទាំងខេត្តកំពង់ស្ពឺមានវត្តចំនួន ២៨៨វត្ត ក្នុងនោះមហានិកាយមាន ២៧១វត្ត និងធម្មយុត្តិកនិកាយមាន ១៧វត្ត អាស្រមវិបស្សនាមាន ២២កន្លែង មជ្ឈមណ្ឌលមាន ០១កន្លែង ។
- ព្រះសង្ឃចំនួន ៣,៧៨៦អង្គ ភិក្ខុចំនួន ១,១១២អង្គ សាមណេរចំនួន ២,៦៧៤អង្គ អាចារ្យចំនួន ៨៣២នាក់ គណៈកម្មការចំនួន ១,៩៣៤នាក់ និងចំនួនជនស្នាក់នៅក្នុងវត្ត អាចារ្យ២៦នាក់ គណៈកម្មការ ០៨នាក់ តាជីចំនួន ១៤៦នាក់ ដូនជីចំនួន ៥៥៩នាក់ សិស្សចំនួន ២៣៩នាក់ ក្មេងចំនួន ១៩២នាក់។
- ឥស្លាមសាសនាមាន ០៣កន្លែង មានបរិស័ទចំនួន ៣៩០នាក់ ក្នុងនោះស្រីចំនួន ២១៤នាក់ និងប្រុសចំនួន ១៧៦នាក់។

- ព្រះវិហារចិននិកាយមហាយានមាន ០៥កន្លែង បរិស័ទចំនួន ២៩៧នាក់ ក្នុងនោះស្រី ១៨០នាក់ ប្រុស ១១៧នាក់ មានសាលារៀន១ខ្នង ស្មើនឹង ៦ថ្នាក់ មានសិស្សសរុបចំនួន ៣៣០នាក់។
- សហគមន៍បាហៃមាន ០១កន្លែង បរិស័ទចំនួន ២៩៣នាក់ ក្នុងនោះស្រី៦០នាក់ ប្រុស២៣៣នាក់។
- សាសនាគ្រីស្តមានព្រះវិហារ ៨០កន្លែង មានស្នាក់ការថ្វាយបង្គំ ៣៤កន្លែង ចំនួនបរិស័ទសរុប ៥,២១០នាក់ ក្នុងនោះស្រីចំនួន ២,៧៥១នាក់ ប្រុសចំនួន ២,៤៥៩នាក់។
- សាលាពុទ្ធិកអនុវិទ្យាល័យមាន ០១សាលា សមណសិស្សសរុប ១៩៦អង្គ/នាក់ មាន ០៦បន្ទប់ក្នុងនោះដែរ គ្រូក្របខណ្ឌមាន ០១រូប គ្រូកិច្ចសន្យាមាន ១៥រូប គ្រូជួលមាន ២១រូប សរុបចំនួនគ្រូមាន ៣៧រូប។

  សិស្សសរុប ១១៦៣អង្គ/នាក់ មាន៣កម្រិត មាន៧៣បន្ទប់គ្រូក្របខណ្ឌមាន ០៨អង្គ/នាក់ គ្រូកិច្ចសន្យាមាន ៨០អង្គ/នាក់ គ្រូជួលមាន ៣៧អង្គ/នាក់ គ្រូស្ម័គ្រចិត្ត ៤០អង្គ/នាក់ សរុបមាន១៦៥រូប។
- សាលាធម្មវិន័យមាន ៣៨សាលា សមណសិស្សចំនួន ៦០៤អង្គ/នាក់ មាន៣កម្រិត មាន ៣៨បន្ទប់ គ្រូក្របខណ្ឌមាន ០០អង្គ/នាក់ គ្រូកិច្ចសន្យាមាន ១០អង្គ/នាក់ គ្រូជួលមាន ៣៩អង្គ/នាក់ គ្រូស្ម័គ្រចិត្តមាន ១៥អង្គ/នាក់ សរុបមានចំនួន ៦៤អង្គ/នាក់។
- សាសនបណ្ណាល័យមានសៀវភៅចំនួន ៤៣មុខ ហើយមានសៀវភៅ សរុបចំនួន ១,៧៣៣ក្បាល។

## ២. ស្ថានភាពបុគ្គលិក (ទិន្នន័យចាស់)

- មន្ទីរធម្មការ និងសាសនាមាន ក្របខ័ណ្ឌមានចំនួន ៦៩នាក់ ស្រីចំនួន ១៦នាក់ ក្នុងនោះមាន
  - មន្ត្រីចំនួន ៥៤នាក់ ក្នុងនោះមានស្រីចំនួន ១៥នាក់
  - គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ០១នាក់
  - គ្រូបង្រៀនកម្រិតបឋមមានចំនួន ១៤នាក់ ក្នុងនោះមានស្រីចំនួន ០១នាក់
  - ក្របខ័ណ្ឌរួមមាន៖
    - ក្របខ័ណ្ឌ<ក> ចំនួន ១៥នាក់ ស្រីចំនួន ០៦នាក់
    - ក្របខ័ណ្ឌ<ខ> ចំនួន ១៥នាក់ ស្រីចំនួន ០៣នាក់
    - ក្របខ័ណ្ឌ<គ> ចំនួន ៣៩នាក់ ស្រីចំនួន ០៧នាក់
- កិច្ចសន្យាមានសរុបចំនួន ១៣០អង្គ/នាក់ ស្រី២១នាក់ ក្នុងនោះ
  - មន្ត្រីជាប់កិច្ចសន្យាមានចំនួន ២៧អង្គ/នាក់ ស្រី ១៥នាក់
  - គ្រូជាប់កិច្ចសន្យាមានចំនួន ១០៣អង្គ/នាក់ ស្រី ០៦នាក់

ដើម្បីសម្រេចគោលបំណងពង្រឹងតម្លៃគ្រួសារ និងសាសនាក្នុងគោលដៅលើកកម្ពស់សីលធម៌រស់នៅក្នុងសង្គម មន្ទីរធម្មការសាសនាខេត្តកំពង់ស្ពឺត្រូវអនុវត្តន៍ការងារដូចជា៖

- ពង្រឹងតួនាទី ភារកិច្ច និងសមត្ថភាពរបស់មន្ត្រីក្នុងការអនុវត្តន៍ការងារឱ្យបានល្អ
- ពង្រឹងតួនាទី ភារកិច្ចរបស់មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ ថេរសភា និងថៅអធិការវត្ត
- ធ្វើការបោះឆ្នោតរៀបចំអាចារ្យគណៈកម្មការ និងស្នើសុំបន្តអាណត្តិ

- រៀបចំសមាគមអាចារ្យខ្មែរ និងវគ្គតម្រង់ទិសតួនាទីអាចារ្យ-អាចារិនី
- បន្តចុះបញ្ជីសាសនា និងធ្វើការត្រួតពិនិត្យតាមដានសកម្មភាពសាសនានានាដែលប្រតិបត្តិក្នុងខេត្ត
- តាមដានរាល់ការផ្សព្វផ្សាយពាហិរសាសនាតាមភូមិ ទីផ្សារ និងទីជនបទ
- ពង្រឹង និងពង្រីកវិស័យអប់រំតាមសាលាពុទ្ធិកសិក្សានូវគ្រប់កម្រិត
- បើកវគ្គបណ្តុះបណ្តាលគ្រប់មុខវិជ្ជាដល់គ្រូគ្រប់កម្រិត
- ពង្រឹងការ ទប់ស្កាត់ តាមដាន ដោះស្រាយអធិករណ៍
- ពង្រឹង និងពង្រីកការអប់រំ សីលធម៌ ចរិយាធម៌ តាមរយៈសាសនា

ផ្អែកតាមទិសដៅសំខាន់ៗ ដែលបានលើកឡើងខាងលើមន្ទីរបានពង្រឹង និងធ្វើយ៉ាងណាគឺដើម្បីឱ្យការិយាល័យជំនាញ ការិយាល័យប្រចាំក្រុង ស្រុ រៀបចំកម្មវិធីអនុវត្តការងារជាក់ស្តែងរបស់ខ្លួនឱ្យទទួលលទ្ធផលល្អ និងមានប្រសិទ្ធភាពខ្ពស់។

### ១.២.២.៦ វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានរាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា បន្តចាត់ទុកជាវិស័យអាទិភាពមួយក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដូចមានដែលចែងយ៉ាងច្បាស់នៅក្នុង " មុំទី៣ នៃចតុកោណទី៤ ស្តីពីការលើកស្ទួយវិស័យឯកជន និងការងារ " (ការអភិវឌ្ឍទីផ្សារការងារ) " មុំទី១ ទី៣ នៃចតុកោណទី៤ ស្តីពីការអភិវឌ្ឍធនធានមនុស្ស " (ការពង្រឹង និងលើកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គម) ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាតួអង្គមួយដ៏សំខាន់ ក្នុងការរួមចំណែកអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម(IDP) និងជាតួអង្គស្នូលក្នុងការអនុវត្តគោនយោបាយជាតិស្តីពីមុខរបរ និងការងារ (NEP) ដែលរាជរដ្ឋាភិបាលដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០១៥ ។

ជាក់ស្តែង ដើម្បីលើកកម្ពស់ការងារនេះ ត្រូវបន្តអនុវត្តនូវកញ្ចប់គោលនយោបាយមួយចំនួនដើម្បីទ្រទ្រង់ដល់ដំណើរការនៃវិស័យឯកជន ជាពិសេសវិស័យវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើង ក្នុងនោះដើម្បីសម្រេចបាននូវការអភិវឌ្ឍធនធានមនុស្សប្រកបដោយសមធម៌ទាំងបរិមាណ និងគុណភាព ដែលឆ្លើយតបបានតាមតម្រូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ព្រមទាំងដោះស្រាយរាល់បញ្ហាប្រឈមខាងលើ ក៏ដូចជាចូលរួមចំណែកក្នុងការធ្វើកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ ដូចមានចែងនៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់នូវយុទ្ធសាស្ត្រអាទិភាពចំនួន ០៥ ៖ (១)-ការអភិវឌ្ឍន៍លក្ខខណ្ឌការងារ និងការធានានូវ សុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ (២)-ការអភិវឌ្ឍន៍ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (៣)-ការអភិវឌ្ឍន៍មុខរបរ និងការងារ (៤)-ការអភិវឌ្ឍន៍របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ (៥)-

ការពង្រឹងអភិបាលកិច្ចល្អ ដែលទាំងអស់នេះ ជាកត្តាមួយឆ្ពោះទៅរកភាពជោគជ័យនៃគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជាផងដែរ ។

ដូច្នេះ ដើម្បីចូលរួមចំណែកអនុវត្តន៍ឱ្យបានជោគជ័យនូវយុទ្ធសាស្រ្តអាទិភាពទាំង៥ ខាងលើថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីរាជការនៅតាមអង្គភាពក្រោមឱវាទទាំងអស់ប្តេជ្ញាខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការអនុវត្តតាមផែនការយុទ្ធសាស្រ្ត និងសកម្មភាពនីមួយៗ។ ជាក់ស្តែង ក្នុងត្រីមាសទី១ឆ្នាំ២០១៩នេះ មន្ទីរសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើនដូចខាងក្រោម៖

- ស្ថិតិស្ដីពីចំនួន រោងចក្រ សហគ្រាស គ្រឹះស្ថាន ក្នុងខេត្តកំពង់ស្ពឺ មានចំនួន252 ទីតាំង មានកម្មករសរុប 118,821នាក់ ស្រី 96,646នាក់ ក្នុងនោះវិស័យ វាយនភ័ណ្ឌកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងចំនួន 118កន្លែង មានកម្មករសរុប113,487នាក់ ស្រី94,820នាក់។
- មន្ទីរបានចុះធ្វើអធិការកិច្ចការងារលើលក្ខខណ្ឌការងារទូទៅបានចំនួន 45 លើក។
- ចេញលិខិតអនុញ្ញាតធ្វើការលើសចិរវេលាកំណត់បានចំនួន 119 លើក។
- មន្ទីរបានជំរុញសកម្មភាពហ្វឹកហ្វឺននៅតាមសហគ្រាស គ្រឹះស្ថានសរុបចំនួន06 សហគ្រាស គ្រឹះស្ថាន ដែលមានកូនជាងកម្មករសរុបចំនួន212នាក់ ដែលក្នុងនោះស្រីមានចំនួន 143នាក់។
- ចំនួនសិក្ខាកាម សិស្ស-និស្សិត បានកំពុងសិក្សា និងបញ្ចប់ការសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺមាន៖ សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស មានចំនួនសរុប 65នាក់ ស្រីមានចំនួន 22 នាក់។ សិក្ខាកាមបានបញ្ចប់ការសិក្សាវគ្គខ្លី តាមរយៈថវិកាទ្រទ្រង់ គ្រឹះស្ថានសិក្សា ( PB) មានចំនួនសរុប 643 នាក់ ដែលក្នុងនោះ ស្រីមានចំនួន 338 នាក់។ សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ មានចំនួនសរុប 50នាក់ ដែលក្នុងនោះស្រីមានចំនួន 6 នាក់ សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២ មានចំនួនសរុប 37នាក់ ដែលក្នុងនោះស្រីមានចំនួន 09 នាក់ សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ មានចំនួនសរុប 11នាក់ដែលក្នុងនោះស្រីមានចំនួន 01នាក់ ។

#### ១.២.២.៧ វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ទិន្នន័យចាស់)

បច្ចុប្បន្ននេះ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានយកចិត្តទុកដាក់ក្នុងការងារសំខាន់ៗរបស់ខ្លួនដូចជា ការងារសោធននិវត្តន៍ និងការងារចាស់ជរា ត្រូវបានយកចិត្តទុកដាក់អនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ ដើម្បីធានាការបើកប្រាក់សោធននិវត្តន៍ប្រចាំខែបានទាន់ពេលវេលា ពិសេសការជំរុញការងារសមាគមចាស់ជរាឱ្យមានដំណើរការល្អ។ ការការពារសិទ្ធិកុមារ និងទប់ស្កាត់ការជួញដូរស្ត្រី និងកុមារក៏បានពង្រីកសកម្មភាពនៅតាមសហគមន៍គោលដៅ ដោយប្រើប្រាស់ថវិការដ្ឋាភិបាល និងអង្គការដៃគូនានា។ ចំណែកកុមារកំព្រា និងជនអនាថាក៏បានបន្តការជួយសង្គ្រោះតាមលទ្ធភាពនៃថវិកាដែលមាន។ ចំពោះជនពិការ ក៏កំពុងមាន ការយកចិត្តទុកដាក់តាមរយៈការផ្តល់ជារទេះរុញ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីចិញ្ចឹមជីវិត។

#### ១.២.២.៨ វិស័យវប្បធម៌ និងវិចិត្រសិល្បៈ (ទិន្នន័យចាស់)

វិស័យវប្បធម៌ត្រូវអភិវឌ្ឍន៍ និងអភិរក្សយ៉ាងយកចិត្តទុកដាក់ តាមការណែនាំពីថ្នាក់ជាតិ និងមានការសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋ។ ការបណ្តុះបណ្តាលជាបន្តបន្ទាប់នូវជំនាញសិល្បៈសូនរូប និងសិប្បកម្ម (តម្បាញ ចម្លាក់ និងគំនូរ)។ ការងារសិល្បៈ ទស្សនីយភាពក៏កំពុង បណ្តុះបណ្តាលយុវជនជំនាន់ក្រោយលើវិជ្ជាជីវៈរបាំល្ខោន ចាប៉ី ភ្លេងសម័យ និងបុរាណ ព្រមទាំងមាន ការបើកជាមហោស្រពទៀតផង។ ការប្រមូលវត្ថុបុរាណ ដែលនៅរាយប៉ាយមករក្សាទុកក្នុងសារៈមន្ទីរ។ បន្តអភិរក្ស និងអភិវឌ្ឍវប្បធម៌ជនជាតិដើមភាគតិចតាមរយៈការរៀបចំជាសហគមន៍ ឬ ជាភូមិវប្បធម៌។ អនុវត្តការចុះបញ្ជីបេតិកភណ្ឌ បោះបង្គោលដែនការពារបេតិកភណ្ឌ និងធ្វើប្លង់កាន់កាប់ជាសម្បត្តិរដ្ឋ។ យកចិត្តទុកដាក់ក្នុងការទប់ស្កាត់ការជួល និងចាក់វីដេអូអាសអាភាស។

### ១.២.២.៩ វិស័យព័ត៌មាន

មន្ទីរព័ត៌មាន មានតួនាទីក្នុងការផ្សព្វផ្សាយព័ត៌មានយ៉ាងយកចិត្តទុកដាក់តាមការណែនាំពីថ្នាក់ជាតិ និងរួមសហការជាមួយអាជ្ញាធរដែនដី មន្ទីរអង្គភាព និងប្រជាពលរដ្ឋ ដើម្បីចុះយកព័ត៌មានក្នុងក្រុបខ័ណ្ឌខេត្តតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានៈវិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី គេហទំព័រ និងរូបភាព ។ ជាមួយគ្នាដែរវិស័យសោតទស្សន៍មានតួនាទីភារកិច្ចយ៉ាងសំខាន់ ដែលមន្ទីរកំពុងយកចិត្តទុកដាក់ អនុវត្តយ៉ាងសកម្ម តាមរយៈការផ្តល់សេវាសាធារណៈជូនអតិថិជន ។តាមគោលនយោបាយរបស់រដ្ឋាភិបាល បានចាត់ទុកវិស័យព័ត៌មាន ជាកញ្ចក់សម្រាប់ ឆ្លុះបញ្ចាំងតថភាពក្នុងសង្គម ហើយជាស្ពានចម្លងពីរាជរដ្ឋាភិបាលមកជូនប្រជាពលរដ្ឋ ពីប្រជាពលរដ្ឋទៅកាន់រាជរដ្ឋាភិបាល ។មន្ទីរបានបង្កលក្ខណៈងាយស្រួលជូន ក្រុមហ៊ុនឯកជនតំឡើងទូរទស្សន៍ខ្សែកាប មានចំនួន ០៣ ស្ថានីយ៍ និងវិទ្យុ FM ចំនួន ០២ ស្ថានីយ៍ ។

-បានបញ្ជូនមន្ត្រីបណ្តុះបណ្តាលជំនាញយកព័ត៌មាន

-កៀងគរថវិកា ដើម្បីអភិវឌ្ឍន៍វិស័យព័ត៌មានឲ្យកាន់តែប្រសើរឡើង

### ១.២.២.១០ វិស័យទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច (ទិន្នន័យចាស់)

មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចត្រូវបានក្រសួងផ្តល់តួនាទី ភារកិច្ចជាសេនាធិការឱ្យក្រសួងអនុវត្តការងារ ដូចខាងក្រោម៖

- ទំនាក់ទំនងជាមួយសមាជិករដ្ឋសភា ព្រឹទ្ធសភា តំណាងរាស្ត្រប្រចាំមណ្ឌល និងអាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់
- ធ្វើអធិការកិច្ចលើគ្រប់វិស័យក្នុងរង្វង់ដែនដី ដែលខ្លួនតាំងនៅសំដៅប្រឆាំងនឹងអំពើពុករលួយការរំលោភអំណាច និងបាតុភាពអសកម្មនានា
- ទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធវិវាទដីធ្លីទូទាំងខេត្ត និងសង្កេតស្រាវជ្រាវដើម្បីធ្វើការសម្របសម្រួលព្រមទាំងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

- ផ្សព្វផ្សាយច្បាប់ដែលចូលជាធរមាន និងលិខិតបទដ្ឋានគតិយុត្តជូនប្រជាពលរដ្ឋឱ្យយល់ដឹងជ្រួតជ្រាប និងជំរុញឱ្យពួកគាត់ចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់
- ចុះត្រួតពិនិត្យការអនុវត្តច្បាប់។

ជារៀងរាល់ឆ្នាំ មន្ទីរបានធ្វើការផ្សព្វផ្សាយច្បាប់បានមួយចំនួនដូចជា ច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ។ ក្រៅពីនោះ មន្ទីរក៏បានផ្សព្វផ្សាយលិខិតបទដ្ឋាននានាដូចជា អនុក្រឹត្យស្តីពីការគ្រប់គ្រងជីវជ្ជជាដើម។ ជាក់ស្តែងនៅក្នុងឆ្នាំ ២០១៧ មន្ទីរបានខិតខំបំពេញការងាររបស់ខ្លួនទាំងការផ្សព្វផ្សាយច្បាប់ ការទទួលពាក្យបណ្តឹង និងចុះអង្កេតស្រាវជ្រាវ និងតាមដានការអនុវត្តច្បាប់ដោយធ្វើអធិការកិច្ចតាមមន្ទីរ ជំនាញជុំវិញខេត្តបានទទួលលទ្ធផលគួរឱ្យកត់សម្គាល់។

ទោះជាយ៉ាងណាក្តី ក៏ការផ្សព្វផ្សាយច្បាប់ទាំងនេះនៅមានកម្រិតមិនទាន់បានទូលំទូលាយទូទាំងខេត្តនៅឡើយ ដោយកង្វះថវិកាសម្រាប់រៀបចំផ្សព្វផ្សាយ រីឯការចុះអង្កេតស្រាវជ្រាវ និងការសម្របសម្រួលបញ្ហា បណ្តឹងវិញ មន្ទីរបានខិតខំប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការជួយប្រជាពលរដ្ឋដែលរងនូវភាពអយុត្តិធម៌។ មន្ទីរបានដាក់ផែនការការងារជាប្រចាំ ដើម្បីអនុវត្តដូចជា ផែនការខែ ត្រីមាស ឆមាស ផែនការឆ្នាំ ៣ឆ្នាំ និង៥ឆ្នាំ។ ជាចាំបាច់ត្រូវផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់សម្រាប់គាំទ្រវិស័យខាងលើនេះឱ្យដំណើរការ និងទទួលបានលទ្ធផលល្អ។

### ១.២.២.១១ វិស័យមុខងារសាធារណៈ (ទិន្នន័យចាស់)

ស្ថានភាពវិស័យមុខងារសាធារណៈក្នុងខេត្តមានភាពល្អប្រសើរច្រើន ដោយបានអនុវត្តទៅតាមគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រ នៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៧ ២០១៩- ដោយក្នុងនោះ នៅទូទាំងខេត្តយើងមានការប្រើប្រាស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា៖

- មន្ត្រីរាជការស៊ីវិល ៧,៧២៦ នាក់ ស្រី ៣,០៣៤ នាក់
- មន្ត្រជាប់កិច្ចសន្យា ៥៧៤ នាក់ ស្រី ១៧៨ នាក់
- គ្រុពុទ្ធិកសិក្សា៩០ នាក់ ស្រី ០១នាក់

**បញ្ហាប្រឈមរួមមាន ៖**

1. ផ្សព្វផ្សាយច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលដល់មន្ត្រីរាជការគ្រប់មន្ទីរ / អង្គភាព
2. ធ្វើការផ្សព្វផ្សាយរាល់លិខិតបទដ្ឋានគតិយុត្តិថ្មីៗ ដែលមានដូចជា ព្រះរាជក្រឹត្យ,អនុក្រឹត្យ, ប្រកាស,សារាចរ។
3. ចុះត្រួតពិនិត្យការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាតាមបណ្តាមន្ទីរ អង្គភាព និងក្រុង/ស្រុកទាំង០៨។

## ១.២.៣ ស្ថានភាពធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (ទិន្នន័យចាស់)

សណ្ឋានដីខេត្តកំពង់ស្ពឺមានរាងជាបាតឆ្នាំងខ្ទះ ដោយមានចំណោតជម្រាលពីប៉ែកខាងលិច ខាងជើង និងប៉ែកខាងត្បូងជាតំបន់ព្រៃភ្នំ និងខ្ពង់រាបដែលអំណោយផលល្អសម្រាប់ដំណាំកសិ-ឧស្សាហកម្ម រីឯប៉ែក ខាង

កើត និងកណ្ដាលជាតំបន់វាលទំនាបសម្រាប់កសិកម្ម និងមានការរីកចម្រើនខ្លាំងខាងវិស័យកសិ-ឧស្សាហកម្ម និងវិស័យឧស្សាហកម្មកាត់ដេរ។

កំណែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន របស់រាជរដ្ឋាភិបាល បានធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានការរីកចម្រើនជាលំដាប់ ជាក់ស្តែងនៅពាក់កណ្ដាលឆ្នាំ២០១២ និងដើមឆ្នាំ២០១៣ អាជ្ញាធរខេត្តកំពង់ស្ពឺ បានអនុវត្តតាមគោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី ដោយក្រុមនិស្សិតបានចុះវាស់វែងដីធ្លីជូនប្រជាពលរដ្ឋនៅស្រុកឧដុង្គ ថ្ពង ឱរ៉ាល់ ភ្នំស្រួច និងស្រុកបសេដ្ឋ។

រាជរដ្ឋាភិបាលបានធ្វើការកែទម្រង់ស៊ីជម្រៅលើវិស័យបរិស្ថាន ពិសេសការគ្រប់គ្រងធនធានធម្មជាតិ ដោយបានដកហូតដីសម្បទានសេដ្ឋកិច្ចដែលមិនបានអនុវត្តគម្រោងរបស់ខ្លួន មិនគោរពតាមកិច្ចសន្យាព្រមទាំងបានកម្រិតរយៈពេលដីសម្បទានសេដ្ឋកិច្ចមកនៅត្រឹម៥០ឆ្នាំ។ ម្យ៉ាងវិញទៀតក្រសួងបរិស្ថានបាននឹងកំពុងធ្វើប្រតិភូកម្ម "ការគ្រប់គ្រងតំបន់ការពារធម្មជាតិ" ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើការគ្រប់គ្រង។

### ១.២.៣.១ ការប្រើប្រាស់ដីធ្លី (តួលេខចាស់ របស់មន្ទីរកសិកម្ម) (ទិន្នន័យចាស់)

ការប្រើប្រាស់ដីធ្លីមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងខេត្ត ព្រោះថាប្រជាពលរដ្ឋ ៧០.០២% មានមុខរបរកសិកម្មជាចម្បង។ ការប្រើប្រាស់ដីនៅខេត្តកំពង់ស្ពឺ អាចចែកចេញជា ០៥ ចំណាត់ថ្នាក់សាមញ្ញរួមមាន៖ ដីលំនៅដ្ឋានដីកសិកម្ម (ស្រែនិងចម្ការ) ដីព្រៃ តាមតំបន់ភ្នំដីខ្សោះជីជាតិ គ្មានរុក្ខជាតិដុះនិងដីអាងស្តុកទឹក (ស្ទឹង ប្រឡាយ អូរ និង ត្រពាំង)។ ការកាន់កាប់ និងគ្រប់គ្រង ដីធ្លីក្រៅពីដីលំនៅដ្ឋាន និងដីស្រែចម្ការ ដែលជាកម្មសិទ្ធិរបស់ឯកជន គឺសុទ្ធសឹងជាដីរបស់រដ្ឋដែល ស្ថិតនៅក្រោម រូបភាពពីរ៖ ទី១- ដីឯកជនរបស់រដ្ឋដែលភាគច្រើនជាតំបន់ភ្នំ និងតំបន់ខ្ពង់រាបស្ថិតនៅក្នុង បណ្ដាស្រុកទាំង០៧ លើកលែងក្រុងច្បារមនមួយចេញ និងទី២- ដីសាធារណៈរបស់រដ្ឋ ដោយស្ថានភាពភូមិសាស្ត្រខេត្តស្ថិតនៅជាប់ព្រំប្រទល់ខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តពោធិសាត់ ដូច្នេះដីសាធារណៈរបស់រដ្ឋមានលក្ខណៈជាដីព្រៃធំៗ ឬ តំបន់ការពារ តំបន់អភិរក្សធំៗ តំបន់ការពារជាលក្ខណៈសហគមន៍ និងតំបន់រដ្ឋបាល សាធារណៈ ដូចជា៖ មន្ទីរពេទ្យ សាលារៀន ផ្លូវថ្នល់ វត្តអារ៉ាម និងអាងទំនប់។

បន្ថែមលើនេះអាជ្ញាធរខេត្ត ជាពិសេសមន្ទីរបរិស្ថាន បានបង្កើតនូវតំបន់ការពារជាលក្ខណៈសហគមន៍ជាច្រើនហិកតាទៀត។ ស្ថានភាពនៃការកាន់កាប់ និងគ្រប់គ្រងដីនៅក្នុងខេត្តទាំងមូល មានដីកម្មសិទ្ធិរបស់ ឯកជន និងដីរបស់រដ្ឋ គឺកំពុងធ្វើឱ្យមានភាពច្បាស់លាស់តាមរយៈការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ លក្ខណៈជាប្រព័ន្ធ និងតាមរយៈការអនុវត្តគោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាល ហើយបច្ចុប្បន្នរាជរដ្ឋាភិបាលក៏កំពុងជំរុញនូវយន្តការនៃការងារចុះបញ្ជីដីរដ្ឋ ដើម្បីពង្រឹងការគ្រប់គ្រងដីសម្បទាន សេដ្ឋកិច្ចដែលពីមុនដីភាគច្រើនគឺពុំមានប័ណ្ណសម្គាល់សិទ្ធិ កាន់កាប់អចលនទ្រព្យដែលជាហេតុធ្វើឱ្យទំនាស់ ដីធ្លីកើតមានជាច្រើនករណី ដូចជា៖ ទំនាស់ដោយសារជណ្ដើមទាមទារដីកេរអាករ ទំនាស់ដោយសារព្រំប្រទល់ដីមិនច្បាស់លាស់ ទំនាស់ដោយសារការទន្ទ្រានកាន់កាប់ដីដោយខុសច្បាប់ និងទំនាស់ដោយសារ ចេញប័ណ្ណកាន់កាប់ដីជាន់គ្នា ហើយជាក់ស្តែងក្នុងឆ្នាំ ២០១៤ ខេត្តកំពង់ស្ពឺមានទំនាស់ដីធ្លីរហូតដល់ ២០៧ករណី គណៈកម្មការ

សុរិយោដីខេត្ត និងអាជ្ញាធរខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានយកចិត្តទុកដាក់ ដោះស្រាយវិវាទដីធ្លីក្នុងដែនសមត្ថកិច្ចជាបន្តបន្ទាប់ ទំនាស់ដីធ្លីកំពុងដោះស្រាយមាន ០២ករណី នៅឆ្នាំ ២០១៦។

ចំពោះដីលំនៅដ្ឋាននៅក្នុងខេត្ត គឺសំដៅទៅដល់ដីដែលប្រើប្រាស់សម្រាប់សង់លំនៅដ្ឋាន អគារ រដ្ឋបាល និងសម្រាប់ដាំដំណាំសួនជាលក្ខណៈគ្រួសារនៅឆ្នាំ២០១៥ មានកំណើនខ្ពស់ដែលនេះជាតម្រូវការ មួយធ្វើឱ្យតម្លៃដីធ្លីសម្រាប់លំនៅដ្ឋានកើនឡើងមួយកម្រិតទៀត។

ផ្ទៃដីកសិកម្ម ជាតម្រូវការដែលមិនអាចខ្វះបានសម្រាប់ប្រជាពលរដ្ឋនៅក្នុងខេត្តដែលឆ្នាំ ២០១៥ ប្រមាណ ៦១.២៥% ជាប្រជាកសិករប្រកបរបរធ្វើស្រែ និង១.៤៧% ជាប្រជាកសិករប្រកបរបរធ្វើចម្ការ។ បច្ចុប្បន្នខេត្តកំពុងរៀបចំឱ្យមានប្រភេទដំណាំ ដើម្បីគាំទ្រដល់វិស័យឧស្សាហកម្មដែលមានទ្រង់ទ្រាយធំ បើទោះបីជាស្ថានភាពផ្ទៃដីខេត្តមិនមានដីទំនេរសម្រាប់ដាំដំណាំលក្ខណៈជាឧស្សាហកម្ម ម្យ៉ាងដោយដីទំនេរ ខ្លះជាដីព្រៃស្ថិតក្រោមការគ្រប់គ្រងការពារ និងអភិរក្សហើយនោះជាលក្ខណៈដីភ្នំ។

យើងឃើញមានបញ្ហាមួយចំនួន ដែលកើតមានចំពោះការគ្រប់គ្រងដីធ្លី ដែលតម្រូវឱ្យអាជ្ញាធរខេត្ត ត្រូវតែដោះស្រាយ។ បញ្ហាទាំងនោះរួមមាន៖ អ្នកកាន់កាប់ឯកជនភាគច្រើនគ្មានប័ណ្ណកាន់កាប់ ហើយការចេញ ប័ណ្ណតាមរយៈការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំមានភាពយឺតយ៉ាវ។ ប្រព័ន្ធចុះបញ្ជីដីពុំទាន់អភិវឌ្ឍន៍ បានល្អនៅឡើយ។ ពុំទាន់មានផែនការគោលសុរិយោដី ហើយការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធក៏នៅមានការខ្វះខាតនូវសម្ភារ ថវិកា និងធនធានមនុស្ស ដែលជាហេតុធ្វើឱ្យការចុះ បញ្ជីដីនៅមានភាពយឺតយ៉ាវនៅឡើយ។ ការផ្សព្វផ្សាយព័ត៌មាន និងការអប់រំដីធ្លីនៅមានកម្រិត ហើយការយល់ដឹងអំពីសិទ្ធិកាន់កាប់លើដីធ្លីក្នុងចំណោមប្រជាពលរដ្ឋក្នុងខេត្តនៅទាប។ ផែនការប្រើប្រាស់ដី និងការគ្រប់គ្រងធនធាន ធម្មជាតិមិនបានធ្វើសមាហរណកម្មជាមួយគ្នា និងមិនបានធ្វើវិមជ្ឈការ។ ដីរដ្ឋពុំទាន់បានធ្វើអត្តសញ្ញាណកម្មច្បាស់លាស់ ហើយការគ្រប់គ្រងមិនបានត្រឹមត្រូវបន្ទាប់ពីដំណើរការអន្តរកាល ដែលនាំទៅរកការបង្កើនល្បឿននៃការរំលោភយកដី និងការកាប់បំផ្លាញព្រៃឈើ។ គ្រួសារក្រីក្រជាច្រើនគ្មានដី ឬ ដីតិចសម្រាប់ការចិញ្ចឹមជីវិត។ ដីបង្កបង្កើនផលភាគច្រើនមិនសុទ្ធតែស្ថិតក្នុងការផលិតទេ។ ភាពក្រីក្រធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនមិនមានលទ្ធភាពទិញ ឬ ជួលដីបាន។ ក្នុងនោះដែរ ដីសម្បទានសង្គមកិច្ច ដីសម្បទានកសិកម្ម ដីសម្បទានដាំដុះ និងដីសម្បទាននៅទំនេរមិនទាន់មានការស្រុះស្រួលគ្នា ១០០% នៅឡើយ។

បញ្ហាប្រឈម រួមមាន៖ (**ទិន្នន័យចាស់**)

- គោលនយោបាយរៀបចំដែនដី គោលនយោបាយជាតិស្តីពីលំនៅស្ថាន និងសារាចរណែនាំ ស្តីពីនីតិវិធីដោះស្រាយសំណង់បណ្តោះអាសន្នក្នុងទីក្រុង និងទីប្រជុំជនពុំទាន់បានចាត់តាំង អនុវត្តឱ្យមានប្រសិទ្ធភាព នាំឱ្យមានបាតុភាពសាងសង់សំណង់ថ្មីៗនៅលើដីសាធារណៈកើតមានជាបន្តបន្ទាប់ស្របពេលករណីចាស់ពុំទាន់បានដោះស្រាយ។
- ប្រជាពលរដ្ឋត្អូញត្អែរពីថ្លៃសេវា និងតម្លៃពន្ធប្រថាប់ត្រាក្នុងការផ្ទេរអចលនទ្រព្យ និងជាកត្តានាំឱ្យ ប្រជាជនគេចវេសពីការផ្ទេរដីធ្លីតាមនីតិវិធីសុរិយោដី និងនាំឱ្យបាត់បង់ពន្ធប្រថាប់ត្រាស្របពេល ដែល

ប្រព័ន្ធវាយតម្លៃថ្លៃដី ផែនទីថ្លៃដីពុំទាន់មានតម្លាភាព គណនេយ្យភាព។ ឯការងារសាងសង់ ក៏មានបញ្ហាប្រហាក់ប្រហែលគ្នានេះដែរ។

- ការប្រមូលទិញដីបង្កកទុកដោយមិនប្រើប្រាស់និងមិនធ្វើផលិតកម្មលើដីទាំងនោះក៏នៅតែជាបញ្ហា។
- ប្រជាពលរដ្ឋប្រមាណ ១០% ត្រូវបានបាត់បង់ដីធ្លី គ្មានដីបង្កបង្កើនផលដោយសារភាពក្រីក្រ និង ជម្ងឺដោយលក់ដីទៅឱ្យអ្នកដទៃ។
- ទំនាស់ដីធ្លីនៅកើតមានជាបន្តបន្ទាប់ ផ្តើមចេញពីការយល់ដឹងច្បាប់ភូមិបាលនៅមានកម្រិត និង នៅមានការបំពានលើច្បាប់។

### ១.២.៣.២ រដ្ឋបាលព្រៃឈើ (តួលេខចាស់)

ប្រទេសកម្ពុជា ជាប្រទេសមួយស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍ នៃតំបន់ត្រូពិច ដែលសម្បូរទៅដោយធនធានធម្មជាតិ ជាពិសេសព្រៃឈើដែលគ្របដណ្តប់លើផ្ទៃដីប្រមាណ ៧៣% នៃផ្ទៃប្រទេសមុនឆ្នាំ១៩៧០ (ធនធានគម្របព្រៃឈើកម្ពុជាឆ្នាំ២០០៤)។

នៅក្នុងឆ្នាំ២០០៦ គម្របព្រៃឈើកម្ពុជាបានថយចុះមកនៅប្រមាណ ៥៩% នៃផ្ទៃប្រទេស (កម្មវិធី ព្រៃឈើជាតិ) ការថយចុះនេះបណ្តាលមកពីការរុករានកាន់កាប់ដីព្រៃឈើ ការបម្លែងដីព្រៃឈើទៅជាដីកសិកម្ម តាមរយៈសម្បទានដីសេដ្ឋកិច្ច ការផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់នៅមានកម្រិត ការគាំទ្រសហគមន៍ព្រៃឈើនៅមានកម្រិត ការកំណត់ព្រំប្រទល់ និងការចុះបញ្ជីការព្រៃឈើយឺតយ៉ាវ និងការកើនឡើងនូវតម្រូវការប្រើប្រាស់ផលិតផលព្រៃឈើ និងដីព្រៃឈើ រួមផ្សំនឹងភាពក្រីក្ររបស់ប្រជាជនផងនោះបានជំរុញឱ្យប្រជាជនកាប់រុករានទន្ទ្រានជាបន្តបន្ទាប់ទៅលើធនធាន និងដីព្រៃឈើ ដើម្បីដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃ។ ដូច្នេះការបម្លែងដីព្រៃឈើទៅជាដីកសិកម្ម និងដីលំនៅដ្ឋានសម្រាប់រស់នៅ ឬលក់បន្តការប្រមូល និងការលក់ផលអនុផលព្រៃឈើផ្សេងៗទៀត ដែលជាហេតុបណ្តាលឱ្យធនធានព្រៃឈើថយចុះ។ ការថយចុះធនធាន និងដីព្រៃឈើធ្វើឱ្យខូចខាតប្រព័ន្ធអេកូឡូស៊ីព្រៃឈើបានជះឥទ្ធិពលជាច្រើនទៅលើសង្គម និងសេដ្ឋកិច្ចរបស់សហគមន៍មូលដ្ឋានដូចជាការធ្វើកសិកម្ម ការនេសាទ ការចិញ្ចឹមសត្វ។ល។

### ១.២.៣.៣ ធនធានធម្មជាតិ (ទិន្នន័យចាស់)

ផ្ទៃដីមួយភាគធំរបស់ខេត្តកំពង់ស្ពឺជាតំបន់ខ្ពង់រាប ហើយមានភ្នំព័ទ្ធជុំវិញជាហេតុធ្វើឱ្យខេត្តមានលក្ខណៈអំណោយផលគ្រាប់គ្រាន់សម្រាប់ប្រភពស្ទឹង បឹងបួរ ដែលជាលក្ខខណ្ឌមួយចាំបាច់សម្រាប់ការប្រកបរបរកសិកម្មរបស់ប្រជាពលរដ្ឋក្នុងខេត្តដែលនោះជាធនធានធម្មជាតិមួយដ៏សំខាន់ ដែលរាជរដ្ឋាភិបាល ជាពិសេសអាជ្ញាធរខេត្តកំពុងយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង។ ធនធានទឹកដ៏សំខាន់នេះ បានធ្វើឱ្យប្រជាពលរដ្ឋដែលមានទីតាំងស្ថិតនៅជាប់នឹងប្រភពទឹកនោះប្រើប្រាស់នូវសក្តានុពល ដែលខ្លួនមានសម្រាប់ការបង្កើនសេដ្ឋកិច្ចគ្រួសារតាមរយៈការធ្វើកសិកម្មទាំងរដូវប្រាំង និងវស្សា ការដាំដុះផ្សេងៗ ហើយក៏មានការវិនិយោគពីវិស័យឯកជនផងដែរលើការចិញ្ចឹមសត្វ និងការដាំដុះដំណាំឧស្សាហកម្មផ្សេងៗ។

ចំពោះធនធានព្រៃឈើ មានតួនាទីយ៉ាងសំខាន់ចំពោះប្រជាពលរដ្ឋខេត្តកំពង់ស្ពឺ ដែលរស់នៅតាម ទីជនបទ និងទីប្រជុំជនផ្សារផងដែរក្នុងការបង្កើតប្រាក់ចំណូលសម្រាប់ដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃ។

ផល-អនុផលព្រៃឈើ ដែលអាចប្រមូលបានសម្រាប់ជីវភាពប្រជាពលរដ្ឋរស់នៅមានដូចជា ផ្សិត ជ័រទឹក ជ័រចុង ផ្លែ ឈើ ស្លឹក ឫស មើម រុក្ខជាតិឱសថ អុស ធ្យូង កូនឈើសសរ ផ្តៅ ខ្លឹមច័ន្ទ ឈើដៃខ្លា ឫស្សីព្រិច ឫស្សី វល្លិ៍រមៀត សត្វស្លាប ថនិកសត្វ ត្រី សត្វល្មិត ទឹកឃ្មុំ។ល។

ការដកហូតផល-អនុផលព្រៃឈើពីសហគមន៍ត្រូវមានការអនុញ្ញាតពីគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងខណ្ឌរដ្ឋបាលព្រៃឈើ ហើយក៏មានប្រភេទឈើកម្រ ដែលសហគមន៍ និងអាជ្ញាធរខេត្តមិនអនុញ្ញាតឱ្យកាប់រំលំ មានដូចជា៖ បេង សុក្រម កកោះ ក្រញូង ឈើទាល ស្រឡៅ ត្រសេក ត្រាច លំបោរ ផ្ចឹក ក្រឡាញ់ កំពីងរាជ នាងផ្លែត ដូងថែម ម៉ៃសាក់ ស្វាយព្រៃ គគីរ រំដួល បង្គោ មៀនព្រៃ រ៉ូល និងព្យុង។

ក្រៅពីធនធានដែលប្រជាពលរដ្ឋបានអាស្រ័យផលខាងលើ ខេត្តកំពង់ស្ពឺនៅមានធនធានធម្មជាតិជាច្រើនទៀតទាំងលើដី ក្នុងដី ក្នុងទឹក លើទឹក និងមានខ្យល់អាកាសដ៏ល្អបរិសុទ្ធ ដែលអាចជាប្រភពសំខាន់សម្រាប់ជួយជ្រោមជ្រែងការអភិវឌ្ឍផ្នែកទេសចរណ៍ ឧស្សាហកម្មវិស័យរ៉ែ និងថាមពល ប្រភពថាមពលវារីអគ្គីសនី កសិកម្ម វប្បធម៌ សិប្បកម្ម និងការវិនិយោគផ្សេងៗ ដូចជា ភ្នំ ព្រៃឈើ ទឹកជ្រោះ ជ្រលងភ្នំ ជ្រោះភ្នំ ដងអួរ ស្ទឹង បឹងធម្មជាតិ ស្ថានីយ៍បូរាណវិទ្យា និងតំបន់វាលរាបធំៗ និងតំបន់មានជីជាតិខ្ពង់រាបជាច្រើន ហើយតំបន់ទាំងនេះបានក្លាយជាតំបន់មួយដែលអាជ្ញាធរខេត្ត និងអ្នកពាក់ព័ន្ធទាំងអស់កំពុងការពារអភិរក្ស ស្រាវជ្រាវ និងធ្វើការអភិវឌ្ឍន៍។

### ១.២.៣.៤ បរិស្ថាន (ទិន្នន័យចាស់)

បញ្ហាបរិស្ថាននៅបន្តកើតមានឡើង ហើយយើងទទួលស្គាល់ទាំងអស់គ្នាថា ដោយសារតែយើងនៅមានភាពខ្វះចន្លោះខាងច្បាប់ និងការអនុវត្តដោយមិនទាន់មានប្រសិទ្ធភាពខ្ពស់។ មន្ទីរបរិស្ថានខេត្តមានការគ្រប់គ្រងវិស័យបរិស្ថាននៅទូទាំងខេត្ត និងដោយមានកិច្ចសហការពីគ្រប់មជ្ឈដ្ឋាន បានប្រឹងប្រែងពុះពាររាល់ការលំបាក និងដោះស្រាយបញ្ហាប្រឈមនានាជាបណ្តើរៗប្រកបដោយជោគជ័យ ទោះបីជាមានឥទ្ធិពលយ៉ាងខ្លាំងក្លាពីសកម្មភាពរបស់មនុស្ស កំណើនតម្រូវការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសម្ពោធនៃការអភិវឌ្ឍផ្នែក ឧស្សាហកម្មយ៉ាងណាក៏ដោយ ។ បញ្ហាដែលយើងគួរឱ្យចាប់អារម្មណ៍ និងពិចារណាបំផុត គឺការការពារ ការអភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ការបំពុលបរិស្ថានក្នុងខេត្ត ព្រមទាំងផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ទាំងនេះគឺទាមទារឱ្យយើងមានយន្តការការអភិវឌ្ឍស្អាត សម្រាប់សេដ្ឋកិច្ចសង្គម។

មន្ទីរបរិស្ថានខេត្តបានសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការពង្រឹងការគ្រប់គ្រង ការការពារ ការអភិរក្ស ប្រើប្រាស់ធនធានធម្មជាតិ កិច្ចគាំពារបរិស្ថាន ការអភិវឌ្ឍន៍ដោយចីរភាព និងការគ្រប់គ្រងបរិស្ថានឱ្យមាននិរន្តរភាព។ ស្នាដៃសំខាន់ៗជាច្រើនរួមមាន៖ ការកសាងលិខិតបទដ្ឋាន សេចក្តីណែនាំ ការអប់រំ និងផ្សព្វផ្សាយចំណេះដឹងពីព័ត៌មានបរិស្ថាន ការការពារគុណភាពបរិស្ថាន ការត្រួតពិនិត្យ តាមដានសកម្មភាពនៅតាមប្រភពបំពុល កាតត្រួតពិនិត្យលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការត្រួតពិនិត្យផលប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍន៍មូលនិធិឃុំ-សង្កាត់ និងត្រួតពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅលើគម្រោងវិនិយោគនានា។ ដោយឡែកការគ្រប់គ្រងសំរាម សំណល់រឹង-រាវនៅតែជាបញ្ហានៅឡើយ ជាពិសេសការចោលសំរាមនៅទីសាធារណៈ កង្វះទីលានចាក់សំរាមនៅតាមបណ្តាស្រុកទាំង៧ ការគ្រប់

គ្រងសំណល់រាវ និងអាងប្រព្រឹត្តកម្ម មិនទាន់បានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ដែលទាមទារនូវការគ្រប់គ្រងបន្ថែមទៀតឱ្យមានប្រសិទ្ធភាព។

ការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅជួបបញ្ហាខ្លះៗដោយម្ចាស់គម្រោងអភិវឌ្ឍន៍មិនព្រមសហការជាមួយមន្ទីរជំនាញបរិស្ថានក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច និងសង្គម បានបណ្តាលឱ្យប៉ះពាល់សុខភាពសាធារណៈ ការរស់នៅរបស់ប្រជាពលរដ្ឋ ហេដ្ឋារចនាសម្ព័ន្ធ ដោយក្លិន រំញ័រ សម្លេង និងដីហុយជាដើម។

ទន្ទឹមនេះមន្ទីរបរិស្ថានក្នុងនាមស្ថាប័នជំនាញបានខិតខំបំផុសចលនាមហាជនបើកយុទ្ធនាការប្រមូលសម្អាតសំរាមនៅតាមទីប្រជុំជនសំខាន់ៗ មានដូចជា៖ យុទ្ធនាការប្រមូលសម្អាតអនាម័យក្នុងពេលពិធីចូលឆ្នាំប្រពៃណីជាតិខ្មែរ មុននិងក្រោយពេលពិធីបុណ្យអុំទូក ចូលឆ្នាំសកលនិង នៅសួនច្បារសម្តេចសង្ឃរាជ ជួន ណាត និងបរិវេណមណ្ឌលកីឡាខេត្តជាដើម។ យុទ្ធនាការប្រមូលសម្អាតសំរាមនៅតាមដងផ្លូវជាតិលេខ៤ នៅចំណុចពីផ្សារថ្នល់ទទឹងស្រុកសំរោងទង រហូតដល់ភ្នំពេជ្រនិល ស្រុកភ្នំស្រួច និងផ្លូវជាតិសំខាន់ៗដែលមាននៅក្នុងខេត្ត។ម្យ៉ាងវិញទៀតមន្ទីរបរិស្ថានបានចលនាឱ្យមានការស្រឡាញ់បរិស្ថាន ដោយបំផុសឱ្យមានការចូលរួមដាំកូនឈើ និងរុក្ខជាតិផ្កាលម្អ នៅតាមដងផ្លូវជាតិលេខ៤ក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងនៅលើឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ» ថែមទៀតផង។

### ១.២.៣.៥ ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ (ទិន្នន័យចាស់)

ខេត្តកំពង់ស្ពឺមានទីតាំងនៅភាគខាងលិចនៃរាជធានីភ្នំពេញ។ ខេត្តមានព្រំប្រទល់ខាងជើងជាប់ខេត្តកំពង់ឆ្នាំង និងពោធិសាត់ ខាងកើតជាប់ខេត្តកណ្តាលនិងតាកែវ ខាងលិចជាប់ខេត្តព្រះសីហនុ និងខេត្តកោះកុង ខាងត្បូងជាប់ខេត្តកំពតនិងខេត្តតាកែវ។ បើយើងធ្វើការវិភាគទៅលើឋានលេខា ឬ វិទ្យាសាស្ត្រខាងផែនទីវិញ ខេត្តត្រូវបានចែកចេញជាពីរតំបន់ គឺតំបន់វាលទំនាបស្ថិតនៅផ្នែកខាងកើតនៃទីរួមខេត្ត និងតំបន់ខ្ពង់រាបស្ថិតនៅផ្នែកខាងលិចនៃទីរួមខេត្ត ដែលគ្របដណ្តប់ដោយព្រៃឈើព្រមទាំងមានជួរភ្នំក្រវាញលាតសន្ធឹងនៅទិសខាងជើងនៃទីរួមខេត្ត ហើយខេត្តកំពង់ស្ពឺគឺត្រូវបានគេចាត់ទុកថា ជាខេត្តដែលស្ថិតក្នុងតំបន់ជនបទ។

ពាក់ព័ន្ធទៅនឹងស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ យើងសង្កេតឃើញថា ខេត្តកំពង់ស្ពឺបាននិងកំពុងទទួលរងការបាត់បង់ ខូចខាត បំផ្លិចបំផ្លាញ និងការប្រែប្រួល ដែលបង្កឡើងដោយគ្រោះមហន្តរាយសំខាន់ៗ ដូចជាការបំផ្លិចផ្លាញដោយសារ ខ្យល់កន្ត្រាក់ រន្ទះបាញ់ អគ្គិភ័យ និងការប្រែប្រួលអាកាសធាតុ ដូចជាភាពរាំងស្ងួត សីតុណ្ហភាពឡើងខ្ពស់កម្រិតទឹកភ្លៀងមិនគ្រប់គ្រាន់ ភ្លៀងធ្លាក់ខុសរដូវ និងគ្រោះទឹកជំនន់ជាដើម។ល។

**បញ្ហាប្រឈម រួមមាន៖**

- សហគមន៍មិនទាន់មានភាពធន់ទៅនឹងមុខសញ្ញាគ្រោះមហន្តរាយផ្សេងៗ ពិសេសមិនទាន់មានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- សមត្ថភាពត្រៀមបង្ការ និងឆ្លើយតបចំពោះមុខសញ្ញាផ្សេងៗនៃគ្រោះមហន្តរាយនៅមានកម្រិត

- ខ្វះធនធានហិរញ្ញវត្ថុសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលផ្សេងៗពាក់ព័ន្ធនឹងការងារគ្រោះមហន្តរាយដល់អ្នកពាក់ព័ន្ធពិសេសសហគមន៍
- ខ្វះមន្ត្រីបំពេញការងារពិតប្រាកដនៅលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង ស្រុក ពិសេសថ្នាក់ឃុំ សង្កាត់មិនទាន់យល់ដឹងច្បាស់ពីការងារគ្រោះមហន្តរាយ លើសពីនេះថ្នាក់ដឹកនាំមិនទាន់មានការលើកទឹកចិត្តចំពោះមន្ត្រីទទួលបន្ទុករ៉ាប់រងការងារគ្រោះមហន្តរាយ។

**ព័ត៌មាន និងទិន្នន័យគ្រោះមហន្តរាយ ឆ្នាំ២០១៩**

- **គ្រោះមហន្តរាយដែលបានកើតឡើងដោយធម្មជាតិ**

១). រន្ទះបាញ់បានកើតឡើងចំនួន ០៣ លើក ដោយបណ្តាលឱ្យស្លាប់មនុស្សចំនួន ០៤ នាក់ និងរងរបួសចំនួន ០៥ នាក់ ក្នុងនោះរងរបួសធ្ងន់ចំនួន ០២ នាក់។

២). ខ្យល់កន្ត្រាក់បានកើតឡើងចំនួន ៣៤ លើក ដោយបណ្តាលឱ្យខូចខាតទោចក្រយានយន្ត ចំនួន ០១ គ្រឿង និងខូចខាតផ្ទះប្រជាពលរដ្ឋចំនួន ៣០០ ខ្នង ក្នុងនោះខូចខាតធ្ងន់ធ្ងរចំនួន ៣៦ ខ្នង ខូចខាត មធ្យមចំនួន ២៨ ខ្នង និងខូចខាតស្រាលចំនួន ២៣៦ ខ្នង។

- **គ្រោះមហន្តរាយដែលបានកើតឡើងដោយមនុស្ស**

១). អគ្គីភ័យបានកើតឡើងចំនួន ៣១ លើក ដោយបណ្តាលឱ្យឆេះផ្ទះប្រជាពលរដ្ឋចំនួន ២៧ ខ្នង ឆេះផ្ទះបាយចំនួន ០១ ខ្នង ឆេះរថយន្តដឹកប្រេងចំនួន ០២ គ្រឿង ឆេះទោចក្រយានយន្តចំនួន ០៤ គ្រឿង ឆេះទូរទស្សន៍ចំនួន ០២ គ្រឿង ឆេះគ្រែចំនួន ០២ ឆេះទូឈើចំនួន ០៤ ឆេះសាលាបុណ្យភូមិចំនួន ០១ ខ្នង ឆេះមេក្រូចំនួន ០២ ឆេះកម្រាលព្រំចំនួន ០៦ ខ្សែ ឆេះកន្ទេលចំនួន ០៦ និងចានឆ្នាំងមួយចំនួន ឆេះស្នាក់ការមេព្រៃចំនួន ០១ ខ្នង ឆេះបន្ទះសឡាចំនួន ០១ ឈុត ឆេះម៉ាស៊ីនដែលដកហូតបានពីបទល្មើសព្រៃឈើចំនួន ០៣ គ្រឿង ឆេះឈើចំនួន ០២ ម៉ែត្រគូប ឆេះអាគុយចំនួន ០៤ ឆេះស្រូវក្នុងស្រែរបស់ប្រជាពលរដ្ឋចំនួន ៥៦ អា ឆេះអង្ករចំនួន ១៥០ គ.ក ឆេះស្រូវចំនួន ១៥ បាវ ឆេះសិប្បកម្មកែច្នៃប្រេងខ្មៅចំនួន ០១ កន្លែង ឆេះម៉ាស៊ីន ចម្រាញ់ប្រេងចំនួន ០៧ គ្រឿង ឆេះស៊ីទែនផ្ទុកប្រេងចំនួន ០៦ ឆេះធុងជ័រចំនួន ២៤ ឆេះប្រេងចម្រាញ់រួចចំនួន ៦៧ ០០០ លីត្រ ឆេះលុយអស់ចំនួន ១១ ៨៥០ ០០០ រៀល និងឆេះមាសអស់ចំនួន ០២ តម្លឹង ៣ ជី។

២). គ្រោះថ្នាក់ចរាចរណ៍បានកើតឡើងចំនួន ១៨៨/១៣២ លើក កើនឡើងចំនួន ៥៦ លើក បើប្រៀបធៀបនឹងឆ្នាំ ២០១៨ ដោយបណ្តាលឱ្យមនុស្សស្លាប់ចំនួន ១៣៥/១០២ នាក់ ក្នុងនោះស្រីចំនួន ២០/១២ នាក់ និងរបួសចំនួន ៣៥៣/២៩៤ នាក់ ក្នុងនោះរបួសធ្ងន់ចំនួន ២១៥/១៥៩ នាក់ ខូចរថយន្តចំនួន ១៧៨ គ្រឿង និងទោចក្រយានយន្តចំនួន ១៩៣ គ្រឿង។

### ១.២.៤ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ (ទិន្នន័យចាស់)

សកម្មភាពនានានៃការងារគ្រប់គ្រង់រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់មានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក្រោយពីមានកំណែទម្រង់រដ្ឋបាលសាធារណៈ និងការដាក់ចេញនូវកម្មវិធីជាតិសម្រាប់ការគាំទ្រដល់មូលដ្ឋានផ្ទាល់ តាមរយៈការពង្រឹងប្រព័ន្ធអភិបាលកិច្ចល្អនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍

ពង្រឹង និងពង្រីកលិទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន។ ក្នុងនោះដែរបទល្មើសផ្សេងៗមានការថយចុះផងដែរ បើយើងប្រៀបធៀបមុនពេលអនុវត្តនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។ ខាងក្រោមនេះ ជាស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្នទាក់ទងនឹងការងារគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់ របស់ខេត្តដែលកំពុងជួបប្រទះនាពេលកន្លងមកដែលទាមទារឱ្យមានការដោះស្រាយបន្ថែម៖

### ១.២.៤.១ ការងារអភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ គឺជាស្នូលនៃការរួមចំណែកអនុវត្តយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលក្នុងគោលដៅកៀរគរនូវការចូលរួមរបស់សាធារណៈជនប្រកបដោយសមធម៌ និងភាពត្រឹមត្រូវក្នុងគ្រប់ទិដ្ឋភាពតាមបែបប្រជាធិបតេយ្យ និងគ្មានអំពើហិង្សាធ្វើឱ្យវឌ្ឍនភាពផ្នែកសេដ្ឋកិច្ច សង្គមកិច្ចគួរឱ្យមានមោទកភាព តាមរយៈសមិទ្ធផលទាំងឡាយបានឆ្លុះបញ្ចាំងពីលទ្ធផលនៃកំណែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ ទី២ ទី៣ និងទី៤ ត្រូវបានបង្កើតឡើងដោយផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាទាំង ៨២ឃុំ និង៥សង្កាត់ ដែលមានសមាជិក ៦០៩នាក់ ស្ត្រី១០០នាក់ ត្រូវបានបណ្តុះបណ្តាល បំពាក់បំប៉នឱ្យបំពេញនូវតួនាទីភារកិច្ច សិទ្ធិអំណាចតាមច្បាប់ និងគោលការណ៍នានាជាធរមាន និងបានរួមចំណែកដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមភូមិ ឃុំ សង្កាត់ និងការលើកស្ទួយសេវាកម្មនានាជូនប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

រដ្ឋបាលខេត្តតែងតែខិតខំពង្រឹងការងារអភិបាលជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន និងប្រជាពលរដ្ឋ។ ក្រោយពេលមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់បោះឆ្នោតពាក់ព័ន្ធនឹងរដ្ឋបាលទាំងនេះ។ ក្រុមប្រឹក្សាខេត្ត ដែលមានសមាជិក ២៥នាក់ (ស្រី ០៣នាក់) គណៈអភិបាលខេត្ត ០៧នាក់ (ស្រី ០១នាក់) និងមន្ត្រីចំណុះសាលាខេត្តចំនួន ១២៨នាក់ (ស្រី ៥០នាក់) បានរៀនសូត្រអំពីតួនាទីភារកិច្ច សិទ្ធិអំណាច និងរបៀបរបបធ្វើការងារពាក់ព័ន្ធនឹងការងារ អភិបាលកិច្ចក្នុងបរិការណ៍ថ្មីនៃកំណែទម្រង់រដ្ឋបាលសាធារណៈ។ ក្រោយពីបានបង្កើតគណៈកម្មាធិការនានា របស់ក្រុមប្រឹក្សាខេត្តបាននឹងកំពុងចូលរួមយ៉ាងសកម្មក្នុងការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០ -២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់អាណត្តិទី៣ នៃក្រុមប្រឹក្សាខេត្ត ដែលឯកសារនេះនឹងក្លាយជាឧបករណ៍ដ៏សំខាន់សម្រាប់ធ្វើជាត្រីវិស័យក្នុងការលើកកម្ពស់កិច្ចដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច របស់ខេត្តឱ្យមានការរីកចំរើន។

រដ្ឋបាលខេត្តមានការិយាល័យប្រជាពលរដ្ឋ អង្គភាពច្រកចេញចូលតែមួយ និងការិយាល័យច្រកចេញចូលតែមួយមាននៅក្រុងច្បារមន ស្រុកឧដុង្គ គងពិសី និងស្រុកសំរោងទងក្នុងឆ្នាំ២០១៩ ។

**បញ្ហាប្រឈម រួមមាន៖**

- សមត្ថភាព និងគុណភាពការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅមានកម្រិតស្របពេលដែលតួនាទីភារកិច្ចមានច្រើន

- ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការរបស់វិស័យជំនាញនានាមានភាពយឺតយ៉ាវ និងពុំទាន់ស៊ីសង្វាក់ និងស្របគ្នាជាមួយរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ។
- ការធ្វើសមាហរណកម្មការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុក ចូលក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ពុំទាន់អនុវត្តបានល្អប្រសើរនៅឡើយ ។
- ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់មួយចំនួន ពុំទាន់បានយល់ពីការបែងចែកកញ្ចប់ថវិកាមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ ទៅតាមវិស័យនានាឱ្យបានចំគោលដៅ និងប្រសិទ្ធភាពនៅឡើយ ។
- ការអភិវឌ្ឍសមត្ថភាពទាំងកម្រិតស្ថាប័ន កម្រិតបុគ្គល (បុគ្គលិក) និងកម្រិតបរិយាកាសគាំទ្រ មិនទាន់បានបំពេញតាមតម្រូវការ សម្រាប់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ។
- គុណភាពសមត្ថភាពរបស់មន្ត្រីរាជការគ្រប់ផ្នែក ពុំទាន់ឆ្លើយតបតាមតម្រូវការការងារនាពេលបច្ចុប្បន្ន។

### ១.២.៤.២ ការគ្រប់គ្រងដែនដី (ទិន្នន័យចាស់)

ក្នុងខេត្តបានបែងចែកជា ០៨ក្រុង ស្រុក មានភូមិចំនួន ១,៣៧៩ ក្នុងនោះភូមិមានក្របខ័ណ្ឌចំនួន ១,៣៦៨ភូមិ ដែលមានផ្ទៃដីសរុប ៦,៩៦៩.៦៣ គីឡូម៉ែត្រការ៉េ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាប់ឆ្នោតអាណត្តិទី(៤) នាថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៧ មានចំនួន ៦០៩នាក់ ក្នុងនោះស្ត្រី ៨០នាក់ មកពីគណបក្សប្រជាជនកម្ពុជាចំនួន ៤១០នាក់ មកពីគណបក្សសិទ្ធិមនុស្សចំនួន ៩៤នាក់ គណបក្សសមរង្ស៊ីចំនួន ១០០នាក់ និងគណបក្សនរោត្តមរណឫទ្ធិ ចំនួន ០៥នាក់ក្នុងនោះសមាជិកជាប់ឆ្នោតថ្មីមានចំនួន ២១២នាក់។

សាលាឃុំ សង្កាត់ចំនួន ៤៤អគារ ក្នុងនោះ សាលាឃុំស្តង់ដារដែលជាជំនួយរបស់រាជរដ្ឋាភិបាល គាំទ្រដោយក្រសួងមហាផ្ទៃ ក្នុងគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់ (CCDP) តាមរយៈប្រាក់កម្ចី ADB loan (១៩៥៣) CAM (SSF) មានចំនួន ៤៣អគារ និង ១អគារទៀតជាជំនួយរបស់ប្រទេសសិង្ហបុរី តាមរយៈអង្គការមូលនិធិសៅសារីនៅកម្ពុជា។ អគារត្រូវបានសាងសង់រួចជាស្ថាពរបំពាក់សម្ភារៈផ្សេងៗដាក់ឱ្យដំណើរការរួចហើយ។

ចំនួនសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ដែលជាប់ឆ្នោតអាណត្តិទី២ នាថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ មានចំនួន ១៣៦នាក់ ក្នុងនោះស្ត្រី ១៦នាក់។ សាលាក្រុង ស្រុកទាំង ០៨ ត្រូវបានសាងសង់ទាំងកន្លែងធ្វើការ និងសាលប្រជុំរួចជាស្ថាពរ។

ចំពោះការកំណត់ព្រំប្រទល់ក្រុង ស្រុក ឃុំ សង្កាត់ និងភូមិបានរៀបចំដោះស្រាយបានល្អស្របពេលដែលខេត្តបានចុះបញ្ជីក្បាលដីជាលក្ខណៈប្រព័ន្ធ ឯបញ្ហាព្រំប្រទល់ជាមួយខេត្តផ្សេងៗ។ ដោយឡែកបញ្ហាព្រំប្រទល់ជាមួយខេត្តតាកែវ ខេត្តព្រះសីហនុ និងខេត្តកំពតត្រូវមានការសម្របសម្រួលកំណត់លើផែនទីឱ្យស្របតាមទិដ្ឋភាពជាក់ស្តែងដែលបានពិភាក្សាឯកភាពគ្នារួចហើយ។ បញ្ហាប្រឈមដែលត្រូវដោះស្រាយ គឺការរៀបចំប្លង់គោលសម្រាប់គ្រប់គ្រងដែនដីឱ្យបានច្បាស់លាស់។

### ១.២.៤.៣ ការងារគ្រប់គ្រងស្ថិតិ (ទិន្នន័យចាស់)

ការងារគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ជាបញ្ហាចាំបាច់ក្នុងការគ្រប់គ្រងរដ្ឋបាល ដែលកន្លងមករដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងសមត្ថកិច្ចជំនាញពាក់ព័ន្ធតែងតែអនុវត្តជាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។ សកម្មភាព

ផ្លាស់ចេញផ្លាស់ចូលការស្នាក់នៅ និងចំណាកស្រុកត្រូវបានកត់ត្រាយ៉ាងច្បាស់លាស់ដែលអាចជាមូលដ្ឋានសម្រាប់ ឱ្យរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ជំរុញការអភិវឌ្ឍន៍ខាងធនធានមនុស្សស្របតាមដំណាក់កាលនីមួយៗ។ តាមការធ្វើជំរឿនប្រជាពលរដ្ឋឆ្នាំ២០១៩នេះ លទ្ធផលបណ្ដោះអាសន្នក្នុងខេត្តមានចំនួនប្រជាពលរដ្ឋ ៨៧២,២១៩ នាក់ ស្រី ៤២៦,២១៩នាក់ ។

ការចុះបញ្ជីអត្រានុកូលដ្ឋានប្រចាំឆ្នាំ២០១៩ មានដូចតទៅ៖

**ក/ការចុះបញ្ជីអត្រានុកូលដ្ឋាន៖**

- ការរៀបអាពាហ៍ពិពាហ៍ និងរស់នៅជាមួយគ្នាជាលក្ខណៈប្ដីប្រពន្ធសរុប ៣,០៩១ គូរ
- កុមារកើតសរុប ២៤,៧៨៤ នាក់ ស្រី ៧,២៥៣ នាក់
- មរណៈភាពសរុប ២,៤៨៨ នាក់ ស្រី ១,១២៧ នាក់

**ខ/ការចុះបញ្ជីអត្រានុកូលដ្ឋានទាំងបីប្រភេទ៖**

- ចុះបញ្ជីកំណើតចំនួន ១៤,៣៨៩ នាក់ ស្រី ៧,០៩១ នាក់
- ចុះបញ្ជីបញ្ជាក់កំណើតលើស 1 ខែ ក្រោម 1 ឆ្នាំ ចំនួន ៣,៨៤៩ នាក់ ស្រី ១,៨៣៧ នាក់
- ចុះបញ្ជីបញ្ជាក់កំណើតលើស 1 ឆ្នាំ ក្រោម 5 ឆ្នាំ ចំនួន ៤,១៥៩ នាក់ ស្រី ១,៨៧១ នាក់
- ចុះបញ្ជីបញ្ជាក់កំណើត 5 ឆ្នាំឡើង ចំនួន ៤,៨០៤ នាក់ ស្រី ២,៣៦០ នាក់
- ចុះបញ្ជីអាពាហ៍ពិពាហ៍ ចំនួន ១,៩៣៥ គូរ មានមនុស្សស្មើ ៣,៨៧០ នាក់
- ចុះបញ្ជីមរណៈភាពចំនួន ២,៧៧០ នាក់ ស្រី ១,២៣៨ នាក់

**គ/សេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ៖**

| | | |
|---|---|---|
| -សេចក្ដីចម្លងសំបុត្រកំណើត | ចំនួន ៩,៥៣១ | សន្លឹក |
| -សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត | ចំនួន ៤៤,៤៦៤ | សន្លឹក |
| -សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ចំនួន ២,៣០៥ | សន្លឹក |
| -សេចក្ដីចម្លងសំបុត្រមរណៈភាព | ចំនួន ២,៦៨៤ | សន្លឹក |

**បញ្ហាប្រឈមរួមមាន៖**

- ប្រជាពលរដ្ឋពុំទាន់យល់អំពីសារប្រយោជន៍នៃឯកសារអត្រានុកូលដ្ឋាន
- សមត្ថភាពមន្ត្រីនៅថ្នាក់ក្រោមជាតិនៅមានកម្រិត
- ពុំមាននមធ្យោបាយសម្រាប់ចុះគាំទ្រដល់ឃុំ សង្កាត់

### ១.២.៤.៤ ការងារសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ

- <u>សភាពការណ៍បទល្មើសព្រហ្មទណ្ឌ:</u>
  - កើតមាន ៣០/២៧ លើក បើប្រៀបធៀបនឹងឆ្នាំ២០១៨ កើនឡើង ០៣ លើក ស្មើនឹង ១១,១១% ក្នុងនោះ៖ បទឧក្រិដ្ឋចំនួន ១២ លើក។ បណ្ដាលឱ្យស្លាប់មនុស្ស ០៣ នាក់ របួស ១០ នាក់ ធ្ងន់ ០៤ នាក់ អស់រថយន្ត ០២ គ្រឿង ម៉ូតូ ០៣ គ្រឿង ខ្សែកប្លាកទីន ០១ ខ្សែ និងកាបូប ០១។

- **ការងារបង្ក្រាបបទល្មើសព្រហ្មទណ្ឌ៖**
    - បង្ក្រាបបាន ៣០ ករណី ឃាត់ខ្លួន ៣៧ នាក់ បើប្រៀបធៀបនិងសភាពការណ៍ស្មើនឹង ១០០% បទឧក្រិដ្ឋ ១២ ករណី ឃាត់ខ្លួន ១៣ នាក់ និងបទមជ្ឈឹម ១៨ ករណី ឃាត់ខ្លួន ២៤ នាក់ កសាងសំណុំរឿងអនុវត្តន៍តាមនីតិវិធី។
    - បង្ក្រាបជាក់ស្តែងបានចំនួន ២៦ ករណី ឃាត់ខ្លួនមនុស្សបាន ៣៨ នាក់ បទឧក្រិដ្ឋ ១២ ករណី ឃាត់ខ្លួន ១៣ នាក់។ បទមជ្ឈឹម ១៤ ករណី ឃាត់ខ្លួន ២០ នាក់។
    - បង្ក្រាបដោយស៊ើបអង្កេត ០៤ ករណី ឃាត់ខ្លួន ០៤ នាក់ បទមជ្ឈឹម។
    - នគរបាលឃាត់ខ្លួនមុខសញ្ញា ១១ នាក់ រួចប្រគល់ជូនអង្គភាពពាក់ព័ន្ធអនុវត្តន៍តាមនីតិវិធី។
    - បានពិនិត្យកន្លែងកើតហេតុ ២០៨ លើក បទឧក្រិដ្ឋ ១៩ លើក បទមជ្ឈឹម ២៣ លើក និងគ្រោះថ្នាក់ផ្សេងៗ ១៦៦ លើក។
    - ថតរូបធ្វើសាលាកប័ត្រជនល្មើសឃាត់ខ្លួនក្នុងអគារ ៤៨ ម៉ោង ចំនួន ៤៩ នាក់ ពិនិត្យឃើញមានផ្ទុកសារធាតុញៀន ០៣ នាក់ ស្មើនឹង ៦%។
- **ការប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន**

– សភាពការណ៍ កើតមាន ១២/០៦ លើក កើនឡើង ០៦ លើក ក្នុងនោះ៖ បទឧក្រិដ្ឋ ករណីរំលោភសេពសន្ថវៈ ០៧ លើក បណ្តាលឱ្យរបួស ០៧ នាក់ រងគ្រោះ ០៧ នាក់ ស្រី និងខូចខាតសម្ភារៈមួយចំនួន។

– បង្ក្រាបបាន១២ ករណី ឃាត់ខ្លួន ១២ នាក់ បើប្រៀបធៀបនឹងសភាពការណ៍ស្មើនឹង ១០០% បទឧក្រិដ្ឋ ០៧ ករណី ឃាត់ខ្លួន ១២ នាក់ បទមជ្ឈឹម ០៥ ករណី ឃាត់ខ្លួន ០៥ នាក់។

– បានចុះផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស កាត់រត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារច្បាប់ទប់ស្កាត់អំពីហឹង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ និងច្បាប់ ឯកព័ន្ធភាពបាន១៣៥លើកមានអ្នកចូលរួមចំនួន៦.០៦៣នាក់ ស្រី ៣.០១៦ នាក់។

**–ការងារប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនខុសច្បាប់ជាជំហានៗ**

– បានចុះផ្សព្វផ្សាយច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន ២.៣២៧ លើក មានប្រជាពលរដ្ឋចូលរួមចំនួន ២០៨.៦២៨នាក់ ស្រី ១០៦.៣៤៧ នាក់។

– បានបង្ក្រាបជាក់ស្តែង បានចំនួន ១៦៤ ករណី ឃាត់ខ្លួនបាន ៣៦៣ នាក់ ស្រី ២៥ នាក់ ក្នុងនោះ ៖ ពីបទជួញដូរ និងចែកចាយគ្រឿងញៀន ចំនួន ១៤៦ ករណី ឃាត់ខ្លួន ៣១៦ នាក់ ស្រី ២៤ នាក់ ពីបទប្រើប្រាស់គ្រឿងញៀន ១៨ ករណី ឃាត់ខ្លួន ៤៧ នាក់ ដកហូតគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ១.០៧៧ កញ្ចប់ (៩៥២ កញ្ចប់តូច ១០៨កញ្ចប់មធ្យម ធំ១៧កញ្ចប់) ទម្ងន់ ១.៧១៨,៥៨ ក្រាម ម៉ូតូ៦៦ ទូរស័ព្ទដៃ ២៥១ គ្រឿង អាវុធខ្លី ០១ ដើម បង់ ២ គ្រាប់ ២៨ គ្រាប់ អាវុធច្នៃ ៧ អាវុធក្លែងក្លាយធ្វើពីឈើ ១ ដាវ ២២ ស្នាប់ដៃ១ លុយ ២.៨៣០ ដុល្លារ លុយរៀល ១៥.៥៨១.៥០០ រៀល ជញ្ជីងថ្លឹងគ្រឿងញៀន ១៥ និងឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួនទៀត។

– បានធ្វើការអប់រំណែនាំ និងចុះកិច្ចសន្យាមុខសញ្ញាប្រើប្រាស់គ្រឿងញៀន ១៦៧ នាក់ ឲ្យបញ្ឈប់ការប្រើប្រាស់គ្រឿងញៀនរួចបានប្រគល់ជូនឪពុកម្តាយឬអាណាព្យាបាល និងអាជ្ញាធរមូលដ្ឋានគ្រប់គ្រងបន្ត។

–បានបញ្ជូនមុខសញ្ញាប្រើប្រាស់គ្រឿងញៀន ១២៣ នាក់ ទៅមណ្ឌលកែប្រែអ្នកញៀនគ្រឿងញៀន។

–បង្ក្រាបតាមដីកា ២៥ ដីកា មនុស្ស ២៥ នាក់។

- **សភាពការណ៍កូដកម្ម បាតុកម្ម និងការតវ៉ាទាមទារ៖** ចំនួន ៥៧ លើក។

– កម្មករ កម្មការិនីតវ៉ាទាមទារអត្ថប្រយោជន៍ផ្សេងៗចំនួន ១៤ លើក។

– សហគមន៍ប្រជាពលរដ្ឋតវ៉ាទាមទារពាក់ព័ន្ធបញ្ហាដីធ្លីចំនួន ៤៣ លើក។

**–ការងារសុវត្ថិភាពចរាចរណ៍៖**

– កើតមាន ១៨៨/១៣២ កើនឡើង ៥៦ លើក បណ្តាលឱ្យស្លាប់មនុស្ស ១៣៥/១០២ នាក់ ស្រី២០/១២នាក់ របួស ៣៥៣/២៩៤ នាក់ ស្រី ១៣៥/១៧៤ នាក់ ធ្ងន់ ២១៥/១៥៩ នាក់ ស្រី ៨០/៧៥ នាក់ ខូចរថយន្ត ១៧៨ គ្រឿង ម៉ូតូ ១៩៣ គ្រឿង។

–**<u>គ្រោះថ្នាក់សង្គមផ្សេងៗ</u>** កើតមាន ១៦៦/១៦៥លើក បណ្តាលឱ្យមនុស្សស្លាប់ ១៤៣ នាក់ របួស ១៧ នាក់ របើកដំបូល ៤៧ ខ្នង រលំផ្ទះ ០២ ខ្នង ឆេះផ្ទះ ១៨ ខ្នង ឆេះរថយន្ត ០២ គ្រឿង ឆេះម៉ាស៊ីនសម្ងួតស្រូវ ០១ គ្រឿង និងសម្ភារៈមួយចំនួន។

– **<u>ការងារចរាចរណ៍:</u>** បានប្រមូលវត្ថុតាងករណីគ្រោះថ្នាក់ចរាចរណ៍ចំនួន ១៨៨ ករណី បញ្ជូនទៅតុលា ១៦៤ ករណី មនុស្ស ២៦ នាក់ រត់គេច ០៦ ករណី ដោះស្រាយបញ្ចប់ ១១ ករណី និងនៅសល់ចំនួន ០៧ ករណីទៀត កំពុងកសាងសំណុំរឿងបញ្ជូនទៅតុលាការចំនួន ១៤ ករណី។

– បានចាត់តាំងកម្លាំងចុះរឹតបន្តឹងការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកយ៉ាងសកម្ម តាមរយៈការយកចិត្តទុកដាក់ត្រួតពិនិត្យគោលដៅដើមទី និងគោលដៅសំខាន់ៗមួយចំនួន ដោយបានធ្វើការផាកពិន័យរថយន្តចំនួន ៦.១៩១ គ្រឿង និងម៉ូតូ ៣.៦២១ គ្រឿង សរុបទឹកប្រាក់ ២៤.២០០.០០០ រៀល។

- **ការងារគ្រប់គ្រងអាវុធជាតិផ្ទុះ**

– ជាតិផ្ទុះនាំចូលសរុប៖ ស៊ុបដាយ ២៥៣.០២៥ គីឡូក្រាម +(សល់ពីខែមុន ១០.៥២៧ គ.ក្រ ស្មើនឹង ២៦៣.៥៥២គ.ក្រ) អាម៉ូញូមនីត្រាត ៨៥៦.៣៩០ គីឡូក្រាម +(សល់ពីខែមុន ៥០.៥០០ គីឡូក្រាម ស្មើនឹង ៩០៦.៨៩០ គីឡូក្រាម ) គីបផ្ទុះ ៤៦៣.៨៩៦ គ្រាប់ +(សល់ពីខែមុន ១៣.៣១៨ គ្រាប់ ស្មើនឹង ៤៧៧.២១៤ គ្រាប់) និងខ្សែផ្ទុះ២៧.៦៨០ ម៉ែត្រ +(សល់ពីខែមុន ២.២០៤ ម៉ែត្រ ស្មើនឹង ២៩.៨៨៤ ម៉ែត្រ។

– ជាតិផ្ទុះយកទៅប្រើប្រាស់៖ ស៊ុបដាយចំនួន ១៩៦.០៤៦ គីឡូក្រាម អាម៉ូញូមនីត្រាតចំនួន ៧៣៤.៩៥៤ គីឡូក្រាម គីបផ្ទុះចំនួន ៥០.២៥៨ គ្រាប់ និងខ្សែផ្ទុះ ៣៥.២៦០ ម៉ែត្រ។

– ជាតិផ្ទុះនៅសល់ក្នុងឃ្លាំង ៖ស៊ុបដាយចំនួន ៦៧.៥០៧ គីឡូក្រាម អាម៉ូញូមនីត្រាតចំនួន ១៧១.៩៣៦ គីឡូក្រាម គីបផ្ទុះចំនួន ៤២៦.៩៥៦ គ្រាប់ និងខ្សែផ្ទុះ ៥.៣៧៦ ម៉ែត្រ។

**–ការងារអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព**

–បានចុះផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ច្បាប់ពាក់ព័ន្ធផ្សេងៗ ចំនួន ៦.៥៩៨ លើក (៨៧/៨៧ ឃុំ ៨/៨ ក្រុង ស្រុក) មានប្រជាពលរដ្ឋចូលរួមចំនួន ២៨៣.៩៣៥ នាក់ ស្រី ១៣៩.៩០៨ នាក់។

–បានចុះធ្វើវេទិការសាធារណៈចំនួន ១.៦៦០លើក (៧៧/៨៧ឃុំ សង្កាត់ និង៨/៨ក្រុង ស្រុក) មានប្រជាពលរដ្ឋចូលរួមសរុបចំនួន ៥៣.១៧០ នាក់ ស្រី ៣០.២៨៧ នាក់។

–**ការងារអត្តសញ្ញាណប័ណ្ណ**

- បានទទួលអត្តសញ្ញាណប័ណ្ណពីនាយកដ្ឋានចំនួន ២៨.៨៤២ សន្លឹក និងបានចែកជូនប្រជាពលរដ្ឋប្រើប្រាស់មានចំនួន ២៨.៨៤២ នាក់ ប្រុស ១២.៨០០ នាក់ សរុបចំនួន ៦១៨.៥១៣ នាក់ ប្រុស ២៩២.៩១០ នាក់។
- បានបំពេញបែបបទផ្តល់អត្តសញ្ញាប័ណ្ណជូនប្រជាពលរដ្ឋប្រើប្រាស់ចំនួន ២៥.៣០៨ នាក់ ប្រុស ១៣.២០៩ នាក់ សរុបរួមឆ្នាំ២០១៩ ចំនួន ៦៣៧.៥៥៩ នាក់ ប្រុស ៣១៣.៧៩៤ នាក់។
- នៅសល់ត្រូវផ្តល់បន្តសរុបចំនួន ៧.៦៩៥ នាក់ ប្រុស ៤.២៦០ នាក់។

# ជំពូកទី ២

## គម្រោង សកម្មភាព នៃកម្មវិធីវិនិយោគ

## បីឆ្នាំរំកិលខេត្ត

## ជំពូកទី២ ៖ គម្រោង សកម្មភាព នៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តកំពង់ស្ពឺ ២០២០-២០២២ គឺជាកម្រងឯកសារគោលដ៏មានសារៈសំខាន់សម្រាប់គ្រប់គ្រង តាមដានការវិនិយោគលើគម្រោងអភិវឌ្ឍន៍ប្រកបដោយភាពហ្មត់ចត់ និងច្បាស់លាស់។ គម្រោងវិនិយោគបីឆ្នាំរំកិលខេត្ត ២០២០-២០២២ មានបីប្រភេទគឺ៖

២.១. ប្រភពមូលនិធិឆ្នាំ ២០២០

២.២ គម្រោង សកម្មភាពកំពុងដំណើរការ

២.៣ គម្រោង សកម្មភាពវិនិយោគមានថវិកាគាំទ្រ

២.៤ គម្រោង សកម្មភាពអាទិភាពមិនទាន់មានថវិកាគាំទ្រ

២.៥ កម្មវិធីប្រតិបត្តិការសេវាសង្គម

២.៦ ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា

២.៧ គម្រោង សកម្មភាពរបស់ក្រសួង ស្ថានប័នកំពុងដំណើរការ

កម្មវិធីវិនិយោគនេះត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំខេត្តកំពង់ស្ពឺ (២០២០-២០២៤) ជាពិសេសវាបានរំលេចចេញនូវប្រភពមូលនិធិ ទុនវិនិយោគ ភ្នាក់ងារអនុវត្ត និងកាលវិភាគអនុវត្តការងារ ដែលចូលរួមវិនិយោគតាមវិស័យនានារបស់ខេត្ត។ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ នៃអាណត្តិទី២របស់ក្រុមប្រឹក្សាខេត្ត ត្រូវបានរៀបចំតាមលំដាប់អាទិភាពរបស់ផ្នែក និងវិស័យនានា និងបានរៀបចំផែនការអនុវត្ត ដើម្បីបំពេញសេចក្តីត្រូវការចាំបាច់ជាបន្ទាន់របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

### តារាង២.១ ៖ សង្ខេបប្រភពមូលនិធិឆ្នាំ ២០២០

| ល.រ | ស្ថាប័ន | ចំនួន គម្រោង | សរុបតម្លៃ គម្រោង (លានរៀល) | ប្រភព មូលនិធិ | ចំនួន គម្រោង | តម្លៃ គម្រោង (លានរៀល) |
|---|---|---|---|---|---|---|
| ១- រដ្ឋបាលខេត្ត | | 12 | 16,670.00 | ថវិកាខេត្ត | 12 | 16,670.00 |
| **សរុប១** | | **12** | **16,670.00** | | **12** | **16,670.00** |
| ២-ការគាំទ្រតាមបណ្តាមន្ទីរ អង្គភាព | | | | | | |
| 1 | មន្ទីរសាធារណការ និងដឹកជញ្ជូន | 28 | 11,278.16 | ថវិការដ្ឋ | 28 | 11,278.16 |
| 2 | មន្ទីរកិច្ចការនារី | 29 | 1,143.77 | ថវិការដ្ឋ | 29 | 1,143.77 |
| 3 | មន្ទីរកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ | 16 | 1,859.88 | ថវិការដ្ឋ | 16 | 1,859.88 |
| | | 1 | 420.00 | ធនាគាពិភពលោក | 1 | 420.00 |
| | | 1 | 396.00 | ថវិការដ្ឋ&ដៃគូរអភិ | 1 | 396.00 |
| | | 1 | 600.00 | NBP | 1 | 600.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | | 1 | 600.00 | EU-PGA-L | 1 | 600.00 |
| | | 1 | 165.60 | JICA | 1 | 165.60 |
| | | 1 | 2.27 | ASPIRE | 1 | 2.27 |
| 4 | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 14 | 3,691.80 | ថវិការដ្ឋ | 14 | 3,691.80 |
| 5 | មន្ទីរធនធានទឹក និងឧតុនិយម | 18 | 2,029.00 | ថវិការដ្ឋ | 18 | 2,029.00 |
| 6 | មន្ទីររ៉ែ និងថាមពល | 9 | 306.50 | ថវិការដ្ឋ | 9 | 306.50 |
| | | 3 | 74.00 | ក្រសួង | 3 | 74.00 |
| 7 | មន្ទីរមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ | 2 | 23.00 | ថវិការដ្ឋ | 2 | 23.00 |
| 8 | មន្ទីរអប់រំយុវជននិងកីឡា | 11 | 27,271.00 | ថវិការដ្ឋ | 11 | 27,271.00 |
| 9 | មន្ទីរទេសចរណ៍ | 1 | 57.00 | ថវិការដ្ឋ | 1 | 57.00 |
| 10 | មន្ទីរសុខាភិបាល | 5 | 8,764.00 | PHD/MoH | 5 | 8,764.00 |
| | | 13 | 9,645.00 | Gov/MoH | 13 | 9,645.00 |
| | | 3 | 2,050.00 | GF/USID | 3 | 2,050.00 |
| | | 1 | 150.00 | HCs | 1 | 150.00 |
| 11 | មន្ទីរសង្គមកិច្ច | 3 | 232,412.00 | ថវិការដ្ឋ | 3 | 232,412.00 |
| | | 2 | 1,356.00 | ថវិការដ្ឋ +NGOs | 2 | 1,356.00 |
| 12 | មន្ទីរបរិស្ថាន | 2 | 300.00 | ថវិការដ្ឋ | 2 | 300.00 |
| 13 | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | 8 | 16,141.00 | ថវិការដ្ឋ | 8 | 16,141.00 |
| 14 | ន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 2 | 165.00 | ថវិការដ្ឋ | 2 | 165.00 |
| | | 1 | 15.00 | ក្រសួង | 1 | 15.00 |
| 15 | មន្ទីរពាណិជ្ជកម្ម | 4 | 657.00 | ថវិការដ្ឋ | 4 | 657.00 |
| | | 1 | 100.00 | ក្រសួង | 1 | 100.00 |
| 16 | មន្ទីរព័ត៌មាន | 18 | 1,002.00 | ថវិការដ្ឋ | 18 | 1,002.00 |
| | | 1 | 200.00 | ក្រសួង | 1 | 200.00 |
| 17 | មន្ទីរ អភិវឌ្ឍន៍ជនបទ | 1 | 65,200.00 | ក្រសួង | 1 | 65,200.00 |
| **សរុប ២** | | 202 | 388,074.98 | | 202 | 388,074.98 |
| **សរុបរួម (១+២)** | | 214 | 404,744.98 | | 214 | 404,744.98 |

## តារាង២.២៖ គម្រោង សកម្មភាពខេត្តកំពុងដំណើរការ

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតប គោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈ ពេល | តម្លៃ | ប្រភព មូលនិធិ | កម្រិតទុនវិនិយោគ(លានរៀល) | | | | អង្គភាព អនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | ២០១៩ | ២០២០ | ២០២១ | សរុប | | |
| **ក.គម្រោង សកម្មភាពរបស់រដ្ឋបាលខេត្ត** | | | | | | | | | | | | | | |
| **១.ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | | | | | |
| 1 | សាងសង់អគារការិយាល័យច្រកចេញចូលតែមួយ | | ស្រុកគងពិសី | 1 | អគារ | | 420.00 | ថវិកាខេត្ត 2019 | 420.00 | 0 | 0 | 420.00 | រដ្ឋបាលខេត្ត | |
| 2 | សាងសង់អគាររដ្ឋបាលសាលាខេត្តជំហានទី៣ | | សាលាខេត្ត | 1 | អគារ | | 4200.00 | ថវិកាខេត្ត 2019 | 4,200.00 | 0 | 0 | 4,200.00 | រដ្ឋបាលខេត្ត | |
| 3 | ជួសជុលរៀបបិកខា ក្រាលកាវ៉ូឡាពុះទ្រូងផ្លូវជាតិលេខ៤ និងបំពាក់បង្គោលភ្លើងភ្លោះ និងស្លាកសញ្ញាចរាចរក្នុងក្រុងច្បារមនប្រវែង ៦,៨៦៩ ម៉ែត្រ | | ក្រុងច្បារមន | 1 | កន្លែង | | 1500.00 | ថវិកាខេត្ត 2019 | 1,500.00 | 0 | 0 | 1,500.00 | រដ្ឋបាលខេត្ត | |
| 4 | ជួសជុលផ្លូវក្រាលកៅស៊ូបេទីម ក្នុងសង្កាត់ស្វាយក្រវ៉ាន់ | | ក្រុងច្បារមន | 1 | ខ្សែ | | 800.00 | ថវិកាខេត្ត 2019 | 800.00 | 0 | 0 | 800.00 | រដ្ឋបាលខេត្ត | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 5 | ចាក់ដីធ្វើប្រាំងស្ទឹង ព្រែកត្នោតជាប់ ស្ពានថ្មីខាងលិច ផ្សារកំពង់ស្ពឺ ចំនួន ១០៦.៥ម៣ | | ក្រុងច្បារមន | 1 | កន្លែង | | 1135.00 | ថវិកាខេត្ត 2019 | 1,135.00 | 0 | 0 | 1,135.00 | រដ្ឋបាលខេត្ត | |
| 6 | ធ្វើរបង រៀបចំបិក ខារ និងក្រាលការ៉ូ ឡាចិញ្ចើមផ្លូវខាង ត្បូងទីលានកីឡា ខេត្ត | | ក្រុងច្បារមន | 1 | កន្លែង | | 280.00 | ថវិកាខេត្ត 2019 | 280.00 | 0 | 0 | 280.00 | រដ្ឋបាលខេត្ត | |
| **សរុបរង ១** | | | | | | | 8335.00 | | 8335.00 | 0.0 | 0.0 | 8335.00 | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| **សរុបរង ២** | | | | | | | 0 | | 0 | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| **សរុបរង ៣** | | | | | | | 0 | | 0 | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| **សរុបរង ៤** | | | | | | | 0 | | 0 | | | | | |
| **សរុប ក:** (១+២+៣+៤) | | | | | | | 8,335 | | 8,335 | 0 | 0 | 8,335 | | |
| **ខ.គម្រោង សកម្មភាពរបស់មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធ** | | | | | | | | | | | | | | |
| **១.ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | គម្រោងជួសជុលផ្លូវខេត្តលេខ១៤១ | | សាលាខេត្ត, ក្រុងច្បារមន ភូមិសៅកែ, ស្រុកសំរោងទង | 2 | km | | 1,000.00 | ថវិការដ្ឋ | 1,000.00 | 0 | 0 | 1,000.00 | មន្ទីរ សាធារណការ និងដឹកជញ្ជូន | |
| 2 | គម្រោងស្ថាបនាលូផ្លូវលេខ១៣២ | | ឃុំអូរ- ភូមិព្រះខែ ស្រុកភ្នំស្រួច | 3.8 | km | | 1,500.00 | ថវិការដ្ឋ | 1,500.00 | 0 | 0 | 1,500.00 | មន្ទីរ សាធារណការ និងដឹកជញ្ជូន | |
| 3 | គម្រោងជួសជុលផ្លូវខេត្តលេខ ១៤៤០ | | ពីផ្សារក្រាំងចេក ដល់ជើងរាស់ ស្រុកឧដុង្គ | 2 | km | | 1,000.00 | ថវិការដ្ឋ | 1,000.00 | 0 | 0 | 1,000.00 | មន្ទីរ សាធារណការ និងដឹកជញ្ជូន | |
| 4 | គម្រោងផ្លូវជាតិលេខ៤ | | ថ្នល់ទទឹង ស្រុកសំរោងទង-ឃុំអូរ, ស្រុកភ្នំស្រួច | 21 | km | | 1,087.41 | ថវិការដ្ឋ | 1,087.41 | 0 | 0 | 1,087.41 | មន្ទីរ សាធារណការ និងដឹកជញ្ជូន | |
| 5 | គម្រោងផ្លូវជាតិលេខ៤១ | | ថ្នល់ទទឹង ស្រុកសំរោងទង-ដំណាក់ខ្លុង ស្រុកបសេដ្ឋ | 45.5 | km | | 1,138.94 | ថវិការដ្ឋ | 1,138.94 | 0 | 0 | 1,138.94 | មន្ទីរ សាធារណការ និងដឹកជញ្ជូន | |
| 6 | គម្រោងផ្លូវជាតិលេខ៤៤ | | ច្បារមន ក្រុងច្បារមន-ឧដុង្គ ស្រុកឧដុង្គ | 139.6 | km | | 927.26 | ថវិការដ្ឋ | 927.26 | 0 | 0 | 927.26 | មន្ទីរ សាធារណការ និងដឹកជញ្ជូន | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 7 | គម្រោងផ្លូវជាតិលេខ៤៦ | | ស្ពានដែកអូរសំចត-ឧទ្យានជាតិគិរីរម្យ ស្រុកភ្នំស្រួច | 16.9 | km | | 286.53 | ថវិការដ្ឋ | 286.53 | 0 | 0 | 286.53 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 8 | គម្រោងផ្លូវជាតិលេខ១៣០ | | ច្បារមន ក្រុងច្បារមន-ឃុំរលាំងគ្រើល ស្រុកសំរោងទង | 9.6 | km | | 94.91 | ថវិការដ្ឋ | 94.91 | 0 | 0 | 94.91 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 9 | គម្រោងផ្លូវខេត្តលេខ១៤១ | | ផ្សារព្រៃផ្តៅ-ភូមិដែកភ្លើង ស្រុកសំរោងទង | 4.2 | km | | 53.76 | ថវិការដ្ឋ | 53.76 | 0 | 0 | 53.76 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 10 | គម្រោងផ្លូវជាតិលេខ១៤៧ | | ផ្លូវជាតិលេខ៤-ផ្លូវជាតិលេខ៤៣ ស្រុកភ្នំស្រួច | 22 | km | | 216.26 | ថវិការដ្ឋ | 216.26 | 0 | 0 | 216.26 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 11 | គម្រោងផ្លូវខេត្តលេខ១៤៤០ | | ប្រឡាយ ច្បារមន ក្រុងច្បារមន-ភូមិក្រាំងចេក ស្រុកឧដុង្គ | 13 | km | | 112.60 | ថវិការដ្ឋ | 112.60 | 0 | 0 | 112.60 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 12 | គម្រោងផ្លូវខេត្តលេខ1ks1 | | ផ្លូវខេត្តលេខ១៤៤០-សាលាឃុំព្រៃក្រសាំង ស្រុកឧដុង្គ | 3.4 | km | | 35.09 | ថវិការដ្ឋ | 35.09 | 0 | 0 | 35.09 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 13 | គម្រោងផ្លូវជាតិលេខ៤៣ | | ត្រែងត្រយឹង -អូរកូនត្រុំ ស្រុកភ្នំស្រួច | 22 | km | | 192.70 | ថវិការដ្ឋ | 192.70 | 0 | 0 | 192.70 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 14 | គម្រោងផ្លូវជាតិលេខ៤៨-៤ | | រង្វង់មូលកន្ទួតតទឹកពុះ ស្រុកឱរ៉ាល់ | 15 | km | | 128.02 | ថវិការដ្ឋ | 128.02 | 0 | 0 | 128.02 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 15 | គម្រោងផ្លូវខេត្តលេខ១៤០ | | ផ្សារព្រៃផ្តៅ ស្រុកសំរោងទង-ឃុំជើងរាស់ ស្រុកឧដុង្គ | 6.3 | km | | 57.62 | ថវិការដ្ឋ | 57.62 | 0 | 0 | 57.62 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 16 | គម្រោងផ្លូវខេត្តលេខ១៤០-អា | | ផ្លូវជាតិ៤ សំរោងទង-ផ្លូវលេខ៥១ បេ ស្រុកឧដុង្គ | 3.7 | km | | 32.17 | ថវិការដ្ឋ | 32.17 | 0 | 0 | 32.17 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 17 | គម្រោងផ្លូវខេត្តលេខ១៤៤០ | | ភូមិក្រាំងចេក-ផ្សារបាត់ដឹង ស្រុកឧដុង្គ | 19 | km | | 159.05 | ថវិការដ្ឋ | 159.05 | 0 | 0 | 159.05 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 18 | គម្រោងផ្លូវខេត្តលេខ១កាអេស១ | | ថ្មគស់ភ្នំខ្ពង់ ស្រុកថ្ពង-ចាន់ថ្នាល ស្រុកឧដុង្គ | 9.62 | km | | 84.02 | ថវិការដ្ឋ | 84.02 | 0 | 0 | 84.02 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 19 | គម្រោងផ្លូវខេត្តលេខ១កាអេស៣ | | ផ្លូវបំបែក អមលាំង-វត្តជ្រាវ ស្រុកថ្ពង | 15.05 | km | | 132.57 | ថវិការដ្ឋ | 132.57 | 0 | 0 | 132.57 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 20 | គម្រោងផ្លូវខេត្ត លេខ១កាអេស៤ | | ផ្សារសំរោង ស្រុកថ្ពង-ផ្លូវខេត្ត១៤៤០ ស្រុកឧដុង្គ | 22.23 | km | | 210.08 | ថវិការដ្ឋ | 210.08 | 0 | 0 | 210.08 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 21 | ផ្លូវខេត្ត ទេសចរណ៍ ភ្នំព្រះ | | ១កាអេស១- ផ្លូវជាតិ៤៤ ស្រុកថ្ពង | 20 | km | | 215.26 | ថវិការដ្ឋ | 215.26 | 0 | 0 | 215.26 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 22 | ផ្លូវ សម្តេចនាយករដ្ឋមន្ត្រី | | ត្រែងត្រយឹង ស្រុកភ្នំស្រួច-រង្វង់មូលកន្ទួត៤៤ ស្រុកឱរ៉ាល់ | 56.3 | km | | 613.54 | ថវិការដ្ឋ | 613.54 | 0 | 0 | 613.54 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 23 | ផ្លូវខេត្ត ០១៦ | | ឃុំចាន់សែន- ឃុំមានជយ ស្រុកឧដុង្គ | 11.7 | km | | 92.22 | ថវិការដ្ឋ | 92.22 | 0 | 0 | 92.22 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 24 | ផ្លូវខេត្ត ៩២៩ | | ផ្សារត្រពាំងជោរ- ភូមិស្រែកិន ស្រុកឱរ៉ាល់ | 13 | km | | 101.23 | ថវិការដ្ឋ | 101.23 | 0 | 0 | 101.23 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 25 | ផ្លូវខេត្ត អ៊ែរ៣០ អ៊ែរ៣៦ | | ឃុំដំណាក់រាំង- ឃុំជើងរាស់ ស្រុកឧដុង្គ | 14 | km | | 109.65 | ថវិការដ្ឋ | 109.65 | 0 | 0 | 109.65 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 26 | ផ្លូវខេត្ត ៣៣៣.៣៣៧ | | ឃុំភ្នំតូច- ឃុំក្រាំងចេក ស្រុកឧដុង្គ | 18 | km | | 139.21 | ថវិការដ្ឋ | 139.21 | 0 | 0 | 139.21 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 27 | ផ្លូវខេត្ត ៦៧៦.៦៨៤ | | ភូមិផ្លូវត្នោត ភូមិក្រាំងតាវង្ស ស្រុកសំរោងទង | 7.5 | km | | 58.05 | ថវិការដ្ឋ | 58.05 | 0 | 0 | 58.05 | មន្ទីរសាធារណការ និងដឹកជញ្ជូន | |
| 28 | កសាង និងពង្រឹងសមត្ថភាពស្ត្រីក្នុងកិច្ចដំណើរការក្រុមជួយខ្លួនឯង | | ស្រុកគងពិសី | 3 | ក្រុម | | 9.14 | ថវិការដ្ឋ | 9.14 | 0 | 0 | 9.14 | មន្ទីរកិច្ចការនារី | |
| 29 | ចុះត្រួតពិនិត្យ និងប្រជុំជាមួយក្រុមផលិត | | ស្រុកបសេដ្ឋ | 24 | លើក | | 10.42 | ថវិការដ្ឋ | 10.42 | 0 | 0 | 10.42 | មន្ទីរកិច្ចការនារី | |
| 30 | ផ្តល់ជំនាញវិជ្ជាជីវៈ និងបំណិនជីវិត (កាត់ដេរ និងតម្បាញ)ដល់ក្រុមស្ត្រី | | គ្រប់ស្រុក/ក្រុង ទាំង៨ | 6 | វគ្គ | | 435.60 | ថវិការដ្ឋ | 435.60 | 0 | 0 | 435.60 | មន្ទីរកិច្ចការនារី | |
| 31 | ផ្តល់ជំនាញវិជ្ជាជីវៈ និងបំណិនជីវិត(កែច្នៃចំណីអាហារ) ដល់ក្រុមស្ត្រី | | ស្រុកថ្ពង ឱរ៉ាល់ បសេដ្ឋ ឧដុង្គ និងគងពិសី | 6 | វគ្គ | | 62.22 | ថវិការដ្ឋ | 62.22 | 0 | 0 | 62.22 | មន្ទីរកិច្ចការនារី | |
| 32 | កសាង និងពង្រឹងសមត្ថភាពស្ត្រីក្នុងកិច្ចដំណើរការកសាងអាជីវកម្ម | | ក្រុង/ស្រុកទាំង៨ | 6 | លើក | | 5.36 | ថវិការដ្ឋ | 5.36 | 0 | 0 | 5.36 | មន្ទីរកិច្ចការនារី | |
| 33 | ជំរុញផលិតកម្មដំណាំកសិកម្ម | | ក្រុង/ស្រុកទាំង៨ | 129 | វគ្គ | | 1.48 | ថវិការដ្ឋ | 1.48 | 0 | 0 | 1.48 | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | |
| 34 | អភិវឌ្ឍន៍កសិកម្មសហគមន៍កសិកម្ម | | ក្រុង/ស្រុកទាំង៨ | 18 | វគ្គ | | 15.00 | ថវិការដ្ឋ | 15.00 | 0 | 0 | 15.00 | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 35 | ជំរុញការអភិវឌ្ឍន៍ កសិឧស្សាហកម្ម | | ៣ស្រុក | 12 | វគ្គ | | 9.00 | ថវិការដ្ឋ | 9.00 | 0 | 0 | 9.00 | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | |
| 36 | អភិវឌ្ឍន៍ដំណាំ កៅស៊ូ | | ក្រុង/ស្រុក ទាំង៨ | 12 | វគ្គ | | 9.00 | ថវិការដ្ឋ | 9.00 | 0 | 0 | 9.00 | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | |
| 37 | អភិវឌ្ឍន៍ធនធាន មនុស្ស និង បញ្ញាបយេនឌ័រ | | ក្រុង/ស្រុក ទាំង៨ | 6 | វគ្គ | | 6.00 | ថវិការដ្ឋ | 6.00 | 0 | 0 | 6.00 | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | |
| 38 | រៀបចំ អនុវត្តតាម ដាន និងវាយតម្លៃ ផែនការនិងថវិកា | | ក្រុង/ស្រុក ទាំង៨ | 45 | លើក | | 9.00 | ថវិការដ្ឋ | 9.00 | 0 | 0 | 9.00 | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | |
| 39 | អង្កេតស្ទង់ទិន្នផល និងផ្តល់ព័ត៌មាន ស្ថិតិកសិកម្ម | | ក្រុង/ស្រុក ទាំង៨ | 1500 | សំណាក | | 9.00 | ថវិការដ្ឋ | 9.00 | 0 | 0 | 9.00 | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | |
| 40 | អភិវឌ្ឍន៍ការចិញ្ចឹម សត្វ | | ក្រុង/ស្រុក ទាំង៨ | 21 | វគ្គ | | 147.00 | ថវិការដ្ឋ | 147.00 | 0 | 0 | 147.00 | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | |
| 41 | គ្រប់គ្រងអនាម័យ សត្វ សាច់ និង ផលិតផលមាន ដើមកំណើតពីសត្វ | | ក្រុង/ស្រុក ទាំង៨ | 18 | វគ្គ | | 21.00 | ថវិការដ្ឋ | 21.00 | 0 | 0 | 21.00 | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | |
| 42 | ទប់ស្កាត់ជំងឺឆ្លង សត្វ និងផ្តល់សេវា កម្មសុខភាពសត្វ | | ក្រុង/ស្រុក ទាំង៨ | 18 | វគ្គ | | 72.00 | ថវិការដ្ឋ | 72.00 | 0 | 0 | 72.00 | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | |
| 43 | សិក្ខាសាលា ផ្សព្វផ្សាយ ច្បាប់ ស្តីពីការងារ លិខិត បទដ្ឋានគតិយុត្តិ នានាដល់ បុគ្គលិក | | រោចក្រសហ គ្រាស ក្នុង ខេត្តកំពង់ស្ពឺ | 270 | នាក់ | | 16.80 | ថវិការដ្ឋ | 16.80 | 0 | 0 | 16.80 | មន្ទីរការងារ និងបណ្តុះប ណ្តាលវិជ្ជាជី វៈ | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | អង្គការវិជ្ជាជីវៈ និង កម្មករនិយោជិត នៅតាមរោចក្រ សហគ្រាស | | | | | | | | | | | | | |
| 44 | គម្រោងបណ្តុះ បណ្តាល សញ្ញាបត្រ បច្ចេកទេសនិងវិជ្ជា ជីវៈ១ | | ឃុំកាហែង | 50 | នាក់ | | 50.00 | ថវិការដ្ឋ | 50.00 | 0 | 0 | 50.00 | មន្ទីរការងារ និងបណ្តុះប ណ្តាលវិជ្ជាជី វៈ | |
| 45 | គម្រោងបណ្តុះ បណ្តាលសញ្ញាបត្រ បច្ចេកទេសនិងវិជ្ជា ជីវៈ២ | | ឃុំកាហែង | 11 | នាក់ | | 37.00 | ថវិការដ្ឋ | 37.00 | 0 | 0 | 37.00 | មន្ទីរការងារ និងបណ្តុះប ណ្តាលវិជ្ជាជី វៈ | |
| 46 | គម្រោងបណ្តុះ បណ្តាល សញ្ញាបត្រ បច្ចេកទេសនិងវិជ្ជា ជីវៈ៣ | | ឃុំកាហែង | 150 | នាក់ | | 11.00 | ថវិការដ្ឋ | 11.00 | 0 | 0 | 11.00 | មន្ទីរការងារ និងបណ្តុះប ណ្តាលវិជ្ជាជី វៈ | |
| 47 | គម្រោងបណ្តុះ បណ្តាល សញ្ញាបត្រ ជាន់ខ្ពស់ បច្ចេកទេស | | ឃុំកាហែង | 65 | នាក់ | | 39.00 | ថវិការដ្ឋ | 39.00 | 0 | 0 | 39.00 | មន្ទីរការងារ និងបណ្តុះប ណ្តាលវិជ្ជាជី វៈ | |
| 48 | គម្រោងបណ្តុះ បណ្តាល ការសិក្សា វគ្គខ្លី តាមរយៈថវិកា ទ្រទ្រង់ គ្រឹះស្ថាន សិក្សា( PB) | | ឃុំកាហែង | 150 | នាក់ | | 60.00 | ថវិការដ្ឋ | 60.00 | 0 | 0 | 60.00 | មន្ទីរការងារ និងបណ្តុះប ណ្តាលវិជ្ជាជី វៈ | |
| 49 | ជួសជុល រួចថែទាំ ជាប្រចាំ ប្រព័ន្ធធារា សាស្រ្ត អង្គតាកិប | | និទាន | 1 | គម្រោង | | 212.00 | រាជរដ្ឋាភិ បាល | 212.00 | 0 | 0 | 212.00 | មន្ទីរធនធាន ទឹក និងឧតុ និយម | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 50 | ជួសជុល រួចថែទាំ ជាប្រចាំ ប្រព័ន្ធធារាសាស្ត្រ ស្វាយ | | បសេដ្ឋ | 1 | គម្រោង | | 453.00 | រាជរដ្ឋាភិបាល | 453.00 | 0 | 0 | 453.00 | មន្ទីរធនធានទឹក និងឧតុនិយម | |
| 51 | ជួសជុល រួចថែទាំ ជាប្រចាំ ប្រព័ន្ធធារាសាស្ត្រ រកា | | ស្រង់ | 1 | គម្រោង | | 62.00 | រាជរដ្ឋាភិបាល | 62.00 | 0 | 0 | 62.00 | មន្ទីរធនធានទឹក និងឧតុនិយម | |
| 52 | ជួសជុល រួចថែទាំ ជាប្រចាំ ប្រព័ន្ធធារាសាស្ត្រ អូរគ្រែង | | គងពិសី | 1 | គម្រោង | | 127.00 | រាជរដ្ឋាភិបាល | 127.00 | 0 | 0 | 127.00 | មន្ទីរធនធានទឹក និងឧតុនិយម | |
| 53 | ជួសជុល រួចថែទាំ ជាប្រចាំ ប្រព័ន្ធធារាសាស្ត្រ ចំការដូង | | ពេជ្រមុនី | 1 | គម្រោង | | 87.00 | រាជរដ្ឋាភិបាល | 87.00 | 0 | 0 | 87.00 | មន្ទីរធនធានទឹក និងឧតុនិយម | |
| 54 | ជួសជុល រួចថែទាំ ជាប្រចាំ ប្រព័ន្ធធារាសាស្ត្រ តាហោ | | គងពិសី | 1 | គម្រោង | | 189.00 | រាជរដ្ឋាភិបាល | 189.00 | 0 | 0 | 189.00 | មន្ទីរធនធានទឹក និងឧតុនិយម | |
| 55 | ជួសជុល រួចថែទាំ ជាប្រចាំ ប្រព័ន្ធធារាសាស្ត្រ អូរវែង | | ជង្រុក | 1 | គម្រោង | | 147.00 | រាជរដ្ឋាភិបាល | 147.00 | 0 | 0 | 147.00 | មន្ទីរធនធានទឹក និងឧតុនិយម | |
| 56 | ជួសជុល រួចថែទាំ ជាប្រចាំ ប្រព័ន្ធធារាសាស្ត្រ ចាន់ថ្នាល | | គងពិសី | 1 | គម្រោង | | 111.00 | រាជរដ្ឋាភិបាល | 111.00 | 0 | 0 | 111.00 | មន្ទីរធនធានទឹក និងឧតុនិយម | |
| 57 | ជួសជុល រួចថែទាំ ជាប្រចាំ ប្រព័ន្ធធារាសាស្ត្រ អូរស្បា | | ព្រៃវិហារ | 1 | គម្រោង | | 96.00 | រាជរដ្ឋាភិបាល | 96.00 | 0 | 0 | 96.00 | មន្ទីរធនធានទឹក និងឧតុនិយម | |
| 58 | ពង្រឹង ស.ក.ប.ទ អង្គតាកិប | | គងពិសី | 1 | គម្រោង | | 55.00 | រាជរដ្ឋាភិបាល | 55.00 | 0 | 0 | 55.00 | មន្ទីរធនធានទឹក និងឧតុនិយម | |
| 59 | ពង្រឹង ស.ក.ប.ទ អូរគ្រែង | | ត្រពាំងគង | 1 | គម្រោង | | 55.00 | រាជរដ្ឋាភិបាល | 55.00 | 0 | 0 | 55.00 | មន្ទីរធនធានទឹក និងឧតុនិយម | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 60 | ពង្រឹង ស.ក.ប.ទ ចំការដូង | | សំរោងទង | 1 | គម្រោង | | 55.00 | រាជរដ្ឋាភិបាល | 55.00 | 0 | 0 | 55.00 | មន្ទីរធនធានទឹក និងឧតុនិយម | |
